ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# របាយការណ៍បូកសរុបលទ្ធផល
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២០
# និងទិសដៅអនុវត្ត ឆ្នាំ ២០២១

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

# សារលិខិតថ្លែងអំណរគុណ



សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់

សម្តេច ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំស្ថាប័នកំពូល និងគ្រប់ក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងនៅតាមបណ្តាស្ថានតំណាង នៅក្រៅប្រទេស

លោក លោកស្រីថ្នាក់ដឹកនាំ មន្ត្រីគ្រប់ថ្នាក់ ក្នុងរដ្ឋបាលសាធារណៈ អាជ្ញាធរ លោកគ្រូ អ្នកគ្រូ និងកងកម្លាំង សមត្ថកិច្ចគ្រប់ប្រភេទ ទាំងនៅក្នុងប្រទេស និងនៅឈរជើងតាមតំបន់ព្រំដែន

លោក លោកស្រី ជាដៃគូពាក់ព័ន្ធក្នុងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន បព្វជិតគ្រប់និកាយសាសនា និងបងប្អូនជនរួមជាតិ ទាំងអស់ ជាទីស្រឡាញ់រាប់អាន

រំលឹកដល់ព្រឹត្តិការណ៍ដែលកើតមានជាបន្តបន្ទាប់ក្នុងឆ្នាំ២០២០កន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជាយើងពិតជាបានទទួលរងឥទ្ធិពលនៃភាពប្រឈមជាសាកល ដែលបង្កនូវការលំបាកស្មុគស្មាញជាបន្តបន្ទាប់ រួមមានផលប៉ះពាល់វិស័យសេដ្ឋកិច្ច គ្រោះធម្មជាតិ ទឹកជំនន់ ព្យុះ ខ្យល់កន្ត្រាក់ ថែមទាំងការឆ្លងរាលដាលជម្ងឺកូវីដ ១៩ ដែលជះឥទ្ធិពលដល់ការបាត់បង់ការងារ ដល់កម្មករ កម្មការិនីក្នុងស្រុក និងពលករពលការិនីដែលជាជនទេសន្តរប្រវេសន៍នៅក្រៅប្រទេស ធ្វើឲ្យពួកគាត់សម្រេចចិត្តវិលត្រឡប់មកមាតុភូមិវិញជាង១៧ម៉ឺននាក់ ទោះបីជាប្រទេសជិតខាង ដាក់វិធានការបិទព្រំដែនដើម្បីទប់ស្កាត់ភាពចល័តដែលពិបាកគ្រប់គ្រង និងបង្កហានិភ័យដោយជម្ងឺ កូវីដ ១៩ ក៏ដោយ ។

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ដើម្បីគោរព ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ**សម្តេចអគ្គមហាសេនាបតី**តេជោ **ហ៊ុន សែន** ដែលបានដាក់ចេញនូវគ្រប់វិធានការ ក្នុងការដោះស្រាយបញ្ហាទុក្ខលំបាករបស់ប្រជាពលរដ្ឋក្នុងកាលៈទេសៈដ៏លំបាកនេះ និងបានគាំទ្រនូវវិធានការរឹតបន្តឹង ក្នុងគោលដៅបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេស ការនាំមនុស្សឆ្លងដែនខុសច្បាប់ ដែលជាបទល្មើសឧក្រិដ្ឋកម្មឆ្លងដែនផង និងជាការបង្កនូវមហន្តរាយពីការឆ្លងនិងចម្លង កូវីដ១៩ ដល់សង្គមជាតិផង ។ ការដាក់ចេញនូវវិធានការទាំងនេះ បានធ្វើឲ្យមានការចូលរួម អបអរសាទរ និងមានការគាំទ្រពីគ្រប់មជ្ឈដ្ឋាន និងសម្រួលឲ្យការវែកមុខជនល្មើស ការបង្ក្រាប និងការផ្តន្ទាទោស អាចប្រព្រឹត្តទៅបានដោយជោគជ័យ រហូតធ្វើឲ្យអង្គការទេសន្តរប្រវេសន៍អន្តរជាតិ ទទួលស្គាល់ និងដាក់បញ្ចូលព្រះរាជាណាចក្រកម្ពុជា ជា «**ប្រទេសជ័យលាភី ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់**» ។

មួយវិញទៀត ខ្ញុំសូមអរគុណ និងកោតសរសើរដោយស្មោះ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃគ្រប់ក្រសួងស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូជាតិ និងអន្តរជាតិ និងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅគ្រប់ប្រទេសពាក់ព័ន្ធ ដែលបានរួមសហការប្រកបដោយការទទួល

ខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ សាមគ្គីឯកភាព រួមគ្នាជាធ្លុងមួយ ស្រុសដៃគ្នាដោះស្រាយបញ្ហាប្រឈមចំពោះមុខ នៅគ្រប់ទីកន្លែង ទាំងនៅព្រំដែន ទាំងនៅផ្ទៃក្នុងប្រទេស ដោយគ្មានការធ្វេសប្រហែស រហូតរក្សាបាននូវស្ថានភាពនឹងន និងអាចគ្រប់គ្រងបាន គ្រប់ស្ថានភាព ។

ទោះបីជាមានបន្ទុកធ្ងន់ធ្ងរដែលត្រូវដោះស្រាយយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជា មិនព្រងើយកន្តើយក្នុងការបង្កើនការស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាបរាល់បទល្មើស និងសង្គ្រោះជនរងគ្រោះនោះឡើយ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបានពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងការរាតត្បាតដោយជំងឺកូវីដ-១៩ក៏ដោយ។

ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ដែលត្រូវយកចិត្តទុកដាក់ដើម្បីសុវត្ថិភាពនិងសុខុមាលភាពប្រជាជន ។ ដៃម្ខាង រួមគ្នាបង្ការទប់ស្កាត់ការនាំចូលជំងឺកូវីដ-១៩ ទៅក្នុងសហគមន៍ ដៃម្ខាងទៀតការដោះស្រាយភាពប្រឈម និងជីវភាពប្រជាពលរដ្ឋ ក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលក្នុងនោះ ទាំងរាជរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជនបានចូលរួមលះបង់ខ្ពស់ប្រកបដោយស្មារតីមនុស្សធម៌ ។ ទន្ទឹមនឹងនោះ មេខ្យល់បានឆ្លៀតឱកាសចលនាអូសទាញពលករឲ្យចេញទៅប្រទេសក្រៅវិញ ក្នុងស្ថានភាពកំពុងប្រឈមខ្លាំង ធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស និងវិបត្តិកូវីដ ១៩ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះសមត្ថកិច្ចយើង ដែលបានសហការគ្នាទប់ស្កាត់ និងបង្ក្រាបសកម្មភាពទាំងនោះបានជាបន្តបន្ទាប់ និងនៅតែបន្តតាមដានស្វែងរកមេខ្យល់ និងមេខ្លោងដើម្បីផ្តន្ទាទោសតាមច្បាប់ដោយមិនមានការអត់ឱនឲ្យឡើយ ។

ខ្ញុំសូមបួងសួងដល់ព្រះរតនត្រ័យ បារមីវត្ថុសក្តិសិទ្ធិក្នុងលោក សូមជួយបីបាច់រក្សា ព្រះករុណាព្រះមហាក្សត្រ និងព្រះមហាក្សត្រីយ៍ ព្រះវររាជមាតាជាតិខ្មែរជាទីគោរពសក្ការៈ សម្តេច ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សម្តេចកិត្តិព្រឹទ្ធបណ្ឌិត សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការ កងកម្លាំង និងប្រជាពលរដ្ឋគ្រប់រូប សូមមានសិរីសួស្តី ជ័យមង្គលវិបុលសុខ គ្រប់ប្រការ និងសូមឲ្យមានព្រះសុខភាពល្អបរិបូណ៌ និងសុខភាពមាំមួន កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃសុក្រ ១៣ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១

**ប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា

I. ស្ថានភាពទូទៅ ........ 1

II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ........ 2

ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ........ 2

ក.១. ការកសាងច្បាប់ ........ 2

ក.២. បទដ្ឋានគតិយុត្ត ........ 2

ក.៣. ការពង្រឹងកិច្ចសហប្រតិបត្តិការ ........ 3

ខ. ការបង្ការ ទប់ស្កាត់ ........ 5

ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង ........ 5

ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ ........ 5

ខ.១.២.ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ........ 6

ខ.១.៣. ការអប់រំផ្សព្វផ្សាយដោយផ្ទាល់ ........ 6

ខ.១.៤. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ ........ 7

ខ.១.៥. ការផ្សព្វផ្សាយតាមរយៈឧបករណ៍ផ្សព្វផ្សាយ (IEC) ........ 10

ខ.១.៦. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក ........ 12

ខ.១.៧. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីនានា ........ 13

ខ.២. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ ........ 15

ខ.២.១. ការបង្កើតកម្មវិធីសិក្សា ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ........ 15

ខ.២.២. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ ........ 15

ខ.២.៣. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក ........ 17

ខ.២.៤. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ ........ 20

ខ.២.៥. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរូបភាព រៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ........ 20

ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ........ 20

ខ.៤. ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន ........ 22

គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ........ 23

គ.១. ការងារអនុវត្តច្បាប់ ........ 23

គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ ........ 23

គ.២. កិច្ចការយុត្តិធម៌ ........ 24

គ.២.១. លទ្ធផលចំណាត់ការផ្តន្ទាទោស ........ 25

១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ៖ ........ 25

២ .ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖ ........ 25

ឃ. កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវាគាំទ្រ....26
ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព....26
ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់....26
ឃ.១.២. ការទទួលសាកសពបញ្ជូនត្រឡប់....27
ឃ.២. ការផ្ដល់សេវា និងការស្ដារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស....28
ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ....28
III.ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល....29
ក. ការបណ្ដុះបណ្ដាល និងសិក្ខាសាលា....29
ក.១. ការងារបណ្ដុះបណ្ដាល....29
ក.១.១.ការបណ្ដុះបណ្ដាលក្នុងប្រទេស....29
ក.២. សិក្ខាសាលា....30
ក.២.១.សិក្ខាសាលាក្នុងប្រទេស....30
ក.២.២. សិក្ខាសាលាក្រៅប្រទេស....31
ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ....31
ខ.១. សន្និសីទ កិច្ចប្រជុំ ក្នុងប្រទេស និងក្រៅប្រទេស....31
ខ.២. ការទទួលជួបពិភាក្សាការងារ....32
ខ.៣.ការងារទស្សនកិច្ច....34
ខ.៤. ការងារសម្របសម្រួល....34
IV.ការសន្និដ្ឋានវាយតម្លៃ....34
ក. ចំណុចខ្លាំង....34
ខ. ចំណុចខ្វះខាត ឬភាពប្រឈម....34
គ. សំណូមពរ....35
ឃ. សន្និដ្ឋាន....35
V.ទិសដៅ ឆ្នាំ ២០២១....36
ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ....36
ខ. ការងារបង្ការ ទប់ស្កាត់....36
គ. ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ....37
ឃ. ការងារការពារជនរងគ្រោះ....38
ង. ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ....39
- ឧបសម្ព័ន្ធ
- កម្រងរូបភាព

# របាយការណ៍ឆ្នាំ២០២០
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២១

## I. ស្ថានភាពទូទៅ

ក្នុងឆ្នាំ២០២០នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ក្រសួងស្ថាប័នរាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក គ្រោះធម្មជាតិ(ទឹកជំនន់) និងការរាតត្បាតដោយជំងឺកូវីដ-១៩ ក៏ដោយ។

ស្ថានភាពប្រែប្រួល ចាប់ផ្តើមពីខែមីនា ឆ្នាំ២០២០ ដែលធ្វើឱ្យក្រសួងស្ថាប័ន និងរាជធានី ខេត្ត ត្រូវប្តូរទិសដៅ និងរបៀបរបបការងារ ឱ្យផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេស អ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួន ច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ដើម្បីបង្ការទប់ស្កាត់ការនាំចូលជំងឺកូវីដ-១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈម ក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់សកម្មភាពមេខ្យល់ ក្នុងការចលនាអូសទាញឱ្យពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលកំពុងតែមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជម្ងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក បែងចែកការទទួលខុសត្រូវ ឱ្យនៅប្រចាំការនៅតាមព្រំដែន ដើម្បីទទួល និងសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ ការរៀបចំទីតាំងសម្រាប់ការធ្វើចត្តាឡីស័ក ការតាមដានអ្នកដែលមានផ្ទុកមេរោគកូវីដ-១៩ និងការផ្តល់សេវាសុខភាព ការអនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូនឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព ព្រមទាំងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាពសុខភាព និងជីវភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំបង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅ ក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិកគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី

ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងបង្កើនកិច្ចប្រតិបត្តិការក្នុងគោលដៅដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- **រដ្ឋសភា** បានអនុម័ត៖
  - ច្បាប់ស្តីពី ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ(MLA) និងត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ជាការប្រញាប់ ដោយព្រះរាជក្រម លេខ នស/រកម ០៦២០/០២០ នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០។
  - ច្បាប់ស្តីពី ការប្រឆាំង សម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។
  - ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាទ្វេភាគី ស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៣២០/០១៣ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។
- **ក្រសួងយុត្តិធម៌** បាន៖
  - ចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េខាងត្បូង ស្តីពី ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ។
  - បន្តពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងអំពើរត់ពន្ធមនុស្ស និងច្បាប់ស្តីពី អំពើពពោះជំនួស។
  - រៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសបារាំង ស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។
  - រៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសប៉េរូ ស្តីពី ការផ្ទេរទណ្ឌិត។
  - រៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ ស្តីពី ការផ្ទេរទណ្ឌិត។
  - រៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋឥណ្ឌា។

#### ក.២. បទដ្ឋានគតិយុត្ត

- **ក្រសួងមហាផ្ទៃ** បានចេញសេចក្តីជូនដំណឹងទៅអភិបាលខេត្តជាប់ព្រំដែន លេខ១៣៩៦ សជណ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ស្តីពី «ការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរកុំឱ្យឆ្លងដែនដោយខុសច្បាប់ចូលទៅប្រទេសជិតខាងតាមច្រករបៀងនានា» និងវិធានការជាបន្តបន្ទាប់ ដើម្បីពង្រឹងការគ្រប់គ្រងច្រកព្រំដែន និងដាក់បញ្ជាទៅថ្នាក់ក្រោមជាតិ ក្នុងការតាមដាន ស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ដែលព្យាយាមនាំពលករចេញទៅប្រទេសថៃ ក្នុងដំណាក់កាលរឹតបន្តឹង។
- **ក្រសួងយុត្តិធម៌** បាន៖
  - ចេញសេចក្តីសម្រេច លេខ០៨ កយ.សសរ/២០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការដឹកនាំយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿង នៅតាមសាលាដំបូងរាជធានី ខេត្ត។
  - ចេញសេចក្តីសម្រេច លេខ២០ កយ.សសរ/២០ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ ដែលក្នុងនោះមាន រដ្ឋលេខាធិការមួយរូប (ឯកឧត្តម កេង សុម៉ារិទ្ធ) ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគីស្ដីពី ការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៣២០/០១០ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។
- **ក្រសួងអប់រំ យុវជននិងកីឡា** បាន៖
  - អនុម័តគោលនយោបាយជាតិ ស្ដីពីសុខភាពសិក្សា និងក្រុមការងារអន្តរវិស័យសុខភាពសិក្សា ព្រមទាំងក្រុមលេខាធិការដ្ឋានសុខភាពសិក្សា។
  - អនុម័តគោលនយោបាយ ស្ដីពីកិច្ចការពារកុមារពីអំពើហិង្សាគ្រប់ទម្រង់ ទាំងក្នុង និងក្រៅសាលារៀន។
  - ចេញសេចក្ដីសម្រេច លេខ០១ អយក.សសរ ចុះថ្ងៃទី៣ មករា ២០២០ស្ដីពី ការបង្កើតក្រុមការងារចងក្រងសៀវភៅសិក្សា និងជំនួយវិធីសាស្ត្របង្រៀន ពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ។
  - ចេញសេចក្ដីណែនាំ ស្ដីពីការសម្របសម្រួលចេញលិខិតបញ្ជាក់ការសិក្សា និងការចូលរៀន សម្រាប់សិស្សទេសន្តរប្រវេសន៍ និងសិស្សដែលមាតាបិតាធ្វើមាតុភូមិនិវត្តន៍ពីចំណាកស្រុក។
  - ចេញសេចក្ដីសម្រេច លេខ ០៣២/២០សសរ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សអន្តរនាយកដ្ឋាន។
- **ក្រសួងកិច្ចការនារី** បានរៀបចំ៖
  - សេចក្ដីព្រាងវិសោធនកម្មអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ (COMMIT)។
  - សេចក្ដីព្រាងយន្តការបញ្ជូនឆ្លងដែនមានលក្ខណៈស្តង់ដារួមគ្នាតែមួយ និងរួមទាំងចាត់តាំងគ្រូបង្គោលរបស់ប្រទេសជាសមាជិកខមមីតនីមួយៗ។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បាន៖
  - ធ្វើសេចក្ដីព្រាងអនុក្រឹត្យ «ស្ដីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះ ស្នាក់នៅក្នុងមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍ ដែលរងគ្រោះដោយការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត» ។
  - ប្រកាសផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការ "នីតិវិធីប្រតិបត្តិបទដ្ឋាន ស្ដីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ(SOP)"។
  - កែសម្រួលគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្ដីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- **ក្រសួងសុខាភិបាល បាន៖**
  - សហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយមានការគាំទ្រពីអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) បានរៀបចំ និងពិនិត្យសម្រេច "គោលនយោបាយជាតិស្ដីពីសុខភាពជនទេសន្តរប្រវេសន៍" និងត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅខែមីនា ឆ្នាំ២០២១។ គោលនយោបាយនេះ បានផ្ដោតការយកចិត្តទុកដាក់លើកញ្ចប់សេវាសុខាភិបាល សម្រាប់ជនទេសន្តរប្រវេសន៍មានជាអាទិ៍ ការផ្ដល់សេវាសុខភាព ការពិនិត្យវាយតម្លៃសុខភាព ជំងឺឆ្លង ជំងឺមិនឆ្លង សុខភាពមាតានិងទារក សុខភាពបន្តពូជ សេវាសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន ការលើកកម្ពស់ និងអប់រំសុខភាពមុន និងពេលធ្វើទេសន្តរប្រវេសន៍ ទៅប្រទេសគោលដៅ និងក្រោយពេលត្រឡប់មកវិញ។

## គ.៣. ការងារកិច្ចសហប្រតិបត្តិការ

- **គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាន៖**

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ កម្រិតថ្នាក់ដឹកនាំ ដើម្បីសម្រេចជ្រើសរើសគោលបំណងអាទិភាព និងសូចនាករសម្រាប់អភិបាលកិច្ចទេសន្តរប្រវេសន៍(Migration Governance Indicators) ដើម្បីអនុវត្ត កតិកាសញ្ញាពិភពលោកស្តីពី «ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់»។
- ចុះអនុស្សរណៈយោគយល់គ្នារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ A21 Foundation ស្តីពីកិច្ចសហប្រតិបត្តិការលើការងារបង្ការ ទប់ស្កាត់ ការពារ និងកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០។
- ចុះកិច្ចព្រមព្រៀងរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការឃែរអន្តរជាតិប្រចាំនៅកម្ពុជា(Care International in Cambodia) ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០។
- ចុះអនុស្សរណៈយោគយល់គ្នារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា(Cambodia-ACTs) ស្តីពីកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០។
- ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ ០២លើក ស្តីពី "វឌ្ឍនភាព នៃការអនុវត្តអនុសាសន៍ប្រចាំឆ្នាំ របស់សហរដ្ឋអាមេរិក លើកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា" រវាងមន្ត្រីជាន់ខ្ពស់ក្រសួងពាក់ព័ន្ធជាមួយឯកឧត្តមអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព សហរដ្ឋអាមេរិក និងគណៈប្រតិភូអម ស្ថានទូត និងបានជួបពិភាក្សាជាមួយ មន្ត្រីជំនាញជាច្រើនលើក។
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ០២លើក រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** រហូតឈានដល់ការរៀបចំ និងអនុវត្តគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សម្រាប់ពលករវិលត្រឡប់ ក្នុងដំណាក់កាលនៃការរាតត្បាតដោយជំងឺកូវីដ-១៩ នៅក្នុងខេត្តបាត់ដំបង សៀមរាប បន្ទាយមានជ័យ ក្រោមមូលនិធិ Multi Partner Trust Fund (MPTF) របស់អង្គការសហប្រជាជាតិ។
- ពិភាក្សាពិគ្រោះយោបល់ជាមួយ រាជធានី ខេត្ត អង្គការដៃគូជាតិ និងអន្តរជាតិជាច្រើនលើក ដើម្បីរកគន្លឹះដោះស្រាយបញ្ហាប្រឈម បន្ថែមលើគោលនយោបាយជាតិសម្រាប់ប្រជាពលរដ្ឋនៅក្នុងប្រទេស ចំពោះការវិលត្រឡប់របស់ពលករដ៏ច្រើន តាមច្រករបៀងក្រៅផ្លូវការ និងបន្តចូលដោយគ្មានពេលវេលា និងចំនួនកំណត់ ហើយប្រឈមនឹងស្ថានភាពសុខភាព និងជីវភាពយ៉ាងធ្ងន់ធ្ងរ ។

- **ក្រសួងទេសចរណ៍** បានរៀបចំ និងត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយអង្គការចំនួន ០៦(១.អង្គការក្តីសង្ឃឹម និងយុត្តិធម៌ ២.អង្គការក្តីស្រឡាញ់គ្មានព្រំដែន ៣.អង្គការសកម្មភាពដើម្បីកុមារ ៤.អង្គការសម្ព័ន្ធចាប់ដៃ ៥.អង្គការសង្គ្រោះ និងថែទាំអន្តរជាតិស៊ីធីភញ ៦.អង្គការពន្លកថ្មី) ដើម្បីកិច្ចសហប្រតិបត្តិការក្នុងកិច្ចការពារជនរងគ្រោះ និងការផ្តល់សេវា នៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២០។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**
  - បានបន្តពិភាក្សាការងារ ជាមួយក្រសួងការងារថៃ តាមប្រព័ន្ធអនឡាញ ដើម្បីរកគន្លឹះដោះស្រាយភាពប្រឈមរបស់ពលករទេសន្តរប្រវេសន៍ ដែលកំពុងស្ថិតនៅក្នុងប្រទេសថៃ ក្នុងស្ថានភាពរឹតបន្តឹង និងប្រឈមនឹងការរាតត្បាតនៃជំងឺកូវីដ-១៩។

- ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារលើកទី៦ នៃប្រទេស CLMTV (កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម) ដើម្បីត្រៀមរៀបចំ សេចក្តីព្រាងសេចក្តីថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការងារស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ ពលករទេសន្តរប្រវេសន៍នៃប្រទេស CLMTV ដែលនឹងប្រព្រឹត្តទៅនៅឆ្នាំ ២០២១។

- **ក្រសួងកិច្ចការនារី បាន៖**
  - បន្តពិភាក្សាការអនុវត្តផែនការសកម្មភាពមហាអនុតំបន់មេគង្គ ស្តីពីការប្រយុទ្ធ ប្រឆាំងការជួញដូរមនុស្ស លើកទី៤ សម្រាប់ឆ្នាំ២០២០-២០២២(SPA-IV 2015-2018) ដែលត្រូវបានបន្តសុពលភាពអនុវត្ត លើកទី១ ឆ្នាំ២០១៨-២០២០) និងត្រៀមរៀបចំផែនការសកម្មភាពនេះ លើកទី៥ (SPA-V) ដែលត្រូវបញ្ចូលនិន្នាការថ្មីនៃអំពើជួញដូរមនុស្ស ព្រមទាំងមានការចូលរួមពីអង្គការសង្គមស៊ីវិល និងបណ្តាញយុវជន។
  - សហការជាមួយមន្ទីរកិច្ចការនារី និងគ.ក.ស.ក ដោយមានការគាំទ្រថវិកាពីអង្គការ UNICEF បានរៀបចំ និងប្រកាសផ្សព្វផ្សាយឱ្យប្រើប្រាស់នូវផែនការសកម្មភាព ស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់, ការប៉ាន់ប្រមាណថវិកាអំពី អាពាហ៍ ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ និងការសិក្សាស្រាវជ្រាវបឋមស្តីពី អាពាហ៍ពិពាហ៍វ័យកុមារ និងកុមារជាមាតា ក្នុងចំណោមក្មេងស្រីមានផ្ទៃពោះអាយុ ១២-១៧ឆ្នាំ នៅខេត្តរតនគិរី ។

- **ក្រសួងអប់រំ យុវជន និងកីឡា៖**
  - បានចុះអនុស្សរណៈយោគយល់ជាមួយអង្គការផ្លែនអន្តរជាតិកម្ពុជា (Plan International Cambodia) លើការងាររៀបចំតែងនិពន្ធ ការចងក្រង ការបោះពុម្ពសៀវភៅសិក្សា ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀនសម្រាប់កម្រិតបឋមសិក្សានិង កម្រិតមធ្យមសិក្សាបឋមភូមិ ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ និងគ្រូឧទ្ទេសសាលាគរុកោសល្យ ព្រមទាំងការបង្រៀនតាមប្រព័ន្ធឌីជីថល ឬសិក្សាពីចម្ងាយ។
  - បានទទួលកិច្ចសហប្រតិបត្តិការក្នុងការបោះពុម្ពលើកទី១ សៀវភៅសិក្សា ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន សម្រាប់កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ ពីអង្គការ A21 និង CWCC ។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ

| ល.រ | ផ្សព្វផ្សាយតាមរយៈ | ចំនួនលើក | ចំនួនអ្នកចូលរួម | ស្រី |
|---|---|---|---|---|
| ១ | វេទិកាសាធារណៈ ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព និងកិច្ចប្រជុំផ្សព្វផ្សាយដោយឡែក | ១២៥.៩៤៩លើក | ៦.១៤៧.៩៣០នាក់ | ៣.៣៥៩.៨១៧នាក់ |
| ២ | ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ | ១៥ លើក | ១.២០៥ នាក់ | ៣៥០ នាក់ |
| ៣ | កម្មវិធីផ្សេងៗ | ៩១ លើក | ២៦.៨៤៧ នាក់ | ៩.៩១៨ នាក់ |
| ៤ | ផ្សព្វផ្សាយតាមរយៈអង្គការដៃគូ | ១៦៧ លើក | ១៧.៤០៩ នាក់ | ៧.៣១៤ នាក់ |
| | សរុប | ១២៦.២២២ លើក | ៦.១៩៣.៣៩១ នាក់ | ៣.៣៧៦.៤០៧ នាក់ |

### ខ.១.២.ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

•**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានសហការជាមួយទូរទស្សន៍បាយ័ន ចងក្រងឯកសារ និងធ្វើបទយក ការណ៍ស្តីពី "ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សក្នុងបរិបទកូវីដ-១៩" ដើម្បីចាក់ផ្សាយតាម ប្រព័ន្ធផ្សព្វផ្សាយ វិទ្យុ ទូរទស្សន៍រដ្ឋ និងឯកជន តាមរយៈសមាគមវិទ្យុ ទូរទស្សន៍កម្ពុជា បណ្តាញផ្សព្វផ្សាយសង្គម និងបែងចែកទៅរាជធានី ខេត្ត។

•**ក្រសួងអប់រំ យុវជន និងកីឡា** បានធ្វើការផ្សព្វផ្សាយអំពីទិវាជាតិ១២ធ្នូ ឆ្នាំ២០២០ តាមរយៈការប្រជុំតាមក្រុមសិស្សស្វ័យសិក្សាតាមភូមិនៅរាជធានីភ្នំពេញ និងនៅស្រុកបរិបូណ៌ខេត្តកំពង់ឆ្នាំង ដែលបានជួបសិស្សសរុបចំនួន ២៨៦នាក់ ស្រី១៤០នាក់។

•**លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ស្ទើរគ្រប់ខេត្ត និងរាជធានី** បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២០ ដោយបានផលិតសម្ភារ កម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ សម្រាប់អបអរក្នុងយុទ្ធនាការ។ ក្នុងនោះខេត្តចំនួន ០៨ គឺខេត្តព្រៃវែង ស្វាយរៀង កែប កំពង់ធំ កោះកុង កំពង់ឆ្នាំង កំពង់ស្ពឺ បន្ទាយមានជ័យ បានរៀបចំជាកិច្ចប្រជុំតូចៗ ដែលមានការចូលរួមពីថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ ចូលរួមសរុបចំនួន ៩១៩នាក់(ស្រី២១០នាក់)។ ដោយឡែកខេត្តសៀមរាប កំពង់ចាម ត្បូងឃ្មុំ កណ្តាល និងខេត្តមួយចំនួនទៀតមិនបានរៀបចំជាមិទ្ទិញទេ តែបានផ្សព្វផ្សាយតាមរយៈការចែកខិត្តប័ណ្ណ ចងបដា ពាក្យស្លោកពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមសាលាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ តាមសាលារៀន និងនៅតាមទីសាធារណៈមួយចំនួនទៀត និងផ្សព្វផ្សាយបទយកការណ៍ដែលសហការផលិតដោយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងទូរទស្សន៍បាយ័ន ឬធ្វើបទសម្ភាសន៍ នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់ខេត្ត សរុបចំនួន ២២៥បដា។

### ខ.១.៣. ការអប់រំផ្សព្វផ្សាយដោយផ្ទាល់

នៅក្នុងឆ្នាំ២០២០នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **១២៥.៩៤៩លើក** មានអ្នកចូលរួមសរុបចំនួន **៦.១៤៧.៩៣០នាក់** (បើប្រៀបធៀបនឹងឆ្នាំ២០១៩ មានចំនួន **៥.៤៩២.០៤៤នាក់** គឺមានការកើនឡើងចំនួន **៦៥៥.៨៨៦នាក់** ស្មើនឹង**១០,៦៦%** ក្នុងនោះស្ត្រីចំនួន **៣.៣៥៨.៤២៥នាក់** ដូចមានតារាងលម្អិតខាងក្រោម៖

| ក្រសួង ស្ថាប័ន រាជធានី ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|
| | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | |
| ១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១១ | ១៦១ | ៧៤ | | | |
| ២ ក្រសួងសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា | ៣ | ២.៥៨៦ | | | | |
| ៣ ក្រសួងកិច្ចការនារី | | | | ១៤ | ៦៥១ | ៤៤៩ |
| ៤ ក្រសួងប្រៃសណីយ៍ | ២៥ | ៩៥០ | ៥២៨ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | កាកបាទក្រហមកម្ពុជា | ២៥ | ៣៥.៥១៥ | | | | |
| ៦ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៣.២២២ | ១៤៨.៦៥៤ | ៨៤.៤៩២ | ៩៨២ | ៣៧.៥៨៧ | ១៨.២០៧ |
| | **សរុប ក្រសួង ស្ថាប័ន** | **៣.២៨៦** | **១៨៧.៨៦៦** | **៨៥.០៩៤** | **៩៩៦** | **៣៨.២៣៨** | **១៨.៦៥៦** |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | ១.៨៨៤ | ៧៧.០៥២ | ៤៦.៥៥៣ | ៣.១៩៥ | ១៥១.២២១ | ៧៦.៦៧៣ |
| ២ | ខេត្តកណ្ដាល | ៧.៣៨៦ | ៣៤៤.៤៦៤ | ១៨៤.២២៦ | ៨.៦៩៩ | ៤៧០.០០៥ | ២៣៥.៧៨៦ |
| ៣ | ខេត្តបាត់ដំបង | ៩.៥៩២ | ៣៨៤.០៣៨ | ២០១.០០០ | ៦.៤៨២ | ១៧៣.៧២៦ | ៩២.១៩៦ |
| ៤ | ខេត្តពោធិ៍សាត់ | ៥.២១៦ | ៤៤៣.៦១៧ | ២៤៥.០៣០ | ១.៦៣០ | ៦៩.០៨៥ | ៣៣.៨០០ |
| ៥ | ខេត្តសៀមរាប | ៣.៦០០ | ១៩៩.៧៥៤ | ១១៧.៤២៩ | ១.៧៤៤ | ៤៦.៩៩៤ | ២៦.៤៩១ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១១.០១២ | ៤២៦.៣៤៨ | ២២៦.៦៤៨ | ៧.០៤៦ | ២៣៦.១៦៧ | ១២៨.៨៨៥ |
| ៧ | ខេត្តកំពង់ចាម | ១៧.៨៣១ | ៧៨១.១១៥ | ៦១៥.៣៩៤ | ៨.៨៣៣ | ៧៤៣.៤៨១ | ៣០២.៣៣០ |
| ៨ | ខេត្តព្រះសីហនុ | ៥៥៥ | ៦២.០៨៧ | ៣៩.៩៩៧ | ៥៩៩ | ២៧.២៣៣ | ១៦.៣២១ |
| ៩ | ខេត្តព្រះវិហារ | ៩១៨ | ១០៩.១៨៤ | ៦៤.០១៦ | ១.៤៦០ | ៤៣.៧៣៤ | ២១.៩០៣ |
| ១០ | ខេត្តស្វាយរៀង | ៥៣១ | ១៩.១៤១ | ១០.២៥៩ | ៣.៨៣៨ | ១៤០.០១៤ | ៧៤.៧១៥ |
| ១១ | ខេត្តប៉ៃលិន | ៩៩៩ | ២៤.៤៥២ | ១១.១៧៥ | ៣៤៧ | ១៤.០៩៦ | ៧.១៤៦ |
| ១២ | ខេត្តកោះកុង | ១១ | ៣៨១ | ១០៦ | ១.៦២០ | ៣៨.៥១៥ | ២១.០៦០ |
| ១៣ | ខេត្តកំពត | ១៥ | ៩៩៨ | ៣៩៩ | ១០ | ៧៥៣ | ៥៣៣ |
| ១៤ | ខេត្តកំពង់ធំ | ៦៨៣ | ២៩.៤២៣ | ១៤.៨៩៥ | ២០០ | ៧.១៩២ | ២.៤៥៨ |
| ១៥ | ខេត្តតាកែវ | ៣.៧៣៣ | ១៨៧.១៨២ | ៩៤.៧០៦ | ១.២១៩ | ៤៧.៣២២ | ២៣.៩៤២ |
| ១៦ | ខេត្តក្រចេះ | ៥០៣ | ២៦.០៥៥ | ១៤.០២២ | ៧២ | ៤.៧៤០ | ១.៧៨៦ |
| ១៧ | ខេត្តកែប | ១៨៩ | ២៩.៤២២ | ១២.៣៤២ | ៣៩០ | ១៧.៧៩៦ | ៧.៧៦០ |
| ១៨ | ខេត្តកំពង់ស្ពឺ | ១.៦៣២ | ៨១.០៧០ | ៤០.៩៣៥ | ៤៨៩ | ១៣.៣១៣ | ៦.៥៨៤ |
| ១៩ | ខេត្តស្ទឹងត្រែង | ១៦៦ | ៣.៦២២ | ១.៥០៣ | ៦៩ | ១.០៤៧ | ៤៩៣ |
| ២០ | ខេត្តរតនគិរី | ៩៥០ | ៤១.២៣៥ | ២២.២៣៣ | ១៧៩ | ១០.២០១ | ៤.៤៣៩ |
| ២១ | ខេត្តព្រៃវែង | ៥ | ២៥.៣៨៩ | ៨.០៣៦ | ១៣ | ២.២៤៨២ | ៣៥០ |
| ២២ | ខេត្តត្បូងឃ្មុំ | ៣៦ | ៦៩.៩៨៧ | ៤៤.២៥៩ | ៧ | ២៤.៦៧២ | ១៧.៨០៨ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៦ | ៨០០ | ១៨៩ | ៩៨១ | ២១.៥៦៨ | ១២.២១៧ |
| ២៤ | ខេត្តឧត្ដរមានជ័យ | ៥ | ៦២៦ | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ១.៨៩១ | ៧៧.៥៧៦ | ៤៦.៩៣៩ | ៣.១៩៦ | ១៥១.៤៥១ | ៧៦.៧០៨ |
| | **សរុប រាជធានី ខេត្ត** | **៦៩.៣៤៩** | **៣.៤៤៥.០១៨** | **២.០៦៦.៤៨៦** | **៥២.៣១៨** | **២.៤៨៣.៨០៨** | **១.១៩២.៣៨៤** |
| | **សរុបរួម** | **១២៥.៩៤៩ លើក** | | **៦.១៤៧.៩៣០ នាក់** | | **៣.៣៥៨.៤២៥ នាក់** | |

### ១.១.៤. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ក្រសួងធម្មការ និងសាសនា** សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ៖ បានបញ្ជ្រាបខ្លឹមសារការងារបង្ការ ទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ទៅក្នុងមហោស្រពសិល្បៈយុវជនទូទាំងប្រទេសលើកទី៦ ឆ្នាំ២០២០ ទាំង២៥ រាជធានី-ខេត្ត ដើម្បីលើកកម្ពស់ការយល់ដឹង

ពាក់ព័ន្ធការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលមានការចូលរួមពីសិស្ស និស្សិត សិល្បៈករ និង ប្រជាពលរដ្ឋ សរុបចំនួន **៦.៧៦៥**នាក់ ស្រី **២.៩១៧**នាក់។

- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** បានបញ្ជ្រាបខ្លឹមសារការងារបង្ការ ទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ទៅក្នុងសកម្មភាពថ្នាក់ដឹកនាំ និងសកម្មភាពចុះមូលដ្ឋាន ការរៀបចំមហោស្រពសិល្បៈ ទិវាវប្បធម៌ជាតិ៣មីនា និងពេលបង្ហាត់បង្រៀន ដល់សិស្ស និស្សិត សិល្បៈករ និងប្រជាពលរដ្ឋ ទាំង ២៥ រាជធានី-ខេត្ត សរុបចំនួន **១៤.០៧២**នាក់ ស្រី**៥.៩៧២**នាក់។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ក្រុមការងារមណ្ឌលសំចត សហការជាមួយអង្គការ Cambodia-ACTs និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) ចុះផ្សព្វផ្សាយដល់សហគមន៍ អំពីផលប៉ះពាល់ និងការបង្ការទប់ស្កាត់ជំងឺកូវីដ១៩ ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និង វិធីការពារទប់ស្កាត់ការជួញដូរមនុស្ស នៅឃុំមួយចំនួន នៃក្រុងប៉ោយប៉ែត ស្រុកម៉ាឡៃ និងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ចំនួន៤១៧គ្រួសារ (សរុបមនុស្សចំនួន **២.៥៨៦**នាក់) និងបានចែកម៉ាស អាល់កុល និងសាប៊ូលាងដៃផងដែរ។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** បានសហការជាមួយ**ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ APLE** បើកកម្មវិធីយុទ្ធនាការ ស្តីពីការលើកកម្ពស់សុវត្ថិភាពអ៊ីនធឺណិត សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅវិទ្យាស្ថានអប់រំ អ្នកចូលរួមមាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងតំណាងអង្គការជាតិ អន្តរជាតិ សរុបប្រមាណ **៥០០**នាក់។
- **ខេត្តព្រៃវែង៖** សហការជាមួយអង្គការ IOM ធ្វើយុទ្ធនាការហែក្បួនតាមភូមិ នៅស្រុកពារាំង និងស្រុកស្វាយអន្ទរ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអោយយល់ដឹងពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការបង្ការ ទប់ស្កាត់ ការរីករាលដាលនៃជំងឺកូវីដ-១៩។
- **ខេត្តព្រះសីហនុ៖** បានផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស ការរំលោភបំពាន ការធ្វើចំណាកស្រុកខុសច្បាប់ តាមរយៈវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ចំនួន ១៣វគ្គ តាមរយៈសិក្ខាសាលាមកាត់ដេរ ០៣វគ្គ និងតាមរយៈមិទ្ទិញអបអរទិវាអន្តរជាតិនារី ៨មីនា ០២លើក ដែលមានអ្នកចូលរួមសរុបចំនួន **៨៧៧**នាក់ ស្រី **៦២៧**នាក់។
- **ខេត្តកណ្តាល៖** ១-បានផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងវគ្គផ្សព្វផ្សាយ ប្រកាសសាចរាចរណែនាំក្រុមប្រតិបត្តិ ស្តីពីការអនុវត្តវិធានសុវត្ថិភាព ទេសចរណ៍សម្រាប់ភោជនីយដ្ឋាន អាហារដ្ឋាន រមណីយដ្ឋាន សេវាកម្ម ស្នាក់នៅទេសចរណ៍ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ របស់មន្ទីរទេសចរណ៍ខេត្ត ចំនួន ០២លើក មានអាជីវករ សេវាករ សរុបចំនួន **១០០**នាក់ ស្រី **៥៦**នាក់ ។

  ២-បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈការប្រជុំបូកសរុបការងារប្រចាំឆ្នាំ និងកិច្ចប្រជុំផ្សេងៗ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចំនួន ១៨លើក ដែលមានអ្នកចូលរួមសរុប ១.៩៤៧នាក់ ស្រី ៣៤៦នាក់។
- **អង្គការដៃគូ**

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំនានា របស់អង្គការដៃគូ*

| អង្គការ | សកម្មភាព | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| GVC,អង្គការសាម៉ារីតាន់ភឹស អង្គការវីវើល/ជីវីស៊ី និងអង្គការ IOM (ខេត្តបាត់ដំបង) | - បានសហការជាមួយក្រុមប្រឹក្សាឃុំ និងភូមិគោលដៅ ផ្តល់ការអប់រំផ្សព្វផ្សាយ អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព សិទ្ធិការងាររបស់ពលករចំណាកស្រុកក្នុងប្រទេសថៃ ការទប់ស្កាត់នៃការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដល់ពលករចំណាកស្រុក នៅឃុំចំនួន០៦ ក្នុងស្រុកសំឡូត។ | ១០ | ៤៥៤ | ៣២២ |
| អង្គការវីវើល/ជីវីស៊ី អង្គការមូលនិធិ A21 និងអង្គការបន្ទាយស្រី អង្គការជែនជីមនុស្ស ហ្វូឡង់ជំ អង្គការAPLE (ខេត្តសៀមរាប) | - អង្គការវីវើល/ជីវីស៊ី បានសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព សិទ្ធិការងាររបស់ពលករចំណាកស្រុកក្នុងប្រទេសថៃ និងការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់អាជ្ញាធរមូលដ្ឋាននៅតាមភូមិគោលដៅ នៅស្រុកពួក ស្រុកជីក្រែង ខេត្តសៀមរាប និងនៅស្រុកសំឡូត ខេត្តបាត់ដំបង។ | ៣២ | ១.៥៥៩ | ១.២៦២ |
| | - អង្គការមូលនិធិ A21 បានធ្វើការផ្សព្វផ្សាយស្តីពីច្បាប់ពាក់ព័ន្ធនឹងការប្រឆាំងការជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនិងសិទ្ធិកុមារ ដល់ប្រជាពលរដ្ឋ សិស្ស និស្សិត។ | ៧៣ | ៨.៩៥៤ | ៣.៣០៩ |
| | - អង្គការបន្ទាយស្រី៖ បានសហការជាមួយអាជ្ញាធរស្រុកអង្គជុំ ប្រជុំផ្សព្វផ្សាយ និងចងក្រងបណ្តាញសុវត្ថិភាពសហគមន៍ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពទៅក្រៅប្រទេស។ | ០៤ | ៨១ | ៥៨ |
| | - អង្គការជែនជីមនុស្ស-ហ្វូឡង់ជំ បានធ្វើការផ្សព្វផ្សាយអំពី ការទប់ស្កាត់ការកេងប្រវ័ញ្ចពលកម្មកុមារនៅសហគមន៍ ដល់ក្រុមយុវជន គ្រួសារកុមារ និងប្រជាពលរដ្ឋ។ | ០៥ | ៥៤ | ២២ |
| | - អង្គការ APLE បានផ្សព្វផ្សាយលើប្រធានបទពាក់ព័ន្ធនឹងសុវត្ថិភាពអ៊ីនធឺណិត និងកិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ដល់អាជ្ញាធរ មូលដ្ឋាន មន្ត្រីអង្គការសង្គមស៊ីវិលធ្វើការជាមួយកុមារ លោកគ្រូ អ្នកគ្រូ សាធារណជន កុមារ យុវជន ឪពុកម្តាយ និងអាណាព្យាបាល។ | ០៩ | ១.៤០៦ | ៧៧៩ |
| អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (ខេត្តកោះកុង) | - បានផ្សព្វផ្សាយ ស្តីពី ប្រការគួរយល់ដឹងមុនសំរេចចិត្តធ្វើចំណាកស្រុកទៅក្រៅប្រទេស ក្នុងសហគមន៍ចំនួន០៤។ | ៤ | ៨២ | ៦៤ |
| | - បានចូលរួមចំណែកក្នុងការអនុវត្តបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈការពង្រឹងសមត្ថភាពសហគមន៍ ការផ្តល់ប្រឹក្សាពិគ្រោះយោបល់ លើការចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពរួមមាន៖ ការប្រជុំក្រុមជួយខ្លួនឯងប្រចាំខែលើប្រធានបទយល់ដឹងពីលិខិតឆ្លងដែនកម្ពុជា។ | ៥ | ១១៧ | ៩០ |
| សាម៉ារីតាន់ភឹស (ខេត្តបន្ទាយមានជ័យ) | - បានអប់រំផ្សព្វផ្សាយស និងចែកខិត្តប័ណ្ណស្តីពី ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព។ | ៣ | ២.៨៥៧ | ៩២៨ |
| អង្គការគាលើកាដូ និងអង្គការអាជីហុក (ខេត្តតាកែវ) | - បានធ្វើការផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋនៅស្រុកទឹកឈូក។ | ១ | ៣៧ | ២៣ |

| | | | | |
|---|---|---|---|---|
| អង្គការឆាលហ្សាន់ និង CCPCR (ខេត្តស្វាយរៀង) | បានផ្សព្វផ្សាយអំពីបញ្ហាប្រឈមងាយរងគ្រោះដោយការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ការរំលោភបំពាន ការកេងប្រវ័ញ្ច និងកិច្ចការពារកុមារ នៅឃុំក្រសាំង និងឃុំអណ្តូងត្របែក ស្រុករមាសហែក ចំនួន ១២លើ មានអ្នកចូលរួមចំនួន ៥៦០នាក់ (ស្រី ២៨០នាក់)។ | ១៧ | ៨០៦ | ៤០៤ |
| អង្គការសម្ពន្ធចាប់ដៃ | - បានសហការជាមួយអាជ្ញាធរនៅភូមិ ឃុំ ក្នុងខេត្តក្រចេះ និងខេត្តមណ្ឌលគិរី រៀបចំបញ្ចាំងភាពយន្តដើម្បីផ្សព្វផ្សាយ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវិធីការពារកុមារ ដល់គ្រួសារគោលដៅចំនួន ១៧២នាក់ គ្រួសារក្រៅគោលដៅចំនួន ២៦នាក់។ | ០៣ | ៤៦១ | ១៥៧ |
| អង្គការ APLE | - បានការសហការពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ និងក្រសួងអប់រំ ធ្វើយុទ្ធនាការផ្សព្វផ្សាយដើម្បីលើកកម្ពស់សុវត្ថិភាពអ៊ីនធឺណិត សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ ក្រោមប្រធានបទ "រួមគ្នាដើម្បីធ្វើឱ្យល្អប្រសើរឡើងនូវសុវត្ថិភាពអ៊ីនធឺណិត និងកិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត" ដោយមានការចូលរួមពីសំណាក់ កុមារ យុវជន អង្គការដៃគូ មន្ត្រីរាជរដ្ឋាភិបាល និងលោកគ្រូអ្នកគ្រូ ។ | ០១ | ៥៤១ | ២៥៦ |
| សរុប | | ១៦៧ លើក | ១៧.៤០៩ នាក់ | ៧.៧១៤នាក់ |

### ១.១.៤. ការផ្សព្វផ្សាយ តាមរយៈឧបករណ៍ផ្សព្វផ្សាយ (IEC)

- **ថ្នាក់ជាតិ៖**

  - **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយ៖**
    - អង្គការសាម៉ារីតាន់ភីស អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការភឿន(ថៃ) អង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) អង្គការក្តីស្រឡាញ់គ្មានព្រំដែន និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការប្រឹក្សាយោបល់អំពីរបៀបក្លាយខ្លួនជាពលករស្របច្បាប់ និងការធ្វើតេស្តរកមេរោគ កូវីដ១៩ ជូនដល់ពលករ ចំណាកស្រុកដែលត្រឡប់មកពីប្រទេសថៃ និងម៉ាឡេស៊ី។
    - សហការជាមួយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT) ធ្វើការបោះពុម្ពសៀវភៅ នីតិវិធីប្រតិបត្តិបទដ្ឋានស្តីពី ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៏ ចំនួន១,០០០ក្បាល។
  - **ក្រសួងកិច្ចការនារី ៖** បានធ្វើការបោះពុម្ព ចែកជូនដល់ គ.ក.ស.ក ខេត្តនិងស្រុក/ក្រុងទាំង ៩ និងបានធ្វើការចុះផ្សព្វផ្សាយ ស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ ដល់មន្ត្រីអាជ្ញាធរថ្នាក់ស្រុក និងឃុំចំនួន ៣៩៤នាក់ ស្រី ៣១៥នាក់ ដែល(៨០% ជាជនជាតិដើមភាគតិច)។ សមាសភាពទាំងនោះរួមមាន សមាជិក គ.ក.ស.ក ស្រុក លោកមេឃុំ អ្នកទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ (គ.ក.ន.ក) នគរបាលប៉ុស្តិ៍ តាមឃុំនីមួយៗក្នុងស្រុក/ក្រុងទាំង ៩ ។

- **ក្រសួងធម្មការ និងសាសនា** បានសហការជាមួយនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ បានបញ្ចូលសារអប់រំពាក់ព័ន្ធការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សតាមរយៈ(CD, VCD, DVD)ចំនួន ៣៧៦.៣២៤ឌីស។
- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** បានបញ្ចូលសារអប់រំពាក់ព័ន្ធការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុង ស៊ីឌី វីស៊ីឌី ឌីវីឌី ចំនួន៣៩០.៣៦៨ឌីស និងបានផ្សព្វផ្សាយណែនាំដល់ម្ចាស់ផលិតកម្ម អោយដំឡើងសារ អប់រំស្តីពីផលប៉ះពាល់នៃអំពើជួញដូរផ្លូវភេទ ការធ្វើទេសន្តរប្រវេសន៍ខុសច្បាប់ អំពើពពោះជំនួស ការជួញដូរសរីរាង្គ ក្នុងខ្សែភាពយន្ត និងចំរៀងកាយវិការខារ៉ាអូខេ ចំនួន **៧២**ក្រុមហ៊ុន។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** បានសហការជាមួយ **ក្រុមការងារយកព័ត៌មានស្ថានីយ៍ទូរទស្សន៍ បាយ័ន** ចុះស្រាវជ្រាវ និងចងក្រងព័ត៌មាន ដើម្បីផលិតបទយកការណ៍ សម្រាប់ធ្វើការផ្សព្វផ្សាយក្នុងឱកាស ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ ២០២០ នៅតំបន់ជាប់ព្រំដែន កម្ពុជា-ថៃ មានស្រុកកំរៀង និងស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ។
- **អង្គការសម្ព័ន្ធចាប់ដៃ** បាន៖
  - សហការជាមួយអាជ្ញាធរនៅឃុំជ្រះ និងឃុំឃ្សឹម ខេត្តក្រចេះ រៀបចំបញ្ចាំងភាពយន្តដើម្បីផ្សព្វផ្សាយពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវិធីការពារកុមារ ដល់គ្រួសារគោលដៅចំនួន **១៧២**នាក់ គ្រួសារក្រៅ គោលដៅចំនួន **២៦**នាក់។
  - បោះពុម្ពផ្ទាំងរូបភាពផ្សព្វផ្សាយស្តីពី ការការពារកុមារ ចែកជូនដល់ក្រុមប្រឹក្សាកម្ពុជាដើម្បីកុមារខេត្តក្រចេះបានចំនួន**១.១៤១**ផ្ទាំង និងផ្ទាំងផ្សព្វផ្សាយស្តីពី ផលប៉ះពាល់ដោយអំពើជួញដូរមនុស្ស សម្រាប់ចែកជូនដល់សិក្ខាកាមផ្សព្វផ្សាយបន្តដល់សហគមន៍ បានចំនួន **១៨០**ផ្ទាំង។
  - ផ្សព្វផ្សាយតាមរយៈមេក្រូ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយអ្នកស្ម័គ្រចិត្តចំនួន ១៨នាក់ ដល់ប្រជាពលរដ្ឋនៅស្រុក ស្នួល ខេត្តក្រចេះ។
- **អង្គការសាម៉ារីតាន់ភឺស បានសហការជាមួយបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ** បានចែកខិត្តប័ណ្ណផ្សព្វផ្សាយអប់រំស្តីពី ការធ្វើចំណាកស្រុក ដល់ជនចំណាកស្រុកចំនួន **៥៨.១៣៣**នាក់ (ស្រី **២៣.៣១៦**នាក់)។

**• ថ្នាក់ក្រោមជាតិ៖**

- **ខេត្តបន្ទាយមានជ័យ** បាន៖
  - សហការជាមួយអង្គការ IOM បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ របស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដល់ជនចំណាកស្រុកចំនួន **១.៩០៦**នាក់ (ស្រី **៩៦១**នាក់)។
  - ចែកលេខទូរសព្ទ័របស់មជ្ឈមណ្ឌលផ្តល់ព័ត៌មានចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករវិលត្រលប់មកពីប្រទេសថៃ និងប្រទេសម៉ាឡេស៊ីមានចំនួន៩៤២៦នាក់(ស្រី៤០១១នាក់)។
- **ខេត្តសៀមរាប៖** សាខាកាកបាទក្រហមកម្ពុជាខេត្ត បានបញ្ជ្រាបការផ្សព្វផ្សាយ អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សតាមរយៈរូបភាព បានចំនួន **១៤៩**លើក/**១២**ក្រុង ស្រុក បានចំនួន **៤២.៤៩៣**នាក់ ស្រី**២២.៣៦២**នាក់ និងបានចែកជូនសៀវភៅ និងខិត្តប័ណ្ណ ចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការលាងសំអាតដៃ ដើម្បីការពារពីការឆ្លងមេរោគកូវីដ១៩ ចំនួន **៣.៨៥០**សន្លឹក។
- **ខេត្តកំពង់ធំ៖** ស្នងការដ្ឋាននគរបាលខេត្ត បានបិទប្រកាសសេចក្តីណែនាំ ដើម្បីផ្សព្វផ្សាយអំពីច្បាប់ និងការបង្ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារបានចំនួន **៣០២**សន្លឹក តាមបណ្តា

គោលដៅអាជីវកម្ម ដូចជា ខារ៉ាអូខេ ក្លឹបកម្សាន្ត សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល កន្លែងកោសជប់ និង ភោជនីយដ្ឋាន បានចំនួន ៩១កន្លែង។

### ១.១.៦. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក

- **ថ្នាក់ជាតិ៖**
  - **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអនុញ្ញាតឱ្យទូរទស្សន៍ BTV ធ្វើបទសម្ភាសន៍ និងចាក់ផ្សាយក្រោមប្រធានបទ "ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងដំណាក់កាលប្រឈមនឹងវិបត្តិកូវីដ-១៩"។
  - **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
    - បានប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្ម ចំនួន **១៨៤.៨០៨**នាក់ និងផ្សព្វផ្សាយតាមរយៈគេហទំព័រ NEA មជ្ឈមណ្ឌលការងារ NEA Facebook និងកម្មវិធីទីផ្សារការងារ និងមុខរបរនៅតាមស្ថានីយ៍ទូរទស្សន៍នានា។
    - បានពង្រីកការផ្តល់ព័ត៌មានទីផ្សារការងារតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដោយមានអ្នកចូលប្រើប្រាស់គេហទំព័រចំនួន **២.១៤២.៣៤៤**ដង Facebook ចំនួន **៨.៩៥២**នាក់ Youtube ចំនួន **៧០.៧៦៥**នាក់ និងអ្នកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើទូរស័ព្ទវៃឆ្លាត(Mobile App) ចំនួន **៧៤១**នាក់។
  - **ក្រសួងព័ត៌មាន** បាន៖
    - រៀបចំធ្វើបទយកការណ៍ ស្តីពីបញ្ហាប្រឈមនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយខុសច្បាប់ ចាក់ផ្សាយនៅវិទ្យុជាតិ FM105.70MHz និងស្តីពីជីវិតស្ត្រីខ្មែររៀបការជាមួយជនបរទេស ចាក់ផ្សាយនៅវិទ្យុស្ត្រី FM103.5MHz។
    - ចាក់ផ្សាយបទយកការណ៍ តាមរយៈទូរទស្សន៍ជាតិកម្ពុជា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងដំណាក់កាលវិបត្តិកូវីដ ១៩ ។
    - ចាក់ផ្សាយតាមរយៈទូរទស្សន៍អប្សរា ពីការចុះបង្ក្រាបរបស់កងកម្លាំងនគរបាល នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយអាជ្ញាធរខេត្តកំពង់ឆ្នាំង ដើម្បីឃាត់ខ្លួនបុរសម្នាក់ ពីបទចោទប្រកាន់ពីបទចោទមានស្ថានទម្ងន់ទោសនាំចេញមនុស្សឆ្លងដែនខុសច្បាប់។
  - **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** បានសហការជាមួយ **ក្រសួងព័ត៌មាន និងនិយ័តករកម្ពុជា** (TRC) ធ្វើការរត់សារជាអក្សរ និងចាក់ផ្សាយបទយកការណ៍លើអេក្រង់ទូរទស្សន៍ និងផ្ញើសារអប់រំតាមរយៈទូរស័ព្ទចល័ត ក្រោមប្រធានបទ "ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងបរិបទកូវីដ-១៩" ដើម្បីអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២០ ដែលមានខ្លឹមសារ៖(១).អបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស១២ ខែធ្នូ ឆ្នាំ២០២០។ (២). សូមកុំចាញ់ឧបាយកលជនជួញដូរមនុស្ស ដែលអូសទាញឱ្យឆ្លងដែនខុសច្បាប់ ក្នុងពេលកូវីដ-១៩ កំពុងតែរាតត្បាតគ្រប់ទីកន្លែង ។
- **ថ្នាក់ក្រោមជាតិ៖**
  - **ខេត្តសៀមរាប៖**
    - លេខាធិការដ្ឋាន គ.ខ.ប.ជ និង មន្ទីរព័ត៌មានខេត្ត៖ បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM 103 MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប អំពីអំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល និងការផ្សព្វផ្សាយអំពីស្ពតអប់រំ ស្តីពីគ្រឿងញៀន ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងពាក់ព័ន្ធការ

ជួញដូរមនុស្ស សរុបចំនួន ៤៣៤លើក (ផ្សាយផ្ទាល់ ១២៤លើក ចាក់ផ្សាយឡើងវិញ ៣១០លើក និងផ្សព្វផ្សាយស្ពត ៨១.២០៧លើក។

- **ខេត្តក្រចេះ៖**
  - មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុ FM 98.5MHz ស្តីពីច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចំនួន ០៥លើក។
  - មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយនាទីព្រះពុទ្ធសាសនាតាមវិទ្យុ ជាធម្មទានអប់រំផ្លូវចិត្ត ដើម្បីទប់ស្កាត់នូវការជួញដូរមនុស្ស និងកេងប្រវ័ញ្ចកម្លាំងកុមារ ក៏ដូចជាយុវជន បានចំនួន ០៣លើក។
- **ខេត្តតាកែវ៖** ផ្សព្វផ្សាយព័ត៌មាន ស្តីពីច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោកធ្លក បានចំនួន ៦០អត្ថបទ និង ១៩៤លើក។
- **ខេត្តកំពង់ចាម៖** មន្ទីរព័ត៌មានផ្សព្វផ្សាយតាមរយៈវិទ្យុជាតិភ្នំប្រុស ពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន ០៨លើក និងតាមបណ្តាញទំនាក់ទំនងសង្គម(Facebook) ស្តីពីការផ្តល់សេវាគាំទ្រ និងបញ្ហាប្រឈមរបស់ពលករចំណូលស្រុកក្នុងកំឡុងពេលកូវីដ១៩ ចំនួន ០២លើក។
- **ខេត្តមណ្ឌលគិរី៖** មន្ទីរធម្មការ និងសាសនាខេត្ត បានផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ FM 97MHz ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងកម្មវិធី "**ព្រះពុទ្ធសាសនា ផ្សារភ្ជាប់សង្គម**" ចំនួន ៦០លើក។

### ១.១.៧. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការលើកកម្ពស់តម្លៃសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ គ.ជ.ស.ស.ខ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុជាតិ វិទ្យុស្ត្រី វិទ្យុវីអូឌី វិទ្យុវីអូអេ វិទ្យុអាស៊ីសេរី វិទ្យុអ៊ែអេហ្វអ៊ី វិទ្យុស៊ីស៊ីអាយអឹម ទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍បាយ័ន និងសារព័ត៌មានជាតិ និងអន្តរជាតិមួយចំនួន ដើម្បីរួមចំណែកផ្សព្វផ្សាយអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការដៃគូជាតិ អន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សក្នុងបរិបទកូវីដ-១៩ និងធ្វើឱ្យប្រសើរឡើងនូវសីលធម៌សង្គម កាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារ ពីការជួញដូរមនុស្ស និងការធ្វើទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុស្ត្រី ក្រោមប្រធានបទ ការកេងប្រវ័ញ្ចលើកុមារ និងសេវាថែទាំជនរងគ្រោះ ចំនួន០១លើក។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ FM ១០៣.៥ ដឹង គិត យល់ ជោគជ័យ ស្តីពីការងារក្នុងស្រុក ក្រៅស្រុក ដើម្បីលើកកម្ពស់ការយល់ដឹងអំពីព័ត៌មាន ឱកាសការងារនៅក្នុងស្រុក ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញក្នុងគោលបំណងលើកទឹកចិត្តឱ្យបងប្អូនពលករដែលបានទៅធ្វើការនៅក្រៅប្រទេស ដើម្បីមានជំនាញច្បាស់លាស់ យកមកអនុវត្តខ្លួនឯង គ្រួសារ សហគមន៍ និងសេដ្ឋកិច្ចសង្គម។
- **ក្រសួងកិច្ចការនារី៖** ថ្នាក់ដឹកនាំ និងមន្ត្រីផ្នែកច្បាប់ចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ទូរទស្សន៍ ចំនួន ២៤លើក ក្រោមប្រធានបទទាក់ទងនឹងការទប់ស្កាត់អំពើហិង្សា ការរំលោភបំពានលើស្ត្រីនិងក្មេងស្រីដែលមានពិការភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស ស្ត្រីចំណាកស្រុក ការទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការងារ និងយុទ្ធនាការ ១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី។

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមជាវាគ្មិន នៅវិទ្យុ FM102.00MHz និងវិទ្យុ FM103.5MHz ក្រោមប្រធានបទស្តីពី "ការកំណត់អត្តសញ្ញាណបឋម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប" ចំនួន០២លើក។
  - ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ិន វី** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមជាគ្រូបង្គោល ធ្វើបទឧទ្ទេសនាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេស លើស្ត្រី និងកុមារ នៅសាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិ(PKO) មានសិក្ខាកាមចូលរួមសរុបចំនួន **១៤៦**នាក់ (**ស្រី ២១**នាក់) ស្ថិតនៅភូមិទួល ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។
  - ឯកឧត្តម **យឹម វិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ **និង លោកឧ.ទោ កែវ សុវណ្ណារ៉ា ប្រធានក្រុមការងារកិច្ចការបង្ការ ទប់ស្កាត់** បានចូលរួមប្រជុំជាមួយប្រធានក្រុមការងារកិច្ចការបង្ការ ទប់ស្កាត់ ក្នុងកម្មវិធីជួបជុំវាគ្មិនផ្នែកបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដើម្បីជានាការលើកកម្ពស់សិទ្ធិកុមារ និងការអភិវឌ្ឍ សម្រាប់ថតចាក់ផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា(ទ.ទ.ក) នៅសាលប្រជុំទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។
  - លោកឧត្តមសេនីយ៍ទោ **កែវ ផល្លា** ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួមជាវាគ្មិន នៅវិទ្យុFM102MHz ក្នុងកម្មវិធីសំឡេងស្ត្រីដើម្បីការផ្លាស់ប្តូរ ក្រោមប្រធានបទ ស្ត្រី និងចំណាកស្រុកដោយសុវត្ថិភាព ចំនួន០១លើក។
  - **លោកឧ.ទោ កែវ សុវណ្ណារ៉ា ប្រធានក្រុមការងារកិច្ចការបង្ការ ទប់ស្កាត់** បានអញ្ជើញធ្វើបទបង្ហាញ វិធីសាស្ត្រ ៧ចំនុចក្នុងការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់សិក្ខាកាមចំនួន ១០៦នាក់ មកពីស្ថាប័ន និងមន្ទីរពាក់ព័ន្ធ នៅសាលាខេត្តបាត់ដំបង។
- **ខេត្តបាត់ដំបង** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិន៖
  - កម្មវិធីនៃវិទ្យុខេមរា FM91MHz របស់គម្រោង នៅក៏មានសុវត្ថិភាព ចំណាកស្រុកក៏មានសុវត្ថិភាព និងការអនុវត្តច្បាប់ ស្តីពីការងាររបស់កម្មករនិយោជិត និងនិយោជក នៃអង្គការសាម៉ារីតាន់ភីស សង្គ្រោះអន្តរជាតិ ចំនួន០៦លើក។
  - វេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ឱកាសស្វែងរកការងាររបស់ប្រជាពលរដ្ឋ និងវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩។
  - សិក្ខាសាលា ស្តីពីការរំលឹកឡើងវិញអំពីការថែទាំជំនួស សិទ្ធិកុមារ កិច្ចការពារកុមារ និង ការចូលរួមរបស់កុមារក្នុងការការពាររបស់ពួកគេ ការជួញដូរមនុស្ស ទេសន្តរប្រវេសន៍ និងការផ្សព្វផ្សាយអំពីវគ្គបណ្តុះបណ្តាលផ្សេងៗ។
  - ប្រជុំវេទិកាតុមូលជុំទី៦ លើប្រធានបទ "បញ្ហាប្រឈមក្នុងការធ្វើចំណាកស្រុករបស់អនីតិជន និងអំពើជួញដូរមនុស្ស" ចំនួន ០១លើក។
  - ជាវាគ្មិនកិត្តិយសស្តីពី សុវត្ថិភាពស្ត្រី ក្នុងការធ្វើចំណាកស្រុក និងកត្តាងាយរងគ្រោះចំពោះអ្នកធ្វើការផ្នែកសេវាកំសាន្ត អ្នករកស៊ីផ្លូវភេទ និងជនងាយរងគ្រោះដោយការជួញដូរ នៅស្ថានីយវិទ្យុជាតិកម្ពុជា FM92.70MHz ចំនួន០២លើក។
  - វេទិកាយុវជនក្រោមប្រធានបទ កាលានុវត្តភាពទីផ្សារការងាររបស់យុវជនកម្ពុជាក្នុងស្ថានភាពកូវីដ១៩។

- **ខេត្តសៀមរាប៖**
  - មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត៖ បានចូលរួមជាវាគ្មិន នៅប៉ុស្តិ៍វិទ្យុជាតិនគរភ្នំខេត្តសៀមរាប ស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការអនុវត្តច្បាប់ ស្តីពីការងាររបស់កម្មករនិយោជិត និងនិយោជក នៅក្នុងខេត្តសៀមរាប បានចំនួន ០២លើក និងបានចូលរួមជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរ នៅស្រុកអង្គរជុំ បានចំនួន ០១លើក ដែលមានចំនួន ចូលរួមសរុប **២៧នាក់ ស្រី ២៣នាក់** ។
  - ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត ចូលរួមជាវាគ្មិន ក្នុងកម្មវិធីវិទ្យុនគរភ្នំ ០១លើក។
- **ខេត្តក្រចេះ៖** បានចូលរួមជាវាគ្មិនក្នុងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារក្រោមប្រធានបទ អំពើហិង្សា និងការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ តាមរយៈការផ្សព្វផ្សាយសម្លេង និងការផ្សាយផ្ទាល់តាមផេកហ្វេកបុក របស់វិទ្យុសម្លេងស្ត្រីខេត្ត ចំនួន ០៤លើក។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួម៖
  - ជាគ្រូឧទ្ទេសធ្វើបទបង្ហាញ ស្តីពី នីតិវិធីទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស ចំនួន ០២លើក នៅសាលាស្រុកព្រៃឈរ និងស្រុកចំការលើ ខេត្តកំពង់ចាម។
  - បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិនៅវិទ្យុជាតិភ្នំស្រី ភ្នំប្រុស ក្រោមប្រធានបទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ០២លើក។
  - ជាគ្រូឧទ្ទេសធ្វើបទបង្ហាញវគ្គបណ្តុះបណ្តាល អំពីយន្តការដោះស្រាយពាក្យបណ្តឹងរបស់ពលករទេសន្តរប្រវេសន៍ និងអ្នកពាក់ព័ន្ធ នៅស្នាក់ការរបស់អង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ ០១លើក មានអ្នកចូលរួម ២៥នាក់ ស្រី០៨នាក់។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ

### ខ.២.១. ការបង្កើតកម្មវិធីសិក្សា ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស

- **ក្រសួងអប់រំ យុវជននិងកីឡា៖** (១)សហការជាមួយអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ Plan International រៀបចំ «សៀវភៅមេរៀន ស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស» សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីសិក្សា កម្រិតបឋមសិក្សា និងមធ្យមសិក្សា និងបានបញ្ចប់ជាស្ថាពរ។ សៀវភៅសិក្សានេះ នឹងត្រូវប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅខែកុម្ភៈ ឆ្នាំ២០២១ ហើយនឹងបន្តធ្វើការបណ្តុះបណ្តាលគ្រូបង្គោល សម្រាប់ការបន្តបណ្តុះបណ្តាលវិធីសាស្ត្រប្រើប្រាស់សៀវភៅនេះ នៅទូទាំងប្រទេស និងរៀបចំឧបករណ៍សម្រាប់ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ និងគ្រូឧទ្ទេសសាលាគរុកោសល្យ។ (២)បាន និងកំពុងសហការជាមួយអង្គការក្លែនអន្តរជាតិថៃ សិក្សាលើលទ្ធភាពនៃការបង្កើតកម្មវិធីសិក្សា ពីរភាសា កម្ពុជា-ថៃ សម្រាប់កុមារជាប់ព្រំដែនកម្ពុជា-ថៃ ដែលត្រូវបានសាកល្បង នៅខេត្តត្រាត និងកោះកុង ដើម្បីបន្តរកលទ្ធភាពផ្តល់ការសិក្សាទៅកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ក្នុងប្រទេសថៃ។

### ខ.២.២. ការលើកកម្ពស់អភិបាលកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- **ថ្នាក់ជាតិ៖**
  - **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានដាក់ចេញនូវវិធានការគ្រប់គ្រងស្ថានភាព ការទទួល ការបញ្ជូនពលករតាមបណ្តាច្រកព្រំដែន និងការធ្វើសមាហរណកម្មតាមបណ្តាមូលដ្ឋានថ្នាក់ក្រោមជាតិ ដោយរក្សាសុវត្ថិភាពសុខភាព តាំងពីដំណាក់កាលដំបូង នៃការប្រកាសបិទព្រំដែនរបស់ថៃ។
  - **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖**

- បានចុះធ្វើអធិការកិច្ចលើទីភ្នាក់ងារជ្រើសរើសឯកជន បានចំនួន ១២លើក មានទីភ្នាក់ងារជ្រើសរើសឯកជនចំនួន១២ ដើម្បីបង្កើនសមត្ថភាព និងតម្រង់ទិសការងារដល់ទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗ ក្នុងការគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទបញ្ញាជាធរមាន សំដៅពង្រឹងប្រសិទ្ធភាពនៃការការពារ និងលើកកម្ពស់ពលករខ្មែរដែលទៅធ្វើការនៅបរទេស។
- បានធ្វើការអប់រំណែនាំតម្រង់ទិសពលករមុនចេញដំណើរអំពីភាសា បណ្តុះបណ្តាលជំនាញបឋម របៀបរបបធ្វើការងារ និងច្បាប់របស់ប្រទេសទទួលពលករ លក្ខខណ្ឌការងារ ការរស់នៅ និងទំនៀមទម្លាប់ប្រពៃណីនៃប្រទេសទទួល បានចំនួន ២០.៣៦០នាក់ ស្រី៨.១៣៦នាក់។
- បានរៀបចំពិព័រណ៍ការងារចល័ត និងរៀបចំវេទិកាការងារចំនួន ២៩៤លើក មានអ្នកចូលរួម ៣៤.៥២៦នាក់។
- បានចុះឈ្មោះអ្នកស្វែងរកការងារ ចំនួន ១៧.២០១នាក់ ស្រី១២.៨៨៤នាក់ និងជួយស្វែងរកការងារជូនប្រជាពលរដ្ឋតាមរយៈយន្តការផ្គូផ្គងការងារតាមបច្ចេកវិទ្យាព័ត៌មាន មជ្ឈមណ្ឌលការងារ និងវេទិកាការងារថ្នាក់ជាតិ ខេត្ត និងមូលដ្ឋាន ចំនួន ១៧.៣០៣នាក់ ស្រី១០.០៩៩នាក់ និងមានអ្នកទទួលបានការងារធ្វើចំនួន ៤.៨១៤នាក់ ស្រី២.៦៧៣នាក់។
- បានចេញសេចក្តីជូនដំណឹង ស្តីពីឱកាសការងារក្នុងស្រុកប្រមាណពីរម៉ឺនកន្លែង ត្រៀមសម្រាប់ពលករខ្មែរមកពីថៃ ក្រោយបញ្ចប់ការធ្វើចត្តាឡីស័ក។ ទន្ទឹមនឹងនោះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ បានដាក់ចេញនូវយន្តការថ្មី ដែលមានលេខទូរស័ព្ទទំនាក់ទំនងរបស់មជ្ឈមណ្ឌលការងារ ១៣កន្លែង នៅបណ្តារាជធានី ខេត្ត និងបង្កើតជនបង្គោលទំនាក់ទំនងជាមួយអាជ្ញាធរ ដើម្បីប្រមូលទិន្នន័យ ពលករដែលបានវិលត្រឡប់ពីប្រទេសថៃ ដើម្បីស្វែងរកព័ត៌មានពាក់ព័ន្ធនឹងតម្រូវការការងារ និងឆ្លើយតបឱ្យបានទាន់ពេលវេលា។
- បានផ្តល់សេវាប្រឹក្សាយោបល់អាជីព ការងារ និងវិជ្ជាជីវៈ ដល់សិស្ស និស្សិតនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងសាកលវិទ្យាល័យចំនួន ៦.២៣៨នាក់ ។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**

- បានចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅមណ្ឌលអង្គការក្តីសង្ឃឹមនិងយុត្តិធម៌(Hope For Justic) អង្គការសួននៃក្តីសង្ឃឹម អង្គការមេត្រីអន្តរជាតិ(AIM) និងអង្គការរតនៈអន្តរជាតិ។
- បានធ្វើការចុះប៉ាន់ប្រមាណគ្រួសារ និងកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០២លើក សរុបចំនួនមនុស្ស ០៧នាក់ (ស្រី ០១នាក់ នៅស្រុក ប្រសាទសំបូរ ខេត្តកំពង់ធំ ០៦នាក់ (ករណីជួញដូរកម្លាំងពលកម្ម) និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ០១នាក់ (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ)។
- បានចុះត្រួតពិនិត្យ និងតាមដានជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ក្រោយពីបានធ្វើសមាហរណកម្មទៅសហគមន៍វិញ បានចំនួន ១២២នាក់ (ស្ត្រី១១៣នាក់ កុមារ០២នាក់) ដោយមានការគាំទ្រពីអង្គការដៃគូ។
- បានសហការជាមួយអង្គការដៃគូ ចុះពិនិត្យ និងតាមដានស្ត្រីពពោះជំនួស០១លើក(ក្នុងនោះបាត់ខ្លួនទាំងម្តាយ និងកូន) ខេត្តកំពង់ចាម។

▪ **អគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានប្រមូលទិន្នន័យពលករវិលត្រឡប់ចូលមកប្រទេសវិញ ពីក្រុមការងារទទួលពលករនៅព្រំដែន និងពីតាមបណ្តាខេត្ត ជាប្រចាំ។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ មានពលករវិលត្រឡប់មកពីក្រៅប្រទេស សរុប ១២៤.៩៤២នាក់ ស្ត្រី ៥៦.៣៤៥នាក់។

- **ថ្នាក់ក្រោមជាតិ៖**
  - **លេខាធិការដ្ឋានរាជធានី ខេត្ត** បានធ្វើសេចក្តីរាយការណ៍ជាប្រចាំ អំពីពលករ និងពលរដ្ឋ ដែលវិលត្រឡប់ពីបរទេស ដើម្បីតាមដានស្ថានភាពសុខភាព ជីវភាព និងធ្វើការអប់រំបង្ការទប់ស្កាត់ ការវិលត្រឡប់ទៅប្រទេសគោលដៅដោយប្រថុយប្រថាន តាមការញុះញង់ពីមេខ្យល់ និងសហការជាមួយអង្គការដៃគូ ដើម្បីធ្វើការប៉ាន់ប្រមាណអំពី ភាពប្រឈម និងសេចក្តីត្រូវការ ក្នុងពេលធ្វើសមាហរណកម្ម និងបានសហការជាមួយអង្គការដៃគូ សប្បុរសជន ផ្តល់ការឧបត្ថម្ភគាំទ្រ ផ្នែកសុខភាព និងជីវភាព។
  - **ខេត្តកំពង់ស្ពឺ** ក្រុមការងារអធិការកិច្ចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ និងបានបញ្ជ្រាបអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមបណ្តាក្រុមហ៊ុននានាចំនួន ០២លើក។
  - **ខេត្តរតនគិរី៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចុះធ្វើអធិការកិច្ចសាមញ្ញ ១៣លើក និងចុះធ្វើអធិការកិច្ចពិសេស១៤លើក មិនឃើញមានករណីកេងប្រវ័ញ្ចកម្លាំងពលកម្មឡើយ។
  - **ខេត្តសៀមរាប៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះធ្វើអធិការកិច្ចការងារ និងវិធានការចំពោះសហគ្រាសដែលប្រព្រឹត្តល្មើសច្បាប់ស្តីពីការងារ បានចំនួន ២២សហគ្រាស ស្មើនឹង២២លើក។
  - **ខេត្តប៉ៃលិន៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡូតដ្ឋ និងអាហារដ្ឋាន ចំនួន ៨០កន្លែង ដោយរកពុំឃើញមានការកេងប្រវ័ញ្ច និងអំពើជួញដូរកម្លាំងពលកម្មទេ។
  - **ខេត្តកណ្តាល៖** ១-មន្ទីរទេសចរណ៍ខេត្ត បានធ្វើបច្ចុប្បន្នភាពអាជីវកម្មសេវាទេសចរណ៍ ទូទាំងខេត្ត សរុបចំនួន ៤០០កន្លែង មានបុគ្គលិកបម្រើការ សរុបចំនួន ២.២៨៥នាក់ ស្រី ១.៣៨០នាក់ និងបានផ្សព្វផ្សាយពីវិធានការណែនាំរបស់ក្រសួងសុខាភិបាល ស្តីពីការពារទប់ស្កាត់ ការរីករាលដាលនៃជំងឺកូវីដ-១៩ ហើយក៏បានធ្វើការផ្សព្វផ្សាយ និងណែនាំដល់ម្ចាស់អាជីវកម្មខាងលើ ពាក់ព័ន្ធទៅនឹងករណីជួញដូរផ្លូវភេទលើកុមារផងដែរ។

### ១.២.៣. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

ក្នុងឆ្នាំ២០២០នេះ តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេសតាមរយៈ ទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈ ប្រព័ន្ធអនុគ្រោះមុខរបរ Employment Permit System(EPS) របស់រាជរដ្ឋាភិបាល មានចំនួនសរុប **២២.៧៦៩នាក់ ស្រី៩.៤២៨នាក់** ក្នុងនោះមាន៖

| | | | | |
|---|---|---|---|---|
| - ប្រទេសថៃឡង់ដ៍ | ចំនួន | ១៨.៦២៥នាក់ | ស្រី | ៧.៩១៩នាក់ |
| - ប្រទេសជប៉ុន | ចំនួន | ៣.១០៩នាក់ | ស្រី | ១.២១១នាក់ |
| - ប្រទេសសិង្ហបុរី | ចំនួន | ៣៩នាក់ | ស្រី | ៣៩នាក់ |
| - ប្រទេសម៉ាឡេស៊ី | ចំនួន | ២៦នាក់ | ស្រី | ០៩នាក់ |
| - តំបន់រដ្ឋបាលពិសេសហុងកុង | ចំនួន | ៥១នាក់ | ស្រី | ៥១នាក់ |
| -ប្រទេសកូរ៉េតាមប្រព័ន្ធអនុគ្រោះមុខរបរ EPS | ចំនួន | ៩១៩នាក់ | ស្រី | ១៩៩នាក់។ |

ទន្ទឹមនឹងនេះ ក្នុងស្ថានភាពដែលមានជម្ងឺកូវីដ ១៩ រាតត្បាត ចាប់ពីចុងឆ្នាំ២០១៩ ប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង បានទទួលរងឥទ្ធិពលនៃការឆ្លងជម្ងឺនេះ គួរឱ្យព្រួយបារម្ភ និងឈានដល់ការបិទរោងចក្រ សហគ្រាស ការដ្ឋានការងារមួយចំនួន រហូតដល់បិទការចល័តពីភូមិដែលប្រឈមខ្លាំង ឬស្រុក ឬខេត្តមួយចំនួន រហូតដល់បិទព្រំដែនប្រទេស មិនឱ្យមានការឆ្លងដែនទៅមកជាមួយប្រទេសដទៃថែមទៀត។ ប្រទេសថៃ បានប្រកាសបិទព្រំដែនរបស់ខ្លួនលើកទី១ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០។

វិធានការនេះបានបង្កឱ្យមានការព្រួយបារម្ភដល់ពលករ ដែលកំពុងរស់នៅក្នុងប្រទេសថៃ និងដែលកំពុងបាត់បង់ការងារ ឱ្យវិលត្រឡប់មកកម្ពុជាវិញ។ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទៅពិនិត្យស្ថានភាពនៅព្រំដែន ពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ និងបានជំរុញឱ្យ អាជ្ញាធរខេត្តនៅជាប់ព្រំដែន ដំឡើងបញ្ជីពលករទេសន្តរប្រវេសន៍វិលត្រឡប់ ដោយបញ្ចូលព័ត៌មានចាំបាច់ដូចជា ការធ្វើការពិនិត្យកំដៅ និងបង្កើតទំនាក់ទំនង ប្រព័ន្ធបញ្ជូន ដើម្បីតាមដានសុខភាព និងស្ថានភាពរស់នៅ ពេលទៅដល់មូលដ្ឋានរបស់គាត់។ រាជរដ្ឋាភិបាល បានណែនាំឱ្យរដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ សហការជាមួយគ្រប់ក្រសួង មន្ទីរ អង្គភាព ស្ថាប័ន គ្រប់ថ្នាក់ និងអង្គការដៃគូ រួមគ្នាទប់ស្កាត់ការឆ្លងរាលដាលជំងឺដ៏កាចសាហាវនេះ និងយកចិត្តទុកដាក់ចំពោះជីវភាពរស់នៅ ក្នុងដំណាក់កាលនៃការវិលត្រឡប់នេះ ព្រមជាមួយស្ថានភាពសហគមន៍ និងគ្រួសារ ដែលត្រូវរ៉ាប់រងនូវបន្ទុកអ្នកវិលត្រឡប់ដែលមកវិញដោយដៃទទេ និងមានទាំងស្ថានភាពលំបាក ស្ត្រីមានផ្ទៃពោះ ឬមាតុភាព ជនពិការ ចាស់ជរា និងកុមារក្នុងបន្ទុកជាដើម បន្ថែមលើវិធានការដែលរាជរដ្ឋាភិបាល បាននិងកំពុងដោះស្រាយលើបញ្ហាប្រឈម នៃការរងសម្ពាធ នៃវិបត្តិសេដ្ឋកិច្ចដែលជះឥទ្ធិពលពីកូវីដ-១៩ ធ្វើឱ្យរោងចក្រ សហគ្រាសមួយចំនួន បិទទ្វារ ផ្អាកការងារ អ្នកវិនិយោគផ្អាកសកម្មភាព កម្មករ កម្មការិនី បាត់បង់ការងារ រួមជាមួយវិបត្តិគ្រោះទឹកជំនន់ដែលអូសបន្លាយក្នុងរយៈពេលវែងក្នុងផ្នែកខ្លះនៃរាជធានីភ្នំពេញ និងក្នុងខេត្តមួយចំនួន ជាពិសេស ខេត្តជាប់ព្រំដែនថៃ។

ពលករត្រូវត្រឡប់ចូលមកកម្ពុជាវិញ តាមច្រកមិនផ្លូវការ និងរាយប៉ាយតាមព្រំដែន ដែលចាំបាច់ត្រូវមានកម្លាំងអាជ្ញាធរ សមត្ថកិច្ច របស់ខេត្តជាប់ព្រំដែន និងខេត្តផ្សេងៗដែលមានពលករ សហការជាមួយមន្ត្រីសុខាភិបាល មធ្យោបាយដឹកជញ្ជូនពីយោធា កងរាជអាវុធហត្ថ នគរបាលព្រំដែន កម្លាំងយុវជន នារី អង្គការសមាគម និងវិស័យឯកជនជាច្រើន ចូលរួមក្នុងការទទួលពលករ ចុះបញ្ជី ពិនិត្យកម្តៅ សម្ភាសន៍ពីស្ថានភាព ផ្តល់សេវាចាំបាច់ រៀបចំកន្លែង និងបញ្ជូនទៅធ្វើចត្តាឡីស័ក ពិនិត្យរកមេរោគកូវីដ-១៩ ផ្តល់ការព្យាបាល និងផ្តល់ការឧបត្ថម្ភជាគ្រឿងឧបភោគ បរិភោគ សម្ភារៈអនាម័យ និងការអប់រំផ្សេងៗ។ ប្រព័ន្ធទិន្នន័យ នៃពលករវិលត្រឡប់ ត្រូវបានបង្កើតឡើង និងប្រើប្រាស់ ជាមូលដ្ឋានសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមានរបាយការណ៍ជាប្រចាំពីគ្រប់ខេត្ត និងរាជធានី ។

តាមរបាយការណ៍ពីស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដែលបានតាមដានបច្ចុប្បន្នភាពទិន្នន័យនៃពលករដែលធ្វើចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ ឃើញថា ក្នុងរយៈពេលបីខែដើមឆ្នាំ មានប្រជាជនចំណាកស្រុកចេញ ចូលជាប្រក្រតី។ ប៉ុន្តែក្រោយខែមីនា ឆ្នាំ២០២០ ចំនួននៃអ្នកធ្វើចំណាកស្រុកឆ្លងដែន នៅតិចតួចបំផុត ហើយសុទ្ធតែជាការឆ្លងដែនខុសច្បាប់ក្នុងអំឡុងពេល នៃការរឹតបន្តឹង និងបិទព្រំដែន នៃប្រទេសជិតខាង និងការបិទជើងយន្តហោះ។ អ្នកដែលប្រថុយប្រថានឆ្លងដែនដោយខុសច្បាប់ក្នុងអំឡុងពេលនេះ ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា និងប្រទេសពាក់ព័ន្ធ ធ្វើការហាមឃាត់ ឬបញ្ជូនត្រឡប់មកមូលដ្ឋានសហគមន៍ដែលគាត់រស់នៅវិញ។

ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២០ រដ្ឋបាលរាជធានី ខេត្ត បានប្រមូលទិន្នន័យជាប្រចាំ នូវចំនួនពលករវិលត្រឡប់ជារៀងរាល់ថ្ងៃ សរុបប្រមាណ **១២៩,៤២០**នាក់ មានស្ត្រីប្រមាណ **៥៦,៣៤៥**នាក់ (**៤៣.៥៣%**) ដែលភាគច្រើន មិនមានសេសសល់ប្រាក់ចំណូលសម្រាប់ការផ្គត់ផ្គង់ខ្លួន ឬគ្រួសារនៅឯស្រុកទេ។

***តារាងពលករវិលត្រឡប់គិតពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២០***

| ល.រ | ខេត្ត | ចំនួនអ្នកវិលត្រឡប់សរុប | ស្ត្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ១៩៨ | | |
| ២ | កណ្តាល | ១.៩៤០ | ៩០២ | |
| ៣ | កំពង់ឆ្នាំង | ១.៥២៥ | ៤៩៨ | |

| | | | | |
|---|---|---|---|---|
| ៤ | កំពង់ស្ពឺ | ១.១៤២ | ៣៧៦ | |
| ៥ | កំពង់ចាម | ៦.០៤៦ | ២.៦៧៥ | |
| ៦ | កំពង់ធំ | ៦.០៤៥ | ២.២៩៩ | |
| ៧ | កំពត | ១.២៨៧ | ៤៩៩ | |
| ៨ | កែប | ៤២ | ២ | |
| ៩ | កោះកុង | ១៤០ | ៧៣ | |
| ១០ | ក្រចេះ | ៤០០ | ១៥៤ | |
| ១១ | តាកែវ | ៦.៦៣២ | ២.៨៧៨ | |
| ១២ | ត្បូងឃ្មុំ | ៣.១៩៥ | ១.២៩១ | |
| ១៣ | បាត់ដំបង | ២០.៩៦៧ | ៩.៥៨១ | |
| ១៤ | បន្ទាយមានជ័យ | ៣៣.៩៧៦ | ១៥.៧៣០ | |
| ១៥ | ប៉ៃលិន | ១.៤៤៧ | ៦៧៣ | |
| ១៦ | ពោធិសាត់ | ៣.៥០៥ | ១.៥៥៦ | |
| ១៧ | ព្រៃវែង | ១២.០៤៦ | ៤.៦០៦ | |
| ១៨ | ព្រះវិហារ | ៥៤៦ | ២២៤ | |
| ១៩ | ព្រះសីហនុ | ២៤២ | ១០៣ | |
| ២០ | មណ្ឌលគីរី | ១២ | ៤ | |
| ២១ | រតនគិរី | ៤៧ | ១៨ | |
| ២២ | សៀមរាប | ២០.១៥០ | ៨.៨៧៦ | |
| ២៣ | ស្ទឹងត្រែង | ៨២ | ៣២ | |
| ២៤ | ស្វាយរៀង | ៣.០៨១ | ១.១៤៧ | |
| ២៥ | ឧត្តរមានជ័យ | ៤.៧២៧ | ២.១៤៨ | |
| សរុប | | **១២៨.៤២០ នាក់** | **៥៦.៣៤៥ នាក់** | |

▪ **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារព្រំដែនគោក វរសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន **៦៩**លើក ហើយបានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ចំនួន ៨០១នាក់ (ស្រី ៣៣២នាក់ អនីតិជន ៤៦នាក់) បានធ្វើការអប់រំ និងឱ្យត្រឡប់ទៅផ្ទះវិញ។

▪ **ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរដែលឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ ចំនួន **១១**លើក មនុស្សចំនួន **១៩១**នាក់ (ស្រី ៨៦នាក់) និងបានធ្វើការអប់រំណែនាំ និងបានបញ្ជូនទៅធ្វើចត្តាឡីស័ក ពិនិត្យសុខភាពបន្ត។

▪ **ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង៖** បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសវៀតណាមដោយខុសច្បាប់ ចំនួន **០៤**លើក មនុស្សចំនួន **៣៩**នាក់ ស្រី**១៣**នាក់។

▪ **ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ដើម្បីបង្ការទប់ស្កាត់រាល់បទល្មើសផ្សេងៗ និងការឆ្លងដែនខុសច្បាប់ ចំនួន **៤៧៤**លើក(ព្រំដែនកម្ពុជា វៀតណាម **៤៣៧**លើក និងព្រំដែនកម្ពុជា-ឡាវ **៣៧**លើក)។

### ១.២.៤. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

**▪ អគ្គស្នងការដ្ឋាននគរបាលជាតិ**

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ល្បាតឃ្លាំមើលគោលដៅ សង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ៤០៩លើក។

*ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ*

| ស្នងការដ្ឋាន រាជធានី-ខេត្ត | ឆ្នាំ២០២០ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| | ៣១លើក | ៣២លើក | ៤៧លើក | ៤៧លើក | ៣០លើក | ៣០លើក | ២៥លើក | ១៧លើក | ៩០លើក | ២២លើក | ១៨លើក | ២០លើក |
| សរុប | ៤០៩ លើក | | | | | | | | | | | |

- ស្នងការដ្ឋាននគរបាលខេត្តតាកែវ មណ្ឌលគិរី ស្វាយរៀង កោះកុង កែប ឧត្តរមានជ័យ បន្ទាយមានជ័យ ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ ក្រចេះ ត្បូងឃ្មុំ កំពង់ធំ ព្រៃវែង រតនគិរី និងខេត្តកំពង់ចាម បានធ្វើសកម្មភាពបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមគោលដៅបម្រើសេវាកំសាន្ត ដែលអាចបង្កប់សេវាផ្លូវភេទ ដោយចុះធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ ដូចមានតារាងខាងក្រោម៖

*តារាងបច្ចុប្បន្នភាពគោលដៅសេវាកំសាន្ត ដែលបានធ្វើការអប់រំដើម្បីបង្ការទប់ស្កាត់*
*អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០២០*

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនគោលដៅ | ៥០៨ | ៦១៩ | ៦៣០ | គ្មាន | គ្មាន | ២៦៦ | ១៨៣ | ៣៤៤ | ៤៧០ | ៥០ | ២៤០ | ១២ |
| ចំនួនមនុស្ស | ២.១២៧ | ៧.២៨៩ | ៩.៧១៩ | គ្មាន | គ្មាន | ២៤.៩៥១ | ៣.០១៩ | ១.១២២ | ១.៩០៧ | ៣៥៣ | ៧៩៤ | ១៣២ |
| ចំនួនស្ត្រី | ១.០៦៨ | ៥.៣៧២ | ៦.០៧៣ | គ្មាន | គ្មាន | ១២.៧១៥ | ១.៧៧១ | ៨៣៨ | ១.០២២ | ១៦៩ | ២៦៦ | ១១៦ |

### ១.២.៥. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តច្បាប់**) នៃច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានទទួលពាក្យ និងសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ សរុបចំនួន **១.១៣១គូ**។ និងបានទំនាក់ទំនងសាកសួរព័ត៌មានអំពីនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស បានចំនួន **១១២**នាក់ ក្នុងនោះសាធារណរដ្ឋកូរ៉េ ៩៤នាក់ និងចិន ១៨នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។

## ១.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

**• ថ្នាក់ជាតិ៖**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះធ្វើអធិការកិច្ចការងារតាមរោងចក្រចំនួន ០៨រោងចក្រ ដែលបានស្នើសុំកម្មករនិយោជិតវ័យក្មេងចំនួន ០៨លើក មានកម្មករនិយោជិតវ័យក្មេងចំនួន ៨៩នាក់ ស្រី៥៣នាក់ ដើម្បីតាមដានការអនុវត្តគោលការណ៍សុវត្ថិភាពកម្មករ និយោជិតវ័យក្មេង របស់រោងចក្រសហគ្រាស។

- **ថ្នាក់ក្រោមជាតិ៖**
  - **ខេត្តសៀមរាប៖**
    - ស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះត្រួតពិនិត្យ និងស៊ើបអង្កេត និងចុះអធិការកិច្ចស្រង់ស្ថិតិកុមារ និងកម្មករដែលកំពុងស្នាក់នៅ នៅតាមសិប្បកម្មផលិតឥដ្ឋ ដែលសង្ស័យមានការជួញដូរកម្លាំងពលកម្ម និងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ នៅស្រុកក្រឡាញ់ និងស្រុកបន្ទាយស្រីបានចំនួន **០៧លើក/០៨កន្លែង** ជាលទ្ធផលពុំមានការប្រើប្រាស់កម្លាំងពលកម្មកុមារទេ និងបានធ្វើការផ្សព្វផ្សាយបន្ថែមអំពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យឡឥដ្ឋ ។
    - ក្រុមការងារចម្រុះលេខាធិការដ្ឋាន គ.ខ.ប.ជ បានចុះ
      - បិទមណ្ឌលបណ្តោះអាសន្ន របស់អង្គការដាវ៉ូម៉ា (ដើម្បីធ្វើការស្រាវជ្រាវ អំពីករណីបទល្មើសរំលោភកុមារក្នុងមណ្ឌល) និងធ្វើការដកហូតកុមារ ចំនួន **១៣នាក់ ស្រី០៨នាក់** ដើម្បីទុកដាក់កុមារនៅកន្លែងមានសុវត្ថិភាព។
      - ប៉ាន់ប្រមាណស្ថានភាពគ្រួសារកុមាររងគ្រោះ លើករណីជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច និងប្រទូសរកេរខ្មាស់ ចំនួន **១៣**នាក់ ក្នុងនោះកុមារីចំនួន **០៨**នាក់ ដែលស្ថិតនៅក្នុងស្រុកសូទ្រនិគម ស្រុកក្រឡាញ់ ស្រុកស្វាយលើ ស្រុកអង្គរជុំខេត្តសៀមរាប និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
      - អង្គការដើម្បីភាពញញឹមនៃកុមារ(PSE)៖ បានសហការជាមួយ អាជ្ញាធរមូលដ្ឋាន ដើម្បីការផ្តល់ជូនកុមារ និងគ្រួសារកុមារក្រីក្រ នូវស្បៀង សម្ភារសិក្សា ថវិកា ការផ្តល់ប្រឹក្សា ការតម្រង់ទិសវិជ្ជាជីវៈជំនាញទន់ ការអប់រំសីលធម៌ និងច្បាប់ពាក់ព័ន្ធការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានសរុបចំនួន ២៧៨គ្រួសារ។
  - **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះត្រួតពិនិត្យ និងស៊ើបអង្កេត និងចុះអធិការកិច្ចស្រង់ស្ថិតិកុមារ និងកម្មករដែលកំពុងស្នាក់នៅ នៅតាមសហគ្រាសគ្រឹះស្ថានចំនួន ៣៧កន្លែង និងសិប្បកម្មលផលិតឥដ្ឋ ចំនួន១៤កន្លែង ជាលទ្ធផលពុំមានការប្រើប្រាស់កម្លាំងពលកម្មកុមារទេ។
  - **ខេត្តព្រះសីហនុ៖** សហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញ ដែលបានដាក់ចំនួន **១.២២៧**នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។
  - **ខេត្តប៉ៃលិន៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សែឡ កាស៊ីណូ ឡឥដ្ឋ និងអាហារដ្ឋាន ចំនួន ៨០កន្លែង ជាលទ្ធផលពុំមានការប្រើប្រាស់កម្លាំងពលកម្មកុមារទេ។
  - **ខេត្តស្វាយរៀង៖** បានចុះស្រង់ទិន្នន័យតាមគោលដៅសិប្បកម្ម រោងចក្រ សហគ្រាសដែលសង្ស័យអាចមានការពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ចំនួន **២០**លើក ស្មើនឹង **៧៨**គោលដៅមានកម្មករសរុប **៦៥.៩៥០**នាក់ ស្រី **១.៤៥៤**នាក់ ជនបរទេស ចំនួន **២៧**នាក់ ជាលទ្ធផលពុំមានការប្រើប្រាស់កម្លាំងពលកម្មកុមារទេ។
  - **ខេត្តរតនគិរី៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះធ្វើអធិការកិច្ចសាមញ្ញចំនួន **២៦**លើក អធិការកិច្ចពិសេស១៤លើក ដើម្បីពិនិត្យលើការអនុវត្តច្បាប់ស្តីពីការងារ និងការប្រើប្រាស់ពលកម្មកុមារ ជាលទ្ធផលក្រុមហ៊ុនបានអនុវត្តតាមបែបបទស្តីពីសហគ្រាស និងលក្ខខណ្ឌការងារបានល្អប្រសើរ។

## ខ.៤. ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន

ជាយន្តការសម្រាប់គ្រប់គ្រងពលករខ្មែរដែលចេញទៅធ្វើការនៅក្រៅប្រទេស ក្រសួងពាក់ព័ន្ធសំខាន់ចំនួន០៣ គឺ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចទទួលខុសត្រូវចំពោះសុវត្ថិភាព ផលប្រយោជន៍ និងការគោរពសិទ្ធិពលករក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ការងារ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាល បានដាក់ចេញនូវអនុក្រឹត្យ លេខ ១៩០អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងប្រកាស ចំនួន ០៨ដើម្បីកំណត់តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករ និងយន្តការនៃការដោះស្រាយបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍។

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានធ្វើបច្ចុប្បន្នភាពទីភ្នាក់ងារជ្រើសរើសពលករ ជាប្រចាំ និងបានផ្សព្វផ្សាយទូលំទូលាយតាមប្រព័ន្ធឌីជីថល(វិបសាយ និងហ្វេសប៊ុក) ថែមទៀត។ ជាការកត់សម្គាល់ចំនួនទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងឆ្នាំ២០២០ មាន១២៦ និងបានធ្វើសកម្មភាពដោយផ្តោតការយកចិត្តទុកដាក់លើការដោះស្រាយបញ្ហាដែលពលករកំពុងប្រឈមក្នុងប្រទេសគោលដៅ ជាជាងការជ្រើសរើសពលករថ្មីដើម្បីបញ្ជូននៅក្នុងស្ថានភាពនៃការរឹតបន្តឹង ដោយមានវិបត្តិកូវីដ-១៩។

- ក្នុងចំណោមទីភ្នាក់ងារទាំង១២៦ ត្រូវបានចងក្រងជាសមាគមចំនួនពីរ គឺ (១).សមាគមទីភ្នាក់ងារជ្រើសរើសពលករ(ACRA) (២).សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC) ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងផ្សព្វផ្សាយអំពីគោលការណ៍ផ្សេងៗ។
- ក្រសួងបានជួបប្រជុំផ្សព្វផ្សាយដល់ទីភ្នាក់ងារជ្រើសរើសឯកជនចំនួន ៧៥ អំពីគោលការណ៍ជ្រើសរើសប្រកបដោយក្រមសីលធម៌(IRIS Ethical Recruitment) របស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដែលផ្តោតសំខាន់លើការមិនយកថ្លៃឈ្នួលពីពលករ នៅក្នុងដំណាក់កាលជ្រើសរើស និងក្នុងដំណាក់កាលដាក់ឱ្យធ្វើការងារ ដែលថ្លៃឈ្នួលទាំងនោះនឹងត្រូវចេញជំនួសដោយនិយោជក។
- ដោយមានកិច្ចសហការពីអង្គការពលកម្មអន្តរជាតិ(ILO) បានជំរុញឱ្យទីភ្នាក់ងារជ្រើសរើសពលករបង្កើតនូវក្រមសីលធម៌របស់ទីភ្នាក់ងារ ដើម្បីធានានូវគុណភាព និងសុវត្ថិភាពពលករក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ការងារ។
- ក្រសួងមានប្រព័ន្ធទិន្នន័យសម្រាប់ការចុះបញ្ជីរបស់ទីភ្នាក់ងារ និងរបស់ពលករដែលត្រូវបានជ្រើសរើសដោយទីភ្នាក់ងារ និងស្ថានភាពការងារក្នុងប្រទេសគោលដៅ ដែលទីភ្នាក់ងារត្រូវផ្តល់របាយការណ៍ជាប្រចាំដល់នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម។
- ក្រសួងបានបង្កើតយន្តការដោះស្រាយវិវាទការងារ នៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងនៅតាមបណ្តាខេត្ត។ ក្នុងឆ្នាំ២០២០ យន្តការនេះបានដោះស្រាយសំណុំរឿងចំនួន ២១ ដែលជាវិវាទរវាងពលករ ចំនួន ៤០០នាក់ និងក្រុមហ៊ុនចំនួន ២០ ក្នុងនោះ ១៤សំណុំរឿង បានត្រូវដោះស្រាយជាស្ថាពរ ០៤សំណុំរឿងទុកជាមោឃៈ និង ០៣សំណុំរឿងទៀតនៅបន្តដោះស្រាយ។
- នៅតាមបណ្តាស្ថានទូតនៃបណ្តាប្រទេសគោលដៅ ដែលមានពលករកម្ពុជាបាននិងកំពុងស្នាក់នៅនិងធ្វើការច្រើន ក្នុងនោះមាន ព្រះរាជាណាចក្រថៃ សាធារណរដ្ឋកូរ៉េ ប្រទេសជប៉ុន និងប្រទេសម៉ាឡេស៊ី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់បញ្ជូនទីប្រឹក្សាអមស្ថានទូតទទួលបន្ទុកការងារ ដើម្បីដោះស្រាយបញ្ហា ពលករដែលនៅទីនោះ។

ឯក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គស្នងការដ្ឋាននគរបាលជាតិ (នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានកណ្តាលព្រំ

ដែន) និងរដ្ឋបាលថ្នាក់ក្រោមជាតិ សុទ្ធតែមានតួនាទី សម្របសម្រួល ផ្តល់ឯកសារស្របច្បាប់ ត្រួតពិនិត្យតាមដានលំហូរចេញចូលរបស់ពលករ និងការស៊ើបអង្កេត ស្រាវជ្រាវរកបទល្មើសក្នុងប្រព័ន្ធនៃការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានតួនាទីទំនាក់ទំនង សហប្រតិបត្តិការជាមួយប្រទេសពាក់ព័ន្ធ ក្នុងការធានាសុវត្ថិភាព ផលប្រយោជន៍ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពលករដែលបាននិងកំពុងធ្វើការក្នុងប្រទេសគោលដៅ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការខារអនុវត្តច្បាប់

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ចាម កំពង់ឆ្នាំង កណ្តាល កោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ ព្រៃវែង ពោធិសាត់ ស្វាយរៀង រតនគិរី សៀមរាប ព្រះសីហនុ ឧត្តរមានជ័យ កំពត ស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ។

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា កងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **១៥៥ករណី**លើ**១៦៩ករណី** (ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន **១៤ករណី** ស្មើនឹង**៨.២៨%**) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **១៩៣នាក់/២២៩នាក់**(ស្រី **៣០នាក់**) ក្នុងនោះជនសង្ស័យជាអនីតិជន **១២នាក់** និងជនបរទេស **២៣នាក់** មាន **០៨សញ្ជាតិ** (សញ្ជាតិអ៊ីស្រាអែល០១នាក់ ចិន១៣នាក់ អង់គ្លេស០១នាក់ វៀតណាម០៤នាក់ អាមេរិ ០១នាក់ ស៊ុយអ៊ែត០១នាក់ រុស្ស៊ី០១នាក់ និងបង់ក្លាដេស០១នាក់)។

សង្គ្រោះជនរងគ្រោះចំនួន **៤៦៧នាក់/៤៥៦នាក់** ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ **១៣០នាក់** អាយុ១៥-១៧ឆ្នាំ **៣៩នាក់** និងអាយុពី១៨ឆ្នាំឡើង **២៩៨នាក់** (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **៩៨នាក់** និងប្រគល់ឱ្យគ្រួសារ **៣៦៩នាក់**) ក្នុងនោះមានចែកជា៖

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **៤៤ករណី/៣៨ករណី**(កើនឡើង **០៦ករណី**) ឃាត់ខ្លួនជនសង្ស័យចំនួន **៥៥/៦១នាក់** (ស្រី **១៧នាក់**) ជនបរទេស**០៤នាក់** មាន**០៤សញ្ជាតិ** និងសង្គ្រោះជនរងគ្រោះចំនួន **២៧៦/១៥១នាក់** មាន៖ អាយុក្រោម១៥ឆ្នាំ **៣១នាក់** អាយុ១៥-១៧ឆ្នាំ **១៦នាក់** និងអាយុពី១៨ឆ្នាំឡើង **២២៩នាក់** (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **៣០នាក់** និងប្រគល់ឱ្យគ្រួសារ **២៤៦នាក់**)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំអនីតិជនដាក់ទីចេញដោយមិនស្របច្បាប់ | ០៥ | ០៦ | ០៥ | |
| -ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០៦ | ៣៣ | ០៦ | |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០៣ | ១៨ | ០៥ | បង់ក្លាដេស០១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ២២ | ១៦២ | ២៩ | |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០១ | ០១ | |
| -អំពើនាំឆ្លងដែន | ០១ | ៣៧ | ០១ | |

| | | | | |
|---|---|---|---|---|
| -ការទទួលមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ១០ | ០២ | ស៊ុយអែត០១ |
| -ការទិញពេស្យាចារកុមារ | ០៥ | ០៩ | ០៦ | អាមេរិក០១<br>អ៊ីស្រាអែល០១ |
| ***សរុប*** | ***៤៤ ករណី*** | ***២៧៦នាក់*** | ***៥៥ នាក់*** | ***០៤ នាក់*** |

## ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១១១ករណី/១៣១ករណី(ថយចុះ ២០ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៣៨/១៦៨នាក់ (ស្រី ១៣នាក់) អនីតិជន ១២នាក់ ជនបរទេស ១៩នាក់ មាន ០៤សញ្ជាតិ ។ សង្គ្រោះជនរងគ្រោះចំនួន ១៩១/៣០៥នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ៩៩នាក់ អាយុ១៥-១៧ឆ្នាំ ២៣នាក់ និងអាយុពី១៨ឆ្នាំឡើង ៦៩នាក់ (ប្រគល់ទៅមន្ទីរសង្គមកិច្ច ៦៨នាក់ និងប្រគល់ឱ្យ គ្រួសារ ១២៣នាក់)។

***តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ***

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ចារកម្ម | ០៦ | ៣៥ | ១២ | ចិន៤ រុស្ស៊ី១ |
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០៤ | ២៥ | ១០ | |
| -សញ្ចារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០២ | ១៩ | ០៣ | វៀតណាម៤ |
| -បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៦ | ០២ | |
| -ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០១ | ០៩ | |
| -ការផ្ដល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០១ | ០៤ | ០១ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ០៥ | ០៦ | ០៨ | ចិន៩ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០៣ | ០៣ | ០៣ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៧១ | ៧២ | ៧៣<br>(អនីតិជន១២) | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៧ | ២០ | ១៧ | អង់គ្លេស១ |
| ***សរុប*** | ***១១១ ករណី*** | ***១៩១ នាក់*** | ***១៣៨ នាក់<br>(អនីតិជន១២)*** | ***១៩ នាក់*** |

ក្រាហ្វិកប្រៀបធៀបបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៩-២០២០




➢ សូមបញ្ជាក់តារាងលំអិតនៃការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ(ឧបសម្ព័ន្ធ១)

## គ.២. កិច្ចការយុត្តិធម៌

### គ.២.១. លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ ដូចមានក្នុងតារាងលម្អិតខាងក្រោម៖

#### ១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖

សរុបមានចំនួន ៣១៣ករណី ជនរងគ្រោះចំនួន ៣៦៩នាក់(ស្រី ២៦០នាក់) ក្នុងនោះមានអនីតិជន ១៥៣នាក់(ស្រី១៤១នាក់) ជនត្រូវចោទមានចំនួន ៥៥២នាក់ (ស្រី ១១៨នាក់) ក្នុងនោះមានអនីតិជន ៤៥នាក់ (ស្រី ០២នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន ២៣៣ករណី តម្កល់ទុកឥតចាត់ការ ១៨ករណី បញ្ជូនរឿងទៅជម្រះផ្ទាល់ ១០ករណី និងកំពុងចាត់ការចំនួន ៥២ករណី។

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | បញ្ជូនរឿងទៅជម្រះផ្ទាល់ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | |
| ៣១៣ | ៩៧ | ១១៩ | ១២ | ១៤១ | ៣៩១ | ១១៦ | ៤៣ | ២ | ២៣៣ | ១៨ | ១០ | ៥២ |
| សរុប | ២១៦ នាក់ | | ១៥៣ នាក់ | | ៥០៧ នាក់ | | ៤៥ នាក់ | | ៣១៣ ករណី | | | |

#### ២.ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត៖

សរុបមានចំនួន ៣៤៨ករណី ជនរងគ្រោះចំនួន ៥៤៧នាក់ (ស្រី ៣៣៦នាក់) ក្នុងនោះមានអនីតិជន ១៨៨នាក់(ស្រី ១៥៨នាក់) ជនត្រូវចោទមានចំនួន ៥៤៦នាក់ (ស្រី ១១៩នាក់) ក្នុងនោះមានអនីតិជន ៣៥នាក់(ស្រី ០២នាក់) នៅក្នុងឃុំចំនួន ៣២២នាក់(ស្រី ៤៧នាក់) ក្នុងនោះមានអនីតិជន ២៣នាក់(ស្រី ០១នាក់) នៅក្រៅឃុំចំនួន ១៦៤នាក់(ស្រី ៥៩នាក់) អនីតិជន ០៥នាក់ និងបានបញ្ជូនទៅជម្រះចំនួន ១៤៨ករណី លើកលែងចោទ ១០ករណី និងកំពុងចាត់ការចំនួន ១៩០ករណី។

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| ៣៤៨ | ១៨១ | ១៧៨ | ៣០ | ១៥៨ | ៣៩៤ | ១១៧ | ៣៣ | ២ | ២៥៣ | ៤៦ | ២២ | ០១ | ១០០ | ៥៩ | ៥ | ០ | ១៤៨ | ១០ | ១៩០ |
| សរុប | ៣៥៩ នាក់ | | ១៨៨ នាក់ | | ៥១១ នាក់ | | ៣៥ នាក់ | | ២៩៩ នាក់ | | ២៣ នាក់ | | ១៦៤នាក់ | | | | ៣៤៨ ករណី | | |

#### ៣ .ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត៖

សរុបមានចំនួន ៣៥៥ករណី ជនរងគ្រោះចំនួន ៤៩៣នាក់(ស្រី ២៩៩នាក់) ក្នុងនោះមានអនីតិជន ១៨០នាក់(ស្រី ១៥៥នាក់) ជនជាប់ចោទសរុប ៥១៦នាក់(ស្រី ១៥០នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរ ០៨នាក់ ពិន័យជាប្រាក់ ០៤នាក់ រួចផុតពីបទចោទ ២១នាក់ រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ១៩២ករណី ផ្តន្ទាទោសជាក់ពន្ធនាគារក្នុងឃុំ ២៣៤នាក់ នៅក្រៅឃុំ ២០៦នាក់ និងកំពុងចាត់ការ ១៦៣ករណី)។

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោស ពន្ធនាគារ | | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | | | | | | ក្នុងឃុំ | ក្រៅឃុំ | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣៥៥ | ១៦៩ | ១៤៤ | ២៥ | ១៥៥ | ៣៦៦ | ១៥០ | ០៨ | ០៤ | ២១ | ០ | ១៩២ ករណី | ២៣៤ នាក់ | ២០៦ នាក់ | ១៦៣ ករណី |
| សរុប | ៣១៣ នាក់ | | ១៨០ នាក់ | | ៥១៦ នាក់ | | | | | | | | | |

ក្រាហ្វិកប្រៀបធៀបចំណាត់ការរបស់ចៅក្រមជំនុំជម្រះ ឆ្នាំ២០១៩-២០២០




## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

▪ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** តាមរយៈស្ថានតំណាងនៅបរទេស បានសង្គ្រោះ ឧបត្ថម្ភ និងជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណបឋម រកភាពរងគ្រោះ និងបានធ្វើការសន្និដ្ឋានបឋមថាជា ករណីស្នាក់នៅ និងធ្វើការងារដោយខុសច្បាប់ ឬសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស សរុបចំនួន **១០.៥៧៤**នាក់ (ស្រី **៤.២៧៥**នាក់) ក្នុងនោះពលករដែលមកពីប្រទេសថៃមានរហូតដល់ **១០.៤០៦**នាក់ ស្រី **៤.១៤៧**នាក់ ដែលជាពលករខុសច្បាប់។ មាន **២២០**នាក់ ត្រូវបានធ្វើឡើងដោយមានកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល។ ខាងក្រោមនេះជាតារាងនៃពលករដែលបានទទួលការសង្គ្រោះ ឧបត្ថម្ភ និងជួយសម្របសម្រួល ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖

| ល.រ. | ប្រទេសគោលដៅ | មូលហេតុនៃការវិលត្រឡប់ | សរុប | ស្រី |
|---|---|---|---|---|
| ១ | ម៉ាឡេស៊ី | ពលករខុសច្បាប់ | ៥៤ | ១៦ |
| ២ | ចិន | សង្ស័យជួញដូរ និងចាញ់បោកមេខ្យល់ | ៨២ | ៨២ |
| ៣ | សិង្ហបុរី | ទ្រាំការងារមិនបាន | ០២ | ០២ |
| ៤ | វៀតណាម | ឆ្លងដែនខុសច្បាប់ | ២៥ | ២៥ |
| ៥ | ថៃ | ពលករខុសច្បាប់ | ១០.៤០៦ | ៤.១៤៧ |
| ៦ | ឡាវ | ឆ្លងដែនខុសច្បាប់ | ០២ | ០២ |
| ៧ | ឥណ្ឌូណេស៊ី | ឆ្លងដែនខុសច្បាប់ | ០៣ | ០១ |
| សរុប | | | ១០.៥៧៤ នាក់ | ៤.២៧៥ នាក់ |

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលពលករទេសន្តរប្រវេសន៍ ដែលវិលត្រឡប់តាមច្រកព្រំដែន និងជនសង្ស័យរងគ្រោះ និងងាយរងគ្រោះ៖

- ពីអាជ្ញាធរប្រទេសនានា ២២០នាក់ (បុរស២៥នាក់ ស្ត្រី១៨៤នាក់ កុមារា០៤នាក់ កុមារី០៧នាក់) ដែលត្រឡប់មកតាមព្រលានយន្តហោះអន្តរជាតិភ្នំពេញ ១៥២នាក់ ព្រលានយន្តហោះព្រះសីហនុ ០២នាក់

ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ៣៨នាក់ និងច្រកទ្វារអន្តរជាតិបាវិត ២៨នាក់ ដែលមកពីប្រទេសម៉ាឡេស៊ី ១១នាក់ ឥណ្ឌូនេស៊ី ០៣នាក់ ចិន ១៣៩នាក់ វៀតណាម ២៨នាក់ ថៃ ៣៨នាក់ និងសិង្ហបុរី ០១នាក់។ ក្នុងនោះ ជាករណីជួញដូរកម្លាំងពលកម្ម ៥៤នាក់ អាពាហ៍ពិពាហ៍ដោយបង្ខំផ្ទុយពីឆន្ទៈ១១៣នាក់ ជួញដូរផ្លូវភេទ០៣នាក់ និងជាជនងាយរងគ្រោះ៥០នាក់។

- ពីនគរបាលយុត្តិធម៌សរុប **៣៩**នាក់ (បុរស ៣៨នាក់ ស្រី០១នាក់) ក្នុងនោះមានជនជាតិបង់ក្លាដេស ១៦នាក់(ប្រុស) ជនជាតិនេប៉ាល់ ២២នាក់(ប្រុស) ជនជាតិចិន ០១នាក់(ស្រី) ដែលរកឃើញថាជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម និងបានបញ្ជូនទៅអង្គការដៃគូ ដើម្បីទទួលសេវាបន្ត។

- បានទទួលពលករដែលត្រូវបានបញ្ជូនត្រឡប់ដោយអាជ្ញាធរថៃនៅតាម ច្រកអូរបីជាន់ និងច្រកអន្តរជាតិប៉ោយប៉ែត សរុបចំនួន **៦៣.៧៩៣**នាក់ (បុរស **៣១.៧៣៣**នាក់ ស្រី **២៥.៥៨០**នាក់ កុមារា **៣.៣១៨**នាក់ កុមារី **៣.១៦២**នាក់) និងបានកំណត់អត្តសញ្ញាណបឋម រកឃើញថា មានជនសង្ស័យថា រងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន **១០៦**នាក់ (បុរស ០៩នាក់ ស្រី ២៧នាក់ កុមារា ៤៩នាក់ កុមារី ២១នាក់) និងបានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ (តំណក់ទឹក សាម៉ារីតាន់ភឺស IJM និងអង្គការក្តីសង្ឃឹមនិងយុត្តិធម៌) ដើម្បីតាមដានបន្ត មុននឹងបញ្ជូនទៅលំនៅដ្ឋានវិញ។

▪ **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាននគរបាលខេត្ត ចំនួន០៥** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងកម្ពុជា-វៀតណាមចំនួន **៥០៧**លើក មនុស្សចំនួន **៧.២៨៦**នាក់ (ស្រី **២.៧៤៤**នាក់ អនីតិជន **៦៨៧**នាក់) ក្នុងនោះមាន៖

| | | | | |
|---|---|---|---|---|
| - **ខេត្តបន្ទាយមានជ័យ** | ចំនួន **២៧៥**លើក | មនុស្សចំនួន | **៤.២៤០**នាក់ | (ស្រី**១.៤២០**នាក់) |
| | | អនីតិជនចំនួន | **៤៩០**នាក់។ | |
| - **ខេត្តបាត់ដំបង** | ចំនួន **៩៣**លើក | មនុស្សចំនួន | **១.៨៦៣**នាក់ | (ស្រី **៨១៤**នាក់) |
| | | អនីតិជន | **១២២**នាក់។ | |
| - **ខេត្តប៉ៃលិន** | ចំនួន **២០**លើក | មនុស្សចំនួន | **៧៨៦**នាក់ | (ស្រី **៣៦៤**នាក់) |
| | | អនីតិជនចំនួន | **២៩**នាក់។ | |
| - **ខេត្តកោះកុង** | ចំនួន **១១១**លើក | មនុស្សចំនួន | **៣២២**នាក់ | (ស្រី **៩៩**នាក់) |
| | | អនីតិជនចំនួន | **០៨**នាក់។ | |
| - **ខេត្តស្វាយរៀង** | ចំនួន **០៨**លើក | មនុស្សចំនួន | **៧៥**នាក់ | (ស្រី **៤៧**នាក់) |
| | | អនីតិជន | **៣៨**នាក់។ | |

ក្នុងនោះ មន្ត្រីសមត្ថកិច្ចបានធ្វើការអប់រំ ណែនាំ អំពីសេវា និងបែបបទនីតិវិធី ក្នុងការធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់ និងបញ្ជូនត្រឡប់ទៅមូលដ្ឋានដែលគាត់រស់នៅវិញ។

### ឃ.១.២. ការទទួលសាកសពបញ្ជូនត្រឡប់

- **ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ** ទទួលសពពលរដ្ឋខ្មែរស្លាប់ដោយសារជំងឺ និងគ្រោះថ្នាក់ផ្សេងៗ មកពីប្រទេសថៃតាមច្រកប៉ោយប៉ែត បានចំនួន **៥៨**សព (ស្រី **១២**សព )។
- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** បានទទួលសពពលរដ្ឋខ្មែរដែលបានស្លាប់ដោយសារជំងឺ និងគ្រោះថ្នាក់ផ្សេងៗ ក្នុងប្រទេសថៃ ហើយត្រូវបានក្រុមគ្រួសារនាំចូលតាមច្រកទ្វារអន្តរជាតិដូង មានចំនួន **៤១**សព ស្រី **០៩**សព។

## ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

នៅក្នុងឆ្នាំ២០២០ គ.ជ.ប.ជ (និង គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ បានជួយផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយរៀបចំបណ្តឹងទាមទារសំណងដល់ជនរងគ្រោះចំនួន៦៥នាក់ សរុបជាទឹកប្រាក់ទទួលសំណងចំនួន ៥២៤,៤៧៦ (ប្រាំរយម្ភៃបួនពាន់ បួនរយចិតសិបប្រាំមួយដុល្លារអាមេរិកគត់) ដែលមានអង្គការដៃគូ សហការគាំទ្រ និងផ្តល់សេវាផ្នែកច្បាប់រួមមាន៖

- អង្គការសម្ព័ន្ធចាប់ដៃ ជនរងគ្រោះចំនួន៣៩នាក់ បានទទួលសាលក្រមប្រកាសសម្រេចផ្តល់ប្រាក់សំណងសរុបចំនួន ១៤៤,២៥០ (មួយរយសែសិបបួនពាន់ ពីររយហាសិបដុល្លារអាមេរិកគត់)។
- អង្គការសកម្មភាពដើម្បីកុមារ (APLE) ជនរងគ្រោះចំនួន ២២នាក់ ទទួលបានសំណងសរុបចំនួន ៩.០០០ (ប្រាំបួនពាន់ដុល្លារអាមេរិកគត់)។
- អង្គការ IJM ជនរងគ្រោះក្នុងរឿងក្តីទូកនេសាទនៅប្រទេសថៃចំនួន០១នាក់ បានទទួលសំណងសរុបចំនួន ៣៥៥.២២៦ (បីរយហាសិបប្រាំពាន់ ពីរយម្ភៃប្រាំមួយដុល្លារអាមេរិកគត់)។
- អង្គការ Hope for Justice ជនរងគ្រោះ ចំនួន ៣នាក់ បានទទួលសំណងសរុបចំនួន ១៦.០០០ (ដប់ប្រាំមួយពាន់ដុល្លារអាមេរិកគត់)។

គ.ជ.ប.ជ ដែលមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្នូលបានសហការសម្របសម្រួល និងជំរុញក្រុមការងារការពារជនរងគ្រោះ ដោយបានសហការជាមួយអង្គការដៃគូពាក់ព័ន្ធគាំទ្រសេវាផ្លូវច្បាប់ដល់ជនរងគ្រោះបានចំនួន ៥៩នាក់ ក្នុងនោះបានផ្តល់សេវាផ្នែកច្បាប់ និងចិត្តសាស្ត្រសង្គមតាមរយៈអង្គការ APLE ៩០នាក់ IJM ៣៣នាក់ CPUកុមារ ០៤នាក់ A21 Foundation ០៦នាក់ជាកុមារី អង្គការមេត្រីអន្តរជាតិ (AIM) កុមារី១៤នាក់ និងអង្គការសម្ព័ន្ធចាប់ដៃ ៣៩នាក់ (បុរស៦នាក់) CWCC កុមារ០១នាក់ ។

**ក្រុមការងារការពារជនរងគ្រោះ** និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន **៣៧១**នាក់(ស្ត្រី៧៦នាក់ កុមារ៤៤នាក់ កុមារី២២៦នាក់) ក្នុងនោះមន្ទីរស.អ.យ រាជធានី ខេត្ត ៧៨នាក់ និងអង្គការដៃគូ ២៩៣នាក់(***ករណីអាជីវកម្មផ្លូវភេទ៧២នាក់ រំលោភបំពានផ្លូវភេទ១៦៨នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម៨៥នាក់ និងករណីងាយរងគ្រោះ២៨នាក់***)។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និយុវនីតិសម្បទា** បានសហការជាមួយ អង្គការ UNICEF និងអង្គការដៃគូ ចំនួន០៩ទៀត(១.អង្គការមិត្តសម្លាញ់ ២.អង្គការសុវត្ថិភាពខ្ញុំ ៣.អង្គការសុខភាពផ្លូវចិត្ត ៤.អង្គការម្លប់តាប៉ាង ៥.អង្គការទំនុកចិត្តកុមារកម្ពុជា ៦.អង្គការកុមាររីករាយ ៧.អង្គការអនាគតកុមារកម្ពុជា ៨.អង្គការតំណក់ទឹក ៩.អង្គការកល្យាណមិត្ត) អនុវត្តន៍កម្មវិធី ភាពជាដៃគូដើម្បីកិច្ចការពារកុមារ បានផ្តល់សេវាការពារ និងសេវាសង្គ្រោះបន្ទាន់ដល់កុមារ សរុបចំនួន **១.៤២៨**នាក់។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរ មូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន ១០៤នាក់ (ស្ត្រី៦៧នាក់ កុមារា២៤នាក់ កុមារី១០នាក់) ក្នុងនោះនាយកដ្ឋាន ១៥នាក់ មន្ទីរស.អ.យ រាជធានី ខេត្ត ៤៤នាក់ និងអង្គការដៃគូ ៤៥នាក់ (*ជាករណីអាពាហ៍ពិពាហ៍ដោយផ្ទុយពីឆន្ទៈបង្ខំ១៨នាក់ ជួញដូរកម្លាំងពលកម្ម៤២នាក់ រំលោភបំពានផ្លូវភេទ ៤៣នាក់*)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការរៀបចំបណ្តុះបណ្តាល

#### ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.ក.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បើកវគ្គបណ្តុះបណ្តាលចំនួន **២៧៨**វគ្គ មានសិក្ខាកាមចូលរួមចំនួន **១២.៦០៣**នាក់ ក្នុងនោះមានស្ត្រី **៣.៧៦៨**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ សមាជិកគ.ក.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងវគ្គបណ្តុះបណ្តាលខាងក្រោម៖

**តារាងវគ្គបណ្តុះបណ្តាល**

ក្រសួង ស្ថាប័ន បានសហការជាមួយអង្គការដៃគូមាន អង្គការ ILO, អង្គការជំនួយផ្លូវច្បាប់ដល់កុមារ (LSCW), អង្គការដែនដីមនុស្សហូឡង់ដ៍(Terre Des Hommes), អង្គការសម្ព័នចាប់ដៃ, អង្គការមូលនិធិកុមារ (Child Fund), អង្គការសកម្មភាពដើម្បីកុមារ(APLE), អង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា, អង្គការវីនរ៉ក់, អង្គការបន្ទាយស្រី, អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC), អង្គការ IOM, អង្គការមូលនិធិអេ២១, អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី, បានបើកវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្ត ស្តីពី៖

- ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទាំងប្រទេស។
- ទេសន្តរប្រវេសន៍ និងសមភាពយេនឌ័រ ដល់អាជ្ញាធរភូមិ/ឃុំ/សង្កាត់ រាជធានី ខេត្ត។
- ការថែទាំសុខភាពកុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាន ដល់លោកគ្រូ អ្នកគ្រូ និងបុគ្គលិកមន្ទីរសុខាភិបាល និងការសង្គ្រោះចិត្តសាស្ត្របឋមរបស់សហគមន៍ជួយដល់ជនរងគ្រោះដោយការជួញដូរមនុស្ស និងជនងាយរងគ្រោះនៅរាជធានី ខេត្ត។
- ជំនាញទន់ គន្លឹះក្នុងការស្វែងរកការងារ និងការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស។
- ច្បាប់ និងបទដ្ឋានគតិយុត្តនានាដល់ប្រតិបត្តិករទេសចរណ៍ វិនិយោគគិន បញ្ជ្រាបនិងផ្សព្វផ្សាយក្នុងការចូលរួមទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទេសចរណ៍ផ្លូវភេទ ដល់មន្ទីរទេសចរណ៍រាជធានី ខេត្ត។
- ប្រព័ន្ធអន្តរជាតិនៃការជ្រើសរើសពលករដោយសុចរិត
- ការពង្រឹងសមត្ថភាពទីភ្នាក់ងារជ្រើសរើសឯកជនក្នុងការជ្រើសរើស ប្រកបដោយក្រមសីលធម៌
- ប្រធានបទពាក់ព័ន្ធនឹងសុវត្ថិភាពអ៊ីនធឺណិត និងកិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។

| ល.រ | សកម្មភាពរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤៤ | ១.០៩៦ | ៩៩ |
| ២ | ក្រសួងអប់រំយុវជន និងកីឡា | ៣៩ | ១.២៨៧ | ០០ |
| ៣ | ក្រសួងកិច្ចការនារី | ១៤ | ៧៨៨ | ៥៦៥ |
| ៤ | អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | ០៤ | ១១០ | ១០ |

| | | | | |
|---|---|---|---|---|
| ៥ | ខេត្តត្បូងឃ្មុំ | ០១ | ៣០ | ០០ |
| ៦ | ខេត្តស្វាយរៀង | ០៧ | ៧៣០ | ៤៧៨ |
| ៧ | ខេត្តកោះកុង | ០១ | ២៤ | ១០ |
| ៨ | ខេត្តកំពង់ឆ្នាំង | ០៨ | ២០៩ | ១៤២ |
| ៩ | ខេត្តកំពង់ធំ | ០៩ | ៥២៣ | ៣៥ |
| ១០ | ខេត្តសៀមរាប | ២១ | ១.៧៣៥ | ៥៤៦ |
| ១១ | ខេត្តព្រះសីហនុ | ០៤ | ២៤៤ | ៧៧ |
| ១២ | ខេត្តកំពត | ០៨ | ៣០២ | ៩៦ |
| ១៣ | ខេត្តកែប | ០៣ | ១៧០ | ១៤០ |
| ១៤ | ខេត្តព្រៃវែង | ០១ | ២០ | ១១ |
| ១៥ | ខេត្តក្រចេះ | ០៣ | ១២០ | ៤១ |
| ១៦ | ខេត្តកំពង់ចាម | ១៨ | ៩៣៣ | ៣១៧ |
| ១៧ | ខេត្តប៉ៃលិន | ០២ | ១០៦ | ៣៧ |
| ១៨ | ខេត្តបាត់ដំបង | ០១ | ៩០ | ០ |
| ១៧ | ខេត្តព្រះវិហារ | ០២ | ៥៧ | ១៧ |
| **សរុប** | | **១៩០** | **៩.១៦៥** | **៣.០៧៣** |
| **ល.រ** | **សកម្មភាពរបស់អង្គការ** | **ចំនួនវគ្គ** | **សិក្ខាកាមសរុប** | **សិក្ខាកាមនារី** |
| ១ | អង្គការ APLE | ១៨ | ៣៩៨ | ១៧០ |
| ២ | អង្គការសម្ព័ន្ធចាប់ដៃ | ៨ | ៤៣៥ | ១៧១ |
| ៣ | អង្គការ ឆាលហ្វាន កម្ពុជា | ១ | ៧៧ | ២៨ |
| ៤ | អង្គការ CARITAS | ៦១ | ៣.១១៩ | ៧៧៨ |
| | **សរុប** | **៨៨** | **៤.០២៩** | **១.១៤៧** |
| | **សរុបរួម** | **២៧៨** | **១២.៦០៣** | **៣.៧៦៨** |

ស្របពេលជាមួយគ្នានេះដែរ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានសហការជាមួយអង្គការ IJM កែសម្រួលសៀវភៅកម្មវិធីជំនាញអាស៊ាន ស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ នៃព្រះរាជាណាចក្រកម្ពុជា និងបោះពុម្ពលើកទីពីរ ជូន រាជបណ្ឌិតសភា ចំនួន ៥០០ ក្បាល។ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ក៏កំពុងសហការជាមួយអង្គការ IJM ផងដែរក្នុងការចងក្រងសៀវភៅករណីសិក្សាបំពេញបន្ថែមលើកម្មវិធីជំនាញអាស៊ាន ស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសគ្រូបង្គោល ដើម្បីបណ្តុះបណ្តាលសិស្សចៅក្រម ជំនាន់បន្ទាប់។

## ក.២. សិក្ខាសាលា

### ក.២.១.សិក្ខាសាលាក្នុងប្រទេស

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អន្តរក្រសួង ស្ថាប័ន អង្គការដៃគូ** បានសហការគ្នា និងរៀបចំសិក្ខាសាលា ពាក់ព័ន្ធនឹងការបង្ការ ទប់ស្កាត់ ការធ្វើចំណាកស្រុកដោយសុវត្ថិភាពការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ពិសេសលើស្ត្រី និងកុមារ នៅទូទាំងប្រទេសបានចំនួន **១២៥**លើក មានសិក្ខាកាមសរុបចំនួន **៦.៤១៦**នាក់ ស្រី **៣៩៥**នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **០៧**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៥លើក ក្រសួងអប់រំយុវជន និងកីឡា

**០៥**លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **៩៩**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត និងអង្គការដៃគូ **០៩**លើក។ (**ឧបសម្ព័ន្ធ ២**)

### ក.២.២. សិក្ខាសាលាក្រៅប្រទេស

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** បានចូលរួមសិក្ខាសាលាអ្នកគោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ ដើម្បីដោះស្រាយតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ ។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. សន្និសីទ កិច្ចប្រជុំ ក្នុងប្រទេស និងក្រៅប្រទេស

#### ➢ កិច្ចប្រជុំក្នុងប្រទេស

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អន្តរក្រសួង ស្ថាប័ន អង្គការដៃគូ បានសហការគ្នា និងរៀបចំកិច្ចប្រជុំ ពាក់ព័ន្ធនឹងការបង្ការ ទប់ស្កាត់ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ពិសេសលើស្ត្រី និងកុមារ នៅទូទាំងប្រទេសបានចំនួន **៤៧៦**លើក មានអ្នកចូលរួមសរុបចំនួន **១៥.០៩៧**នាក់ ស្រី **៧.៥៦១**នាក់ ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **៧៣**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **១៤**លើក ក្រសួងអប់រំយុវជន និងកីឡា **០៣**លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **០១**លើក ក្រសួងធម្មការ និងសាសនា **០១**លើក ក្រសួងកិច្ចការនារី **០៤**លើក ក្រសួងព័ត៌មាន **០១**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត **៣៧៩**លើក។(**ឧបសម្ព័ន្ធ ៣**)

#### ➢ កិច្ចប្រជុំក្រៅប្រទេស

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានរៀបចំកិច្ចប្រជុំ
  - ថ្នាក់រដ្ឋមន្ត្រីការងារអាស៊ានលើកទី២៦ (26th ALMM) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការងារអាស៊ាន+៣ (សាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន និងសាធារណរដ្ឋកូរ៉េ) លើកទី១១ ក្រោមប្រធានបទ "ការលើកកម្ពស់កម្មករនិយោជិតអាស៊ាន ដើម្បីភាពប្រកួតប្រជែង ភាពធន់ និងភាពបត់បែន សម្រាប់អនាគតនៃការងារ" តាមប្រព័ន្ធវីដេអូ។ កិច្ចប្រជុំនេះបានអនុម័តលើឯកសារសំខាន់ៗមួយចំនួនរួមមាន៖ ១-បច្ចុប្បន្នភាពផែនការសកម្មភាព(ឆ្នាំ២០១៨-២០២៥) នៃឯកច្ឆន្ទភាពអាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តប្រវេសន៍។ ២-ផែនទីបង្ហាញផ្លូវអាស៊ាន ដើម្បីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារត្រឹមឆ្នាំ២០២៥។ ៣-គោលការណ៍ណែនាំ អាស៊ានស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយមុខរបរ និងការងារ ឆ្ពោះទៅរកការងារសមរម្យសម្រាប់ទាំងអស់គ្នា។ ៤-គោលការណ៍ណែនាំអាស៊ាន ស្តីពីការវិលត្រឡប់ និងការធ្វើ សមាហរណកម្មប្រកបដោយប្រសិទ្ធភាពរបស់ពលករទេសន្តប្រវេសន៍។
  - ថ្នាក់រដ្ឋមន្ត្រីការងារកម្ពុជា-ថៃ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងកិច្ចព្រមព្រៀង ស្តីពីការប្រើប្រាស់កម្លាំងពលកម្មក្នុងអំឡុងការរីករាលដាលជំងឺកូវីដ-១៩ តាមប្រព័ន្ធវីដេអូ។ កិច្ចប្រជុំផ្តោតសំខាន់លើ៖ ១.ការបន្តកិច្ចសន្យាការងាររយៈពេល ២ ឆ្នាំបន្ថែមទៀត ចំពោះពលករដែលបានបញ្ជូនតាមរយៈអនុស្សរណៈ នៃការយោគយល់គ្នា ហើយត្រូវបញ្ចប់កិច្ចសន្យាការងាររយៈពេល ៤ឆ្នាំ ចាប់ពីនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ការរីករាលដាលជំងឺកូវីដ-១៩ អាចគ្រប់គ្រងបាន។ ២.ការបញ្ជូន និងទទួលពលករកម្ពុជាទៅធ្វើការតាមរផ្លូវនៅតាមខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។ ៣.ការបន្តសុពលភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស(TD) ជូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលបញ្ចប់

កិច្ចសន្យាការងាររយៈពេល ៤ឆ្នាំ។ ៤.ការបញ្ជូន និងទទួលពលករកម្ពុជាថ្មីទៅធ្វើការនៅប្រទេសថៃ តាមរយៈអនុស្សរណៈនៃការយោគយល់គ្នាក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ-១៩។

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** លោកជំទាវ ឧត្តមសេនីយ៍ទោ **វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មសារជាថ្មី (TEG-RR) ដែលរៀបចំដោយសហប្រធានអូស្ត្រាលី និងស្រីលង្កា ក្រុមជំនាញបច្ចេកទេសរបស់ Bali Process នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា។

## ខ.២. ការទទួលជួបពិភាក្សាការងារ

- **ថ្នាក់ជាតិ**
  - **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារ៖
  - ជាមួយទីប្រឹក្សាការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ (UNOHCHR)ប្រចាំកម្ពុជា ដោយផ្តោតសំខាន់ទៅលើកិច្ចសហប្រតិបត្តិការ ជាមួយកម្ពុជា លើបញ្ហាយេនឌ័រ និងសិទ្ធិស្ត្រី រយៈពេលពេញមួយឆ្នាំ។
  - ជាមួយតំណាងអង្គការឃែរ (CARE) លើគម្រោងស្រាវជ្រាវស្តីពី ចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រជាពលរដ្ឋ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - ចែករំលែកបទពិសោធន៍ការងារ រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងតំណាងអង្គការ IJM Cambodia នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - ជាមួយលោក B.Subba Rao លេខាទី២ តំណាងស្ថានទូតឥណ្ឌាប្រចាំ ប្រទេសកម្ពុជា អំពី MOU (កម្ពុជា-ឥណ្ឌា) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - និងបានដឹកនាំតំណាងគណៈប្រតិភូ ដែលអញ្ជើញមកពីប្រទេសឡាវ មីយ៉ាន់ម៉ា វៀតណាម និងអង្គការ IOM ចូលជួបសំដែងការគួរសមជាមួយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** និងរាយការណ៍អំពីលទ្ធផល នៃអង្គសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ ដែលប្រារព្ធធ្វើអស់រយៈពេលពីរថ្ងៃកន្លងមក ស្តីពី"**ការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេសបញ្ជូន**" (កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម) នៅទីស្តីការក្រសួងមហាផ្ទៃ។
  - និងជួបសំណេះសំណាលការងារជាមួយប្រធាន និងក្រុមការងារ របស់អង្គការអែម(AIM) និងទទួលបាននូវការឧបត្ថម្ភនូវអង្ករ និងសម្ភារបរិក្ខាមួយចំនួន សម្រាប់ប្រើប្រាស់ និងផ្គត់ផ្គង់នៅមណ្ឌលសំចតទទួលពលករដែលត្រលប់មកពីក្រៅប្រទេស ជាពិសេសក្នុងយុទ្ធនាការទប់ស្កាត់ជំងឺកូវីដ-១៩ នេះ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
  - ជាមួយតំណាងស្ថានទូតអាមេរិក និងUSAID អំពីលទ្ធភាពនៃការជួយ គាំទ្ររបស់សហរដ្ឋអាមេរិកក្នុងការលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការឆ្លើយតបទៅនឹងការស្តារ និងលើកកម្ពស់ចំណាត់ថ្នាក់នៅឆ្នាំបន្តបន្ទាប់ ដើម្បីសម្រេចបានលទ្ធផលល្អប្រសើរក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា នៅសាលប្រជុំ គ.ជ.ប.ជ។
  - ជាមួយអង្គការសម្ព័ន្ធចាប់ដៃ ដើម្បីពិភាក្សាការងារក្នុងការរៀបចំសិក្ខាសាលា នៅសាលប្រជុំ គ.ជ.ប.ជ។

- ជាមួយអង្គការ IOM ដើម្បីចុះតាមដាន ត្រួតពិនិត្យផែនការសកម្មភាព ក្នុងការអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ នៅស្រុកកំរៀង ខេត្តបាត់ដំបង និងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។
- ជាមួយតំណាងអង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ស្តីពីការធ្វើចំណាកស្រុក ការជួញដូរមនុស្ស និងបញ្ហាសុខភាព របស់ប្រជាជន នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។
- ពាក់ព័ន្ធបញ្ហាកតិកាសញ្ញាសកល ស្តីពីការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ (Global Compact for Migration (GCM)) រវាង ថ្នាក់ដឹកនាំអគ្គ លេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយនឹងប្រធានអង្គការ IOM ។
- តាមប្រព័ន្ធអនឡាញ (Online) ជាមួយតំណាងអង្គការនានា ដែលមាន បេសកកម្មក្នុងសហគមន៍អាស៊ាន ស្តីពីកិច្ចគាំពារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការផ្តល់សេវាសមស្រប រវាងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដឹកនាំនិងធ្វើបទបង្ហាញ ដោយលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាតំណាងខាងកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ តំណាងអង្គការវីនរ៉ក់អន្តរជាតិ ឯកឧត្តម អគ្គលេខាធិការរង ប្រធាន និងអនុប្រធាន នៃក្រុមជំនួយកិច្ចការ ជួយជនរងគ្រោះ ទេសន្តរប្រវេសន៍ បង្ការទប់ស្កាត់ សហប្រតិបត្តិការជាតិ អន្តរជាតិ។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

-លោកជំទាវវេជ្ជបណ្ឌិត ឧត្តមសេនីយ៍ឯក **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានទទួលជួបពិក្សាការងារជាមួយក្រុមអ្នកស្រាវជ្រាវមកពីសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា អំពីការសិក្សា ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅក្នុងប្រទេសកម្ពុជា។

• **ថ្នាក់ក្រោមជាតិ**

▪ **ខេត្តកែប៖** លោកឧត្តមសេនីយ៍ត្រី **បែន តារា** ស្នងការដ្ឋាននគរបាលខេត្ត បានដឹកនាំស្នងការរងទទួលផែនព្រហ្មទណ្ឌ ផែនប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងប្រធានការិយាល័យជំនាញ ជួបពិភាក្សាការងារជាមួយអង្គការ ការពារកុមារ ដែលដឹកនាំដោយលោក **ម៉ាយ ស៊ីត** ប្រធានផ្នែកស៊ើបអង្កេតរបស់អង្គការ Child Protection Unit (CPU) នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តកែប។

▪ **ខេត្តកណ្តាល៖** លោកជំទាវ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយ៖ ១.តំណាងអង្គការដើម្បីកុមារ(APLE) ស្តីពីការចូលរួមលើកកម្ពស់ចំណេះដឹង និងអនុវត្តផែនការថ្នាក់ជាតិក្នុងកិច្ចការ បង្ការ ការពារ និងឆ្លើយតបនឹងអំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ២.តំណាងអង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ ស្តីពីការអនុវត្តគម្រោងចំណាកស្រុកដោយសុវត្ថិភាព និងកាត់បន្ថយអំពើជួញដូរមនុស្ស ដែលផ្តោតសំខាន់លើទម្រង់នៃការកេងប្រវ័ញ្ចលើស្ត្រី ដើម្បីឱ្យពួកគេធ្វើចំណាកស្រុកដោយសុវត្ថិភាព និងទទួលបានសេវាសមស្រប។

▪ **ខេត្តកំពង់ចាម៖** ១-លោកជំទាវ ប៉ាង ដានី អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន បានជួបពិភាក្សាការងារជាមួយអង្គការជំនួយផ្នែកច្បាប់ដល់កុមារ និងស្ត្រី ដោយផ្តោតលើការងាររបស់ពលករធ្វើការលើទូកនេសាទនៅប្រទេសថៃ។ ២-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ទទួលជួបពិភាក្សាជាមួយតំណាងអង្គការពលកម្មអន្តរជាតិ(ILO) ស្តីពីបញ្ហាប្រឈមរបស់ពលករ ដែលបានធ្វើមាតុភូមិនិវត្តន៍ត្រលប់មកវិញ និងការគ្រប់គ្រងស្ថិតិពលករតាមមូលដ្ឋាន។

### ខ.៣.ការងារទស្សនកិច្ច

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
  - លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានធ្វើទស្សនកិច្ចដើម្បីសិក្សាស្វែងយល់ក្នុងវគ្គបណ្តុះបណ្តាល ស្តីពី ***"ភាពជាអ្នកដឹកនាំសកល"*** នៅទីក្រុង YAMAGUEHI និងទីក្រុង SEMONOSEKI ប្រទេសជប៉ុន មានសិក្ខាកាមជានារីសរុប **៣៦**នាក់។

### ខ.៤. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៥៣០**លើក មានអ្នកចូលរួមសរុប **១២.៦៤០**នាក់ (ស្រី **៥០៥**នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **១៥០**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **៧១**លើក ក្រសួងអប់រំយុវជន និងកីឡា **១៤**លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **០៩**លើក ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**០២**លើក ក្រសួងព័ត៌មាន**០៤**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត **២៨០**លើក។ **(ឧបសម្ព័ន្ធ ៤)**

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាធ្លុងមួយក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្ស ជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិ ផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួន នៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងរំលេចឱ្យឃើញពីសមិទ្ធផលសំខាន់ៗស្តីពីសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស។
- មន្ត្រីយើងមួយចំនួននៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ គ្រប់គ្រាន់ និងទាន់ពេលវេលា រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ គ្រប់គ្រាន់ និងទាន់ពេលវេលាជាប្រចាំ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- បើកវគ្គបណ្តុះបណ្តាលជំនាញដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីសារៈសំខាន់នៃការផ្ញើរបាយការណ៍ និងឱ្យមានជំនាញផ្នែកសរសេររបាយការណ៍ដែលអាចឆ្លុះបញ្ចាំងបានគ្រប់ជ្រុងជ្រោយនិងរំលេចនូវសកម្មភាព និងសមិទ្ធផលសំខាន់ៗក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើជួញដូរមនុស្ស។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន នោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងកាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅ ឆ្នាំ ២០២១

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

### ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

ក.១.គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ដើម្បីបន្តពិគ្រោះយោបល់ និងពិនិត្យឡើងវិញខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីអំពើពពោះជំនួស។

ក.៣.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសកិច្ចសហការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ ។

ក.៤.បន្តពង្រឹង និងជំរុញការអនុវត្ត អនុស្សរណៈ កិច្ចព្រមព្រៀង ស្តង់ដារនៃនីតិវិធីប្រតិបត្តិ ដែលមានស្រាប់ជាមួយបណ្តាប្រទេស និងដៃគូពាក់ព័ន្ធ។

ក.៥. ត្រៀមចុះហត្ថលេខាលើស្តង់ដារនៃនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាង រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការអនុវត្តច្បាប់។

ក.៦.ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍របស់ក្រសួងសុខាភិបាល។

ក.៧.រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីកសាងបទដ្ឋានគតិយុត្តិនានា សម្រាប់ការពារសិទ្ធិ សុវត្ថិភាព ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទសមុទ្រ។

ក.៨.ត្រៀមកិច្ចប្រជុំបួនប្រទេស កម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ក្នុងការពង្រឹងកិច្ចសហការ ការពារ និងបង្ការ ទប់ស្កាត់ ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសស្ត្រី និងកុមារ ក៏ដូចជាទារក។

ក.៩.ត្រៀមបន្តចុះហត្ថលេខាអនុស្សរណៈ និងកិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធ។

### ខ. ការងារបង្ការ ទប់ស្កាត់

ខ.១.សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំយុទ្ធនាការ "គាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម"។

ខ.២.ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សៀវភៅសិក្សាអប់រំស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន" សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីសិក្សាកម្រិត បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

ខ.៣.ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ធ្វើការបោះពុម្ពសៀវភៅសិក្សាអប់រំស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន" និងបើកវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ គ្រូឧទ្ទេសគរុកោសល្យភូមិភាគ និងគ្រូបង្គោល តាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ នៅទូទាំងប្រទេស។

ខ.៤.សហការជាមួយអង្គការដៃគូ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីកវិធានការទប់ស្កាត់អំពើរំលោភបំពានគ្រប់ទម្រង់លើកុមារ។

ខ.៥.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដើម្បីជំរុញ និងពង្រីកការផ្សព្វផ្សាយអំពី ឱកាសការងារឱ្យកាន់តែទូលំទូលាយ នៅតាមសហគមន៍ ជាពិសេសសហគមន៍ដែលងាយរងគ្រោះ រួមទាំងពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់។

ខ.៦.សហការជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតនីតិវិធីងាយស្រួលក្នុងការផ្សារភ្ជាប់ទំនាក់ទំនង និងការទទួលបានការប្រឹក្សាយោបល់ពីទីភ្នាក់ងារជាតិមុខរបរ និងការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីជម្រើសការងារ ឬមុខរបរ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្សេងៗ សម្រាប់ក្រុមជនងាយរងគ្រោះ ជាពិសេស ពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់ពីបរទេស។

ខ.៧.បន្តជំរុញការគ្រប់គ្រង និងធ្វើអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីធានាការអនុវត្តគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារ ក្នុងការការពារសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់ពលករក្នុងការធ្វើទេសន្តរប្រវេសន៍ការងារ។

ខ.៨.បន្តរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ និងវេទិកាជាតិអន្តរសាសនានៅកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ខ.៩.បន្តសហការជាមួយអង្គការសហប្រជាជាតិ (IOM, WHO, UNFPA, UNICEF) និងដៃគូផ្សេងៗទៀត ដើម្បីរៀបចំកម្មវិធី ឆ្លើយតបទៅនឹងផលប៉ះពាល់លើសុខភាព និងជីវភាព ពលករទេសន្តរប្រវេសន៍ និងគ្រួសារ ក្នុងស្ថានភាពនៃការរាតត្បាតដោយជំងឺកូវីដ ១៩ និងគ្រោះមហន្តរាយផ្សេងៗទៀត។

ខ.១០.បន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ការផ្សព្វផ្សាយអំពីការបង្ការ ទប់ស្កាត់ ការឆ្លង និងចម្លងជំងឺកូវីដ ១៩ និងផលប៉ះពាល់ ព្រមទាំងចុះតាមដានការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ។

ខ.១១.បន្តលើកកម្ពស់ការងារផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងពង្រីកការអប់រំតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយ អំពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ទំនាក់ទំនង រវាងទេសន្តរប្រវេសន៍និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងនិងក្រៅសាលារៀន និងជនងាយរងគ្រោះដទៃទៀត។

ខ.១២.បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ដើម្បីកំណត់រកអំពើកេងប្រវ័ញ្ចផ្សេងៗ និងមានវិធានការ ក្នុងប្រភេទការងារដែលមានភាពរងគ្រោះខ្ពស់ ដូចជានៅតាមរោងចក្រសហគ្រាស សហគ្រាសឡឥដ្ឋ កសិដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ កន្លែងសេវាកម្សាន្ត ជាដើម។

ខ.១៣.បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ចំពោះទីភ្នាក់ងារជ្រើសរើសពលករឯកជន។

ខ.១៤.លើកកម្ពស់ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងការអនុវត្តក្រមសីលធម៌ របស់ទីភ្នាក់ងារ និងកាត់បន្ថយការយកថ្លៃឈ្នួលពីពលករ ក្នុងនីតិវិធីនៃការជ្រើសរើសពលករទេសន្តរប្រវេសន៍។

ខ.១៥.បន្តរៀបចំផែនការអនុវត្តគោលបំណងអាទិភាព GCM និងអនុសញ្ញាអាស៊ាន ។

## គ. ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ

គ.១.បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

គ.២.បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោស បទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ។

គ.៣.បន្តពង្រឹងកិច្ចសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេតប្រមូលភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសជួញដូរមនុស្ស។

គ.៤.បន្តពង្រឹងកិច្ចសហការជាមួយសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន។

គ.៥.ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

## ឃ. ការខារការពារជនរងគ្រោះ

ឃ.១.ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករ នៅក្នុងវដ្តនៃទេសន្តរប្រវេសន៍ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយ និងវិធានការសម្រាប់ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ជាពិសេស ដើម្បីផ្តល់សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ដោយអាជ្ញាធរបរទេស និងពលករដែលវិលត្រឡប់ ពីប្រទេសគោលដៅតាមច្រកព្រំដែនសំខាន់ៗ។

ឃ.២.សហការជាមួយអង្គការការីតាសស្វីស និងរដ្ឋបាល ខេត្តបាត់ដំបង សាងសង់ និងដាក់ឱ្យដំណើរការមណ្ឌលទទួលពលករ នៅស្រុកកំរៀង ។

ឃ.៣.រៀបចំយន្តការសម្រាប់ការទទួលពលករ និងការគ្រប់គ្រង និងដំណើរការមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង ដោយមានកិច្ចសហការពីបណ្តា ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ពាក់ព័ន្ធ និងអង្គការដៃគូ ក្នុងការផ្តល់សេវា។

ឃ.៤.រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ ក្នុងទេសន្តរប្រវេសន៍ ពីអំពើជួញដូរមនុស្ស និងការរំលោភបំពាន ។

ឃ.៥.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ៖

- គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- គោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ដល់មន្ត្រីជួរមុខ។
- កម្មវិធីគ្រប់គ្រងករណីដល់មន្ត្រីដែលអនុវត្ត និងអ្នកពាក់ព័ន្ធទាំង២៥ រាជធានី ខេត្ត។

ឃ.៦.ធ្វើបច្ចុប្បន្នលើសារាចរ ស្តីពី នីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស(SOPs) រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

ឃ.៧.បន្តកិច្ចសហប្រតិបត្តិការជាមួយ៖

-ក្រសួងយុត្តិធម៌ដើម្បីរៀបចំឱ្យមានមន្ត្រីសង្គមកិច្ចចូលរួមក្នុងប្រព័ន្ធតុលាការ នៅតាមសាលាដំបូង រាជធានី ខេត្ត។

-ក្រសួងសុខាភិបាល ក្នុងការជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទទួលបានសេវាពិនិត្យសុខភាព និងការព្យាបាលដោយឥតគិតថ្លៃ នៅតាមមជ្ឈមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ។

-ស្ថានទូត និងកុងស៊ុល នៅក្រៅប្រទេស(តាមរយៈក្រសួងការបរទេស) ដើម្បីជួយដល់ជនរងគ្រោះ និងសម្រួលដល់ដំណើរការមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាឱ្យបានឆាប់រហ័ស និងមានសុវត្ថិភាព។

-ក្រសួងស្ថាប័ន និងអង្គការដៃគូ ដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

-មន្ត្រីថ្នាក់ក្រោមជាតិ ក្នុងដំណើរការស្វែងរក ប៉ាន់ប្រមាណគ្រួសារ តាមដាន សមាហរណកម្ម និងបិទករណីរបស់ជនរងគ្រោះ។

-ភាគីថៃសម្រាប់ដំណើរការកសាងមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

ឃ.៨.បន្តចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ឃ.៩.ពិនិត្យលទ្ធភាពដើម្បីបង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះជារបស់រដ្ឋ។

ឃ.១០.គាំទ្រក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធនៅក្នុងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសគោលដៅ អំពីគោលការណ៍ណែនាំ ស្តីពី

បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

ឃ.១១.រៀបចំឧបករណ៍វាយតម្លៃអំពី ភាពប្រឈម និងមេរៀនទទួលបាន នៃ«ការអនុវត្តនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ក្នុងខេត្តដែលបានបណ្តុះបណ្តាលរួចហើយ ។

ឃ.១២.រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការផ្តល់សេវា ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស នៅតាមមណ្ឌល និងនៅតាមសហគមន៍ ។

## ង.ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ

ង.១.ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន ការងាររបាយការណ៍ ការកសាងផែនការ និងការងារត្រួតពិនិត្យ វាយតម្លៃ។

ង.២.ធ្វើការប៉ាន់ប្រមាណ និងវាយតម្លៃ ពាក់កណ្តាលអាណត្តិ ទៅលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ង.៣.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំយន្តការប្រមូលទិន្នន័យថ្នាក់ជាតិ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសទិន្នន័យនៃការអនុវត្តច្បាប់ ការផ្តន្ទាទោស និងការងារការពារជនរងគ្រោះឱ្យមានសង្គតិភាព។

ង.៤.គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រងគ្រប់ផ្នែក ដល់មន្ត្រីជំនាញក្នុងក្រុមការងារ និង លេខាធិការដ្ឋានរាជធានី-ខេត្ត ដើម្បីពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ង.៥.បន្តធ្វើសេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការរាជធានី ខេត្ត ។

ង.៦.រៀបចំប្រព័ន្ធប្រមូល ចងក្រង និងចែកចាយទិន្នន័យ តាមផ្នែកពាក់ព័ន្ធសំខាន់ៗ ។

ថ្ងៃ ព្រហស្បតិ៍ ៥កើត ខែចេត្រ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៥៣០លើក) មនុស្សចំនួន ១២.៦៤០នាក់ (ស្រី ៥០៥នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | គ.ប.ជ.ប សម្របសម្រួលបានចំនួន ១៥០លើក អ្នកចូលរួមចំនួន ១.១៤៤នាក់ (ស្រី ១១០នាក់)<br>▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>១.ដឹកនាំគណៈប្រតិភូចុះសួរសុខទុក្ខ និងនាំយកនូវថវិកាមួយចំនួនជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋរងគ្រោះ ព្រមទាំងក្រុមគ្រូពេទ្យដែលប្រចាំការពិនិត្យថែជនរងគ្រោះដោយគ្រោះថ្នាក់រលំបាក់អគារ៦ជាន់នៅខេត្តកែប ហើយកំពុងសម្រាកព្យាបាលក្នុងមន្ទីរពេទ្យបង្អែកខេត្ត។ ២.ជាអធិបតីភាព ក្នុងកិច្ចប្រជុំពិភាក្សារបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ ជាមួយអង្គការដៃគូ នៅសាលប្រជុំអគ្គលេខា ធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមចំនួន **៣៥**រូប។ ៣.ចូលរួម និងថ្លែងសុន្ទរកថាក្នុងពិធីសម្ពោធជាផ្លូវការនូវគម្រោង Grab for Good គាំទ្រមនុស្សគថ្លង់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម ទេស រដ្ឋមន្ត្រី **ស៊ិន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន។ ៤.ជាអធិបតីភាព ក្នុងពិធីប្រកាសសេចក្តីសម្រេចអំពីការកែប្រែសមាសភាពក្រុមការងារយេនឌ័ររបស់លេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ក្នុងការអនុវត្តតួនាទី ភារកិច្ច នៅទីស្តីការក្រសួងមហាផ្ទៃ អាគារទេ។ ៥.ចូលរួមក្នុងពិធីផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់នូវក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **អិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមការងារទេសន្តរប្រវេសន៍។ ៦.ចូលរួមក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានអ្នកចូលរួមចំនួន **១៨៣**នាក់ ស្រី **៦០**នាក់ នៅសណ្ឋាគារភ្នំពេញ។ **៧.**ដឹកនាំក្រុមការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សហការជាមួយអង្គការដៃគូអភិវឌ្ឍ ការីតាសស្វីស និងIOM ក្រុមការងារសាលាស្រុកកំរៀង មន្ត្រីបច្ចេកទេសផ្នែកសាងសង់ បានចុះពិនិត្យ និងសិក្សាពីស្ថានភាពដីសម្រាប់សាងសង់មណ្ឌលសំចតពលករ ស្ថិតនៅជិតច្រកដូង ភូមិបឹងរាំង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ៨.ដឹកនាំក្រុមការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចុះសួរសុខទុក្ខនៅទីកន្លែងចត្តាឡីស័កស្រុកមាល័យនិងកន្លែងទទួលពលករនៅច្រកដូង និងបានជួបប្រជុំជាមួយគណៈបញ្ជាការឯកភាពស្រុកកំរៀង ពាក់ព័ន្ធពីផែនការនៃគម្រោងសាងសង់មណ្ឌលទទួលពលករប្រចាំច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង។ ៩.ក្នុងពិធីប្រគល់ និងទទួលសម្ភារប្រើប្រាស់ចាំបាច់សម្រាប់ ស្ត្រី និងកុមារ ក្នុងស្ថានភាពប្រឈមនឹងជម្ងឺកូវីដ-១៩ ពីអង្គការ UNFPA Cambodia នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ១០.ក្នុងពិធីប្រគល់ និងទទួលសម្ភារប្រើប្រាស់ក្នុងស្ថានភាពប្រឈមនឹងជម្ងឺកូវីដ-១៩ ពីអង្គការ ការិតាស់ កម្ពុជា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ១១.ជាអធិបតីភាព ក្នុងកិច្ចប្រជុំពិភាក្សាស្តីពី សេចក្តីព្រាងខ្លឹមសារអនុស្សរណៈ នៃការយោគយល់គ្នា រវាងមូលនីធិA២១ និងការប្រគល់ទទួលអំណោយជាអង្ករ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ **១២.**ជាអធិបតី ក្នុងកិច្ចប្រជុំស្តីពី ផែនការសកម្មភាពនៃកិច្ចសហការក្នុងការបង្ការជំងឺកូវីដ ១៩ ដល់ពលករចំណាក |

ស្រុកដែលងាយរងគ្រោះ និងក្នុងសហគមន៍ រវាងអង្គការដែលឋិតក្រោមអង្គការសហប្រជាជាតិ មានអង្គការយូនីសេហ្វ WHO IOM UNFPA ជាមួយនឹងលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ **១៣**.ចូលរួមជាអធិបតីក្នុងកិច្ចប្រជុំពិភាក្សា អំពីគម្រោងកម្មវិធី ការពារពលករទេសន្តប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ និងសហគមន៍ ពីហានីភយ័ឆ្លងជំងឺកូវីដ ១៩ ទ្រង់ទ្រាយធំ និងការផ្ដល់សេវាចាំបាច់នានានៅមូលដ្ឋាន នៅទីស្ដីការក្រសួងមហាផ្ទៃ អគារទ។ **១៤**.ចូលរួមជាអធិបតីបើកកិច្ចប្រជុំស្ដីពី សេចក្ដីប្រកាសរបស់ប្រទេសកាណាដា ទទួលសំណើគម្រោងអាស៊ាន ក្រោមមូលនិធិអាស៊ាន កាណាដា-សម្រាប់ផ្ដួចផ្ដើមថ្នាក់មូលដ្ឋានឆ្នាំ២០២០-២០២១ ស្ដីពី ការរៀបចំឯកសារលើគម្រោងក្នុងមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ ឡាងឆាង (SC-MLC) សម្រាប់ឆ្នាំ២០២១ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។ **១៥**.ដឹកនាំក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន សហការជាមួយអង្គការ UNFPA និងអង្គការ IOM បានចុះជួបសំណេះសំណាលស្ដីពី ការឆ្លើយតបនឹងវិបត្តិ កូវីដ១៩ របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់សម្ភារប្រើប្រាស់មួយចំនួនដល់ប្រជាពលរដ្ឋ១០០គ្រួសារ នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង។ **១៦**.ដឹកនាំក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន ក្រុមសមាគមឯកជនចិន បានចុះជួបសំណេះសំណាលស្ដីពី ការឆ្លើយតបនឹងវិបត្តិកូវីដ ១៩ របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់សម្ភារប្រើប្រាស់មួយចំនួនដល់ពលរដ្ឋប្រមាណ៥០គ្រួសារ នៅក្រុងកំពង់ឆ្នាំង។ **១៧**.ដឹកនាំក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន រួមនឹងអង្គការ UNFPA និង IOM ចុះជួបសំណេះសំណាលស្ដីពី ការឆ្លើយតបនឹងវិបត្តិកូវីដ១៩ របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់សម្ភារប្រើប្រាស់មួយចំនួនដល់ប្រជាពលរដ្ឋចំនួន១០០គ្រួសារ នៅស្រុកកំរៀង ខេត្តបាត់ដំបង។ **១៨**.ចូលរួមកិច្ចប្រជុំពិនិត្យ និងផ្ដល់យោបល់ទៅលើខ្លឹមសារ សេចក្ដីព្រាងសៀវភៅការអប់រំ និងលំនាំ នៃការបង្រៀន ស្ដីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់ថ្នាក់បឋម និងមធ្យមសិក្សា ទាំងរដ្ឋ និងឯកជន នៅសាលប្រជុំគ.ជ.ប.ជ មានអ្នកចូលរួម១៥នាក់ ស្រី០៣នាក់។ **១៩**.ដឹកនាំកិច្ចប្រជុំពិភាក្សាលើសេចក្ដីសម្រេចស្ដីពីការបង្កើត "មណ្ឌលទទួលពលករចំណាកស្រុក ប្រកដួង" នៅសាលប្រជុំ គ.ជ.ប.ជ អ្នកចូលរួមចំនួន ១៨នាក់ ស្រី០៤នាក់ ។ **២០**.ដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមការងារអង្គការ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ចុះសួរសុខទុក្ខ និងចុះសិក្សានៅតំបន់ជាប់ព្រំដែន នៃស្រុកសៀមប៉ាង និងស្រុកឆែប ខេត្តព្រះវិហារ អំពីស្ថានភាពចំណាកស្រុកឆ្លងដែន ការជួញដូរមនុស្ស និងបញ្ហាសុខភាពរបស់ប្រជាជន។ **២១**.ជាអធិបតីភាព ក្នុងវេទិកាសាធារណៈដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ចំនួន០៤លើក ដោយមានការចូលរួមពីក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានក្រុង អភិបាលរងខេត្ត អភិបាលរងក្រុង តំណាងមន្ទីរនានា អាជ្ញាធរ ដែនដីមានសមត្ថកិច្ច ស្នងការរងនគរបាល មេបញ្ជាការរងរាជអាវុធហត្ថស្រុក ក្រុមប្រឹក្សាខុំ សង្កាត់ មន្ត្រីពាក់ព័ន្ធ និងប្រជាពលរដ្ឋ ក្នុងសង្កាត់កំពង់ឆ្នាំងចំនួន១០០នាក់ សង្កាត់ ប្អេរចំនួន៥៦នាក់ សង្កាត់ផ្សារឆ្នាំងចំនួន៦៦នាក់ និងសង្កាត់ខ្សាមចំនួន៦៨នាក់ ខេត្តកំពង់ឆ្នាំង។

- លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖

១.សិក្ខាសាលាស្ដីពីវឌ្ឍនភាព នៃការអនុវត្តផែនការយុទ្ធសាស្ត្រទប់ស្កាត់អំពើជួញដូរមនុស្ស និងគ្រោះថ្នាក់បង្កដោយការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ក្រោមអធិបតីភាព ឯកឧត្តម **ស សុខា** រដ្ឋលេខាធិការ ក្រសួងអប់រំយុវជន និងកីឡា មានអ្នកចូលរួមមាន **១៦៥**នាក់ ស្រី **២៧**នាក់។ ២.វគ្គ" បណ្ដុះបណ្ដាលភាពជាថ្នាក់ដឹកនាំសាកល" នៅទីក្រុង Semonoseki ប្រទេសជប៉ុន មានសិក្ខាកាមចូលរួមចំនួន **៣៦**នាក់។ ៣.ដឹកនាំកិច្ចប្រជុំពិភាក្សា ស្ដីពីកិច្ចការពារជនរងគ្រោះ និងការអនុវត្តច្បាប់

| | |
|---|---|
| | ជាមួយអង្គការចាប់ដៃ អ្នកចូលរួមចំនួន០៨នាក់ ស្រី០២នាក់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៤.ដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការត្រួតពិនិត្យការងាររបាយការណ៍ឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ ដើម្បីត្រៀមធ្វើសន្និបាតរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ៥.ដឹកនាំកិច្ចប្រជុំស្តីពីការ ប្តូរសុបស្ថិតិប្រជាពលរដ្ឋវិលត្រលប់មកពីក្រៅប្រទេស មានការអញ្ជើញចូលរួមពី ឯកឧត្តម អគ្គលេខាធិការរង និងក្រុមការងារជួយជនរងគ្រោះ នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ ៦.កិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុកក្នុងស្ថានភាពនៃជំងឺកូវីដ-១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅសាលប្រជុំក្រសួងមហាផ្ទៃ។ ៧.កិច្ចប្រជុំស្តីពី កិច្ចសហការក្នុងការឆ្លើយតបនឹងវិបត្តិកូវីដ ១៩ ក្នុងចំណោមពលករចំណាកស្រុក និងសហគមន៍ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជនៅទីស្តីការក្រសួងមហាផ្ទៃ អ្នកចូលរួមមាន**៧២**នាក់ ស្រី**២៦**នាក់។ ៨.ទទួលជួបសំណេះសំណាលការងារ ជាមួយប្រធាន និងក្រុមការងាររបស់អង្គការអែម (AIM) ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងទទួលបាននូវការឧបត្ថម្ភពីអង្គការនូវសម្ភារបរិក្ខាមួយចំនួនរួមមាន អង្ករចំនួន ៣០០គីឡូក្រាម ទឹកអាល់កុលចំនួន ៦០លីត្រ ទឹកត្រី១០យួរ និងទឹកស៊ីអ៊ីវ១០យួរ កំប៉ុងប្រើសម្រាប់បាញ់អាកុលលាងដៃមួយចំនួនសម្រាប់ប្រើប្រាស់ និងផ្គត់ផ្គង់នៅមណ្ឌលសំចតទទួលពលករដែលត្រលប់មកពីក្រៅប្រទេស ជាពិសេសក្នុងយុទ្ធនាការទប់ស្កាត់ជម្ងឺកូវីដ ១៩ នេះ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៩. បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីផែនការឆ្នាំ២០២០ ចំនួន០៤លើក ដើម្បីដាក់ជូនក្រសួងមហាផ្ទៃ រៀបចំកម្មវិធីឆ្លងកិច្ចប្រជុំនេះ អ្នកចូលរួមចំនួន**៥១**នាក់ ស្រី**១១**នាក់។ ១០.ទទួលអំណោយពីអង្គការ មេត្រីអន្តរជាតិ (AIM) មានជាអង្ករ ២០០គីឡូ និងមីចំនួន ២០កេះ នៅសាលប្រជុំ គ.ជ.ប.ជ។ **១១**.ចូលរួមប្រជុំ ពិភាក្សាលើសេចក្តីសម្រេចស្តីពីការបង្កើត"មណ្ឌលទទួលពលករចំណាកស្រុក ប្រកដូង" ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **១២**. អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ និងក្រុមហ៊ុនឯកជនចិនជាដៃគូ ដើម្បីចូលរួមកម្មវិធីសំណេះសំណាលស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ របស់សហគមន៍ដែលជួបការលំបាក ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់នូវសម្ភារៈប្រើប្រាស់មួយចំនួន ជូនដល់ពលរដ្ឋចំនួន៥០គ្រួសារ នៅខេត្តកំពង់ឆ្នាំង។ **១៣**.កិច្ចប្រជុំស្តីកិច្ចពិភាក្សាការប្រើប្រាស់កញ្ចប់ថវិកាទៅលើគំរោងប្រគល់ជូន គ.ជ.ប.ជ ដោយអង្គការសម្ព័នចាប់ដៃនៅពេលខាងមុខ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **១៤**.កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ ស្តីពីការចាត់ចែងការងារ រវាងស្ថាប័ន និងដៃគូពាក់ព័ន្ធសម្រាប់ការអនុវត្តក្នុងមណ្ឌលទទួលពលករចំណាកស្រុកកំរៀង ខេត្តបាត់ដំបង ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **១៥**.កិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់ទៅលើខ្លឹមសារសេចក្តីព្រាង សៀវភៅការអប់រំ និងលំនាំនៃការបង្រៀនស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់ថ្នាក់បឋម និងមធ្យមសិក្សាទាំងរដ្ឋ និងឯកជន ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **១៦**.ពិធីប្រគល់ ទទួលសម្ភារៈបរិក្ខារមួយចំនួន ពីតំណាងអង្គការ ASEAN ACT សម្រាប់ជូនជនទេសន្តប្រវេសន៍ដែលជួបការលំបាកតាមបណ្តាខេត្តគោលដៅ ដើម្បីបញ្ចៀស ហានិភ័យ នៃអំពើជួញដូរមនុស្សក្នុងស្ថានភាពប្រឈមនឹងជម្ងឺកូវីដ-១៩ ក្រោមអធិបតីភាព |

| | |
|---|---|
| | លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **១៧.**កិច្ចប្រជុំពិភាក្សា ពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.នៅសាលាខេត្តបន្ទាយមានជ័យ។ **១៨.**អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ជួបសំណេះសំណាលជាមួយពលករទេសន្តរប្រវេសន៍ ស្តីពីការឆ្លើយតបនឹងវិបត្តកូវីដ-១៩ របស់សហគមន៍ដែលជួបការលំបាក ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងបានប្រគល់នូវសម្ភារៈប្រើប្រាស់មួយចំនួនទៅដល់ពលករចំនួន១០០នាក់ នៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ **១៩.**ប្រជុំពិភាក្សាស្តីពី សេចក្តីព្រាងខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នារវាងមូលនិធិអេ២១ និងការប្រគល់ទទួលអំណោយឧត្តម្ភជាអង្ករ ដល់ គ.ជ.ប.ជក្រោម អធិបតីភាពលោកជំទាវ**ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **២០.**កិច្ចប្រជុំស្តីពី ផែនការសកម្មភាពនៃកិច្ចសហការ ក្នុងការបង្ការជម្ងឺកូវីដ-១៩ ទៅដល់ពលករចំណាកស្រុកដែលងាយរងគ្រោះ ក្នុងសហគន៍ រវាងអង្គការដែលស្ថិតក្រោមអង្គការសហប្រជាជាតិមានដូចជាអង្គការយូនីសេហ្វ IOM WHO UNFPA ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **២១.**កិច្ចប្រជុំពិភាក្សា អំពីគម្រោងកម្មវិធីការពារពលករទេសន្តប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ និងសហគមន៍ពីហានិភ័យឆ្លងកូវីដ-១៩ ទ្រង់ទ្រាយធំ និងការផ្តល់សេវាចាំបាច់នានានៅមូលដ្ឋាន ក្រោមអធិបតីភាព ឯកឧត្តម **សក់សេដ្ឋា** រដ្ឋលេខាធិការប្រចាំការ និងលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ គ ជ.ប.ជ.នៅទីស្តីការក្រសួងមហាផ្ទៃអាគារ ទ។ **២២.**កិច្ចប្រជុំស្តីពី សេចក្តីប្រកាសរបស់ប្រទេសកាណាដាទទួលសំណើរគម្រោងអាស៊ាន ក្រោមមូលនិធិអាស៊ាន-កាណាដា សម្រាប់ផ្តួចផ្តើមថ្នាក់មូលដ្ឋាន ឆ្នាំ២០២០-២០២១ និងការរៀបចំឯកសារលើគម្រោងក្នុងមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡាងចាង (NSC-MLC) សម្រាប់ឆ្នាំ ២០២១ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ ជ.ប.ជ.នៅសាលប្រជុំ គ.ជ.ប.ជ។ **២៣.**កិច្ចប្រជុំសិក្ខាសាលាពិគ្រោះយោបល់លើការអនុវត្តគោលនោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារ កាំបូឌីយ៉ាណា អ្នកចូល រួមចំនួន៦០នាក់ ស្រី១០នាក់។ **២៤.**ដឹកនាំកិច្ចប្រជុំប្រមូលជាតុចូលនៃជំហរកម្ពុជា សម្រាប់លើកក្នុងកិច្ចប្រជុំកំពូលអាស៊ាន នៅសាលប្រជុំ គ.ជ.ប.ជ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអនុវត្តៈ**<br>**១.**លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៤០ច្បាប់ លិខិតចូល ៥៩ច្បាប់។ **២.**លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ៤៨ច្បាប់ លិខិតចូល ៧៥ច្បាប់។ **៣.**រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។ **៤.**បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ ខែមករា កុម្ភៈ និងខែមីនាឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៥.**ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥ ជារៀងរាល់ខែ។ **៦.**រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។ **៧.**ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី។ **៨.**ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។ **៩.**Scan & Uploaded |

ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ៦១៨ច្បាប់។ ១០.អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ១២៨សកម្មភាព។

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ិន វី** អគ្គលេខាធិការរង ទទួលបន្ទុក៖
  - ០ បានអញ្ជើញចូលរួមជាគណៈអធិបតី នៃកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារសៀវភៅគោល ស្តីពីលំហាត់របៀបសម្រាប់មន្ត្រីនគរបាលជាតិកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យបណ្ឌិត **សេង ផល្លា** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា។
  - ០ បានដឹកនាំក្រុមជំនួយកិច្ចការងារបង្ការ ទប់ស្កាត់ ចូលរួមប្រជុំពិភាក្សាបន្ត ស្តីពីការបង្កើតមេរៀនប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើការបោះពុម្ពផ្សាយសាកល្បង ក្នុងការដាក់បញ្ចូលនៅក្នុងម៉ោងសិក្សាសង្គម ក្រោមអធិបតីភាព លោកជំទាវ **សឿ សុជាតា** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅក្រសួងអប់រំ។

- **លោកអនុប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** បានដឹកនាំក្រុមការងារបានចូលរួម៖

១.ប្រជុំរៀបចំគម្រោងសិក្ខាសាលា ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ សម្រាប់ការចុះបណ្តុះបណ្តាលសាកល្បងលើសៀវភៅការអប់រំ និងលំនាំនៃការបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់គ្រូឧទ្ទេសភូមិភាគ និងគរុសិស្សឆ្នាំទី២ ខេត្តកំពង់ចាម នៅសាលប្រជុំក្រសួងអប់រំ យុវជន និងកីឡា។ ២.សហការជាមួយក្រសួងអប់រំយុវជននិងកីឡា ចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលសាកល្បងសៀវភៅអប់រំ និងលំនាំនៃការបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដើម្បីប្រមូលធាតុចូលបន្ថែម សម្រាប់កែលម្អការតាក់តែងសៀវភៅ និងផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងជម្ងឺកូវីដ១៩ ជូនដល់គ្រូឧទ្ទេស និងគរុសិស្ស នៅខេត្តកំពង់ចាម។ ៣.ប្រជុំពិភាក្សាកែសម្រួលអក្ខរាវិរុទ្ធ ខ្លឹមសារអត្ថបទ និងខ្លឹមសាររូបភាពសៀវភៅអប់រំ និងលំនាំនៃការបង្រៀនស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ថ្នាក់មធ្យមសិក្សា នៅសាលប្រជុំនៃក្រសួងអប់រំ យុវជន និងកីឡា។ ៤.រៀបចំតាក់តែងសៀវភៅសិក្សាគោល ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងសៀវភៅជំនួយ វិធីសាស្ត្របង្រៀនសម្រាប់គ្រូ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៥.និងតំណាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការវៃគូ បានបន្តរៀបចំតាក់តែងសៀវភៅសិក្សាគោល ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងសៀវភៅជំនួយវិធីសាស្ត្របង្រៀនសម្រាប់គ្រូ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៦.មន្ត្រីចូលរួមកិច្ចប្រជុំពិភាក្សាបង្កើតមេរៀនសៀវភៅសិក្សាគោល ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងសៀវភៅជំនួយវិធីសាស្ត្របង្រៀនសម្រាប់គ្រូ ចំនួន០២លើក ក្រោមអធិបតីភាព លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅក្រសួងអប់រំ។ ៧.ប្រជុំពិភាក្សាបង្កើតសៀវភៅសិក្សា ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងសៀវភៅលំនាំគ្រូបង្រៀនបន្ត ចំនួន០២លើក នៅសាលប្រជុំនាយកដ្ឋាននីតិកម្ម ក្រសួងអប់រំ យុវជន និងកីឡា។ ៨.រៀបចំកិច្ចប្រជុំពិភាក្សាពិគ្រោះ និងផ្តល់យោបល់លើទម្រង់នៃរបាយការណ៍ដើម្បីដាក់បញ្ចូលក្នុង Database អ្នកចូលរួមចំនួន០៥នាក់។៩.រៀបចំកិច្ចប្រជុំពិភាក្សាពិគ្រោះ និងផ្តល់យោបល់លើមេរៀនទម្រង់នៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច សម្រាប់យកទៅបង្រៀន និងធ្វើបតបង្ហាញជូន ដល់សិក្ខាកាមជាកងកម្លាំងមួកខៀវកម្ពុជា អ្នកចូលរួមចំនួន០៥នាក់។

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ** ឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហុយ** អគ្គលេខាធិការរងទទួលបន្ទុក បានដឹកនាំក្រុមការងារចូលរួម៖

| | |
|---|---|
| | ១.អមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចុះសួរសុខទុក្ខនិង នាំយកថវិកាជូនជនរងគ្រោះ សម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកែបដោយគ្រោះថ្នាក់អាគាររលំបាក់ កាលពីថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០២០។ **២**.សហការជាមួយក្រសួងសង្គមកិច្ច និងអង្គការដៃគូរ បានចុះធ្វើការត្រួតពិនិត្យ តាមដានស្ត្រីពពោះជំនួសចំនួន០៣នាក់នៅស្រុកស្រីសន្ធរ ស្រុកកងមាស និងស្រុកកោះសុទិន ខេត្ត កំពង់ចាម។ **៣**.ធ្វើការបូកសរុបរបាយការណ៍ឆ្នាំ ២០១៩ និងលើកទិសដៅបន្ត របស់ក្រុមកិច្ចការការពារជនរងគ្រោះ។ **៤**.សិក្ខាសាលាថ្នាក់ជាតិស្តីពី កិច្ចការពារកុមារ ក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារភ្នំពេញ។ **៥**.សិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារសៀវភៅគោល ស្តីពីលំហាត់របៀបសម្រាប់មន្ត្រីនគរបាលជាតិ នៅសាលាបណ្ឌិត្យសភានគរបាលកម្ពុជា។ **៦**.កិច្ចប្រជុំ ស្តីពីការលើកកម្ពស់សុវត្ថិភាពអ៊ីនធើណេតសីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ នៅសាលប្រជុំទីស្តីការ ក្រសួងអប់រំ យុវជន និងកីឡា។ **៧**.កិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធើណេត (OCSE) នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។ **៨**.វគ្គបណ្តុះបណ្តាលរបស់ក្រុមការងារអន្តរក្រសួង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធើណេត យន្តការឆ្លើយតបបច្ចុប្បន្នភាព និងភាពខ្វះចន្លោះ នៅសណ្ឋាគារខេមរា អង្គរ ខេត្តសៀមរាប ដែលមានអ្នកចូលរួមសរុបចំនួន ៥៣នាក់ (ស្រី ១៦នាក់) ដែលរៀបចំដោយនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។ **៩**.កិច្ចប្រជុំ ស្តីពីការអនុវត្ត គោលនយោបាយប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ **១០**.ចុះធ្វើការវាយតម្លៃអំពីផលប៉ះពាល់សង្គម និងសុខភាពដោយ ជំងឺកូវីដ១៩ លើពលករ ទេសន្តរប្រវេសន៍ ដែលបានវិលត្រឡប់មកវិញ នៅខេត្តចំនួន ០៣ ដោយមានការសហការជាមួយ (បន្ទាយមានជ័យ បាត់ដំបង នឹងសៀមរាបUNFPA . IOM និងភ្នាក់ងារដទៃទៀត)។ **១១**.កិច្ចប្រជុំបូកសរុបរបាយការណ៍ ឆមាសទី ០១ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គកិច្ច នៅសាលប្រជុំទីស្តីការក្រសួងសង្គមកិច្ច។ **១២**.កិច្ចប្រជុំពិភាក្សាស្តីពី ការពង្រឹង វិធានការទប់ស្កាត់ និងគ្រប់គ្រងពលករឆ្លងដែន ដោយខុសច្បាប់ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំខេត្តបន្ទាយមានជ័យ។ **១៣**. ចុះទទួលជនរងគ្រោះ នៅច្រកទ្វារអន្តរជាតិបាវិត ក្រុងបាវិត ខេត្តស្វាយរៀងចំនួន ០៣នាក់ ដែលអាជ្ញាធរ វៀតណាមឃាត់ខ្លួនបាន ដោយបានលួចរត់ឆ្លងមកពីប្រទេសចិន ដោយបានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនិតិសម្បទា និងអង្គការចាប់ដៃ។ **១៤**.កិច្ចប្រជុំក្រុមការងារបច្ចេកទេស OCSE ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការសកម្មភាព ឆ្លើយតបទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ នៅសាលប្រជុំសាលាខេត្តកំពត។ **១៥**.សិក្ខាសាលាពិគ្រោះយោបល់បញ្ចប់សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសុខភាពជនអន្តោប្រវេសន៍ អ្នកចូលរួមចំនួន ៦០នាក់ នៅសាលប្រជុំសាលាខេត្តព្រៃវែង។ |
| | ▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់** ឯកឧត្តម ឧត្តមសេនីយ៍ទោ **តែ សុជាតិ** អគ្គលេខាធិការរងទទួលបន្ទុក បានចូលរួម៖<br>១.សិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុតិធម៌កម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **វង សូត** រដ្ឋមន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារភ្នំពេញ។ **២**.កិច្ចប្រជុំប្រមូលព័ត៌មានអំពីម្តាយ និងកូនស្រីដែលរងគ្រោះនៅប្រទេសចិន ហើយត្រូវបានជួយសង្គ្រោះ ត្រឡប់មកប្រទេសកម្ពុជាវិញតាមច្រកប្រទេសវៀតណាម នៅសាលប្រជុំ គ.ជ.ប.ជ។ **៣**.អមដំណើរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជចូលរួមកម្ម |

វិធីសំណេះសំណាល និងចែកអំណោយជូនប្រជាពលរដ្ឋដែលទើបវិលត្រឡប់មកពីក្រៅប្រទេស នៅស្រុកកំរៀង ខេត្តបាត់ដំបង។ ៤.កិច្ចប្រជុំពិភាក្សាស្តីពីការពង្រឹងវិធានការទប់ស្កាត់និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់ របស់ពលករកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គជ.ប.ជ. នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។ ៤.អមដំណើរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ លោកជំទាវ អគ្គលេខាធិការ ជួបសំណេះសំណាលជាមួយពលករទេសន្តរប្រវេសន៍ចំនួន១០០នាក់ ស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ១៩- របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់សម្ភារ ប្រើប្រាស់មួយចំនួន ដែលទទួលបានការឧបត្ថម្ភគាំទ្រពីអង្គការដៃគូមានៈUNFPA និងIOM ដល់ប្រជាពលរដ្ឋដែលទើបវិលត្រឡប់ពីក្រៅប្រទេស នៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប។

- **ក្រុមជំនួយកិច្ចការយុត្តិធម៌** ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម៖

១.ពិធីជួបជុំរវាង **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងអ្នកសារព័ត៌មានក្នុងស្រុកលើកទី៤ នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័ណ៌កោះពេជ្រ។ ២.កិច្ចប្រជុំនៅសាលាបណ្ឌិតសភានគរបាលកម្ពុជា ដើម្បីពិភាក្សារៀបចំសន្ទានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់នៃក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា។ ៣.បានសហការជាមួយលោកទីប្រឹក្សា គ.ជ.ប.ជ ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ជំនួយកិច្ចការបង្ការទប់ស្កាត់ បានចូលរួមពិនិត្យ កែសម្រួលសេចក្តីព្រាង MOU របស់តំណាងអង្គការ « មូលនិធី អេ ២១ » ចំនួនពីរូប ដែលបានស្នើសុំកិច្ចសហការជាមួយ គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវជូប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គជ.ប.ជ. និង លោកជំទាវ អគ្គលេខាធិការ នៅសាលប្រជុំ គ.ជ.ប.ជ។

- **លោកអនុប្រធានក្រុមកិច្ចការយុត្តិធម៌** បានចូលរួម៖ ១.កិច្ចប្រជុំពិភាក្សាការងារជាមួយ តំណាងអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី និងកុមារ(LSCW) និងវិទ្យាស្ថានបច្ចេកវិទ្យា អាស៊ី(AIT=Asian Institute Technology)ចំនួន០២រូប សុំកិច្ចសហការធ្វើការសិក្សាស្រាវជ្រាវស្តីពី «ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ គោលនយោបាយ និងកិច្ចព្រមព្រៀងទ្វេភាគីរវាងកម្ពុជា ថៃ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស »នៅសាលប្រជុំ គ.ជ.ប.ជ។ ២.កិច្ចប្រជុំជាមួយ ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ជំនួយកិច្ចការការពារ ជនរងគ្រោះ និងជំនួយកិច្ចការអនុវត្តច្បាប់ ដើម្បីពិនិត្យផ្ទៀងផ្ទាត់និងដាក់បញ្ចូលចង្កោមសកម្មភាពរបស់ក្រុមជំនួយកិច្ចការនីមួយៗ តាមលេខរៀងដូចដើមទៅក្នុងផែនការសកម្មភាពឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន នៅសាលប្រជុំ គ.ជ.ប.ជ។ ៣.កិច្ចប្រជុំជាមួយក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីពិនិត្យផ្ទៀងផ្ទាត់លទ្ធផលការងាររបស់ខ្លួនដែលទទួលបានពីក្រុមជំនាញអន្តរក្រសួង ស្ថាប័នទាំង៦ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ និងត្រៀមឆ្លើយតបតាមអនុសាសន៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០-២០២១ ទាំង១៧ចំណុចរបស់អាមេរិក តាមវិស័យពាក់ព័ន្ធរៀងៗខ្លួន នៅសាលប្រជុំ គ.ជ.ប.ជ។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**

- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម ៖

| | |
|---|---|
| | ១.ចូលរួមកិច្ចប្រជុំពិភាក្សាក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ កិច្ចប្រជុំបានផ្តោតសំខាន់ទៅលើរបាយការណ៍យេនឌ័រឆ្នាំ២០១៩ និងរបាយការណ៍ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី។ ២. ដឹកនាំក្រុមការងារប្រជុំផ្ទៃក្នុង ដើម្បីត្រួតពិនិត្យពីវឌ្ឍនភាពការងារ និងស្វែងរកបញ្ហាប្រឈម និងដំណោះស្រាយ អ្នកចូលរួមចំនួន០៦នាក់។ ៣.ចូលរួមកិច្ចប្រជុំពិភាក្សាអំពីគម្រោងកិច្ចសហការជាមួយតំណាងអង្គការ ASEAN-ACTS ដើម្បីសិក្សាពីតម្រូវការបន្ថែមអំពីផែនការ និងសកម្មភាពរបស់ក្រុមការងារសហប្រតិបត្តិការអន្តរជាតិដើម្បីឲ្យខាងអង្គការរៀបចំជាធនធាន ថវិកាដើម្បីធ្វើការចូលរួមសហការជាមួយគ្នា ក្នុងនោះដែរគេក៏បានបង្ហាញអំពីកញ្ចប់ថវិកាដៃគូមួយចំនួន ដែលគេមានសម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០២០។ ៤.ជាគណៈអធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែន នៅសាលាស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ និងនៅខេត្តព្រះសីហនុ។ ៥.កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តឆ្នាំ២០២០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។ ៦.កិច្ចប្រជុំអន្តរក្រសួងដើម្បីត្រៀមឯកសារចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា អឺរ៉ុបលើកទី១១ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។ ៧.កិច្ចប្រជុំបូកសរុបរបាយការណ៍ ក្នុងពិធីបើកសន្និបាតត្រួតពិនិត្យការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ។ ៨.កិច្ចប្រជុំពិនិត្យ និងកែសម្រួលរបាយការណ៍ សម្រាប់ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ដើម្បីផ្ញើជូនក្រុមការងាររបាយការណ៍ នៃលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៩.ពិភាក្សាពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់របស់ពលករកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំខេត្តឧត្តរមានជ័យ។ ១០.អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជួបសំណេះសំណាលជាមួយពលករទេសន្តរប្រវេសន៍ស្តីពីការឆ្លើយតបនឹង១៩ របស់សហគមន៍ប្រគល់សម្ភារប្រើប្រាស់មួយចំនួន ចំនួន១០០នាក់ នៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប។ ១១.កិច្ចប្រជុំពិភាក្សាស្តីពី "គម្រោងកម្មវិធីការពារពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ និងសហគមន៍ពីហានីភ័យឆ្លងជំងឺកូវីដ១៩ ទ្រង់ទ្រាយធំ និងការផ្តល់សេវាចាំបាច់នានានៅមូលដ្ឋាន" ក្រោមអធិបតីភាព ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការ និងលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃអគារ ទ។ ១២.កិច្ចប្រជុំជាមួយ ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ជំនួយកិច្ចការការពារ ជនរងគ្រោះ និងជំនួយកិច្ចការអនុវត្តច្បាប់ ដើម្បីពិនិត្យផ្ទៀងផ្ទាត់និងដាក់បញ្ចូលចង្កោមសកម្មភាពរបស់ក្រុមជំនួយកិច្ចការនីមួយៗ តាមលេខរៀងដូចដើមទៅក្នុងផែនការសកម្មភាពឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ១៣.កិច្ចពិភាក្សាស្តីពី "ការពិគ្រោះយោបល់ពិភាក្សា លើការចាត់ចែងការងាររវាងស្ថាប័ន និងដៃគូពាក់ព័ន្ធ សម្រាប់ការអនុវត្តក្នុងមណ្ឌលទទួលពលករចំណាកស្រុកនៅស្រុកកំរៀងខេត្តបាត់ដំបង" ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>១៤.ជាមួយ ថ្នាក់ដឹកនាំក្រុមជំនួយកិច្ចការការពារជនរងគ្រោះ២រូប ផ្តល់កិច្ចសម្ភាសន៍តាមរយៈប្រព័ន្ធអ៊ីនធើណិត (SKYPE Video Conference) ក្នុងការស្រង់ទិន្នន័យសម្រាប់ការស្រាវជ្រាវ លើការអនុវត្ត "គម្រោងផ្តល់វគ្គបណ្តុះបណ្តាលអំពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត" របស់អង្គការអន្តរជាតិសម្រាប់ទេសន្តរប្រវេសន៍ (IOM)។ ១៥.បានចូលរួមសិក្ខាសាលា ស្តីពីទិវាភាពជាអ្នកដឹកនាំឆ្នាំ២០២០ ក្រោមប្រធានបទ "ការបង្កើតទម្លាប់ធ្វើការងារឱ្យបានខ្លាំងក្លា និងមានប្រសិទ្ធភាពខ្ពស់" នៅទីស្តីការក្រសួងកិច្ចការនារី។<br>- **លោកអនុប្រធានក្រុមការងារ** បានដឹកនាំចូលរួម៖ |

| | |
|---|---|
| | ១.កិច្ចប្រជុំពិភាក្សា ជាមួយតំណាងអង្គការដៃគូចំនួន២គឺ អង្គការ LSCW និងGVC ស្តីពីកិច្ចសហការប្រមូលសេវាកម្មរបស់អង្គការដៃអភិវឌ្ឍន៍ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធ Database និងធ្វើការពិភាក្សាទៅលើការប្រមូលទិន្នន័យទាក់ទងនៅនឹងការរំលោភបំពានទៅលើជនទេសន្តរប្រវេសន៍ ដែលគេធ្វើនៅលើខេត្តគោលដៅចំនួនពីរគឺសៀមរាប និងបន្ទាយមានជ័យ។ ២.កិច្ចប្រជុំផ្ទៃក្នុង លើការរៀបចំផែនការដកស្រង់ព័ត៌មានពលករវិលត្រឡប់រក្សាទុកក្នុង database ការរៀបចំផែនការក្រុមការងារ និងត្រួតពិនិត្យការងារពីដើមឆ្នាំ២០២០ ដើម្បីធ្វើការដកស្រង់ វិភាគ និងវាយតម្លៃការងារដែលបានធ្វើកន្លងមក ដែលមានអ្នកចូលរួមចំនួន ០៤នាក់។ ៣.កិច្ចប្រជុំពិភាក្សា ត្រួតពិនិត្យរបាយការណ៍ឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួមចំនួន១៥នាក់។ ៤.ក្នុងកិច្ចប្រជុំពិភាក្សាស្តីពី "សេចក្តីព្រាងខ្លឹមសារអនុស្សរណៈយោគយល់គ្នារវាងមូលនីធិA២១ និងការប្រគល់ទទួលអំណោយជាអង្គរ" ជាមួយនិងគណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ៖**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង ទទួលបន្ទុកបានចូលរួម៖ ១.ប្រជុំជាមួយ លោកជំទាវ អគ្គលេខាធិការ ដើម្បីជួយផ្តល់គំនិតត្រៀមឆ្លើយតបនូវសំនួរ៧ចំណុច ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់វិទ្យុស្ត្រី នៃមណ្ឌលព័ត៌មានស្ត្រីកម្ពុជា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ២.សិក្ខាសាលាថ្នាក់ជាតិលើកទី២ ស្តីពីកិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពាន ផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ ៣.ប្រជុំពិនិត្យ និងដកស្រង់ខ្លឹមសាររបាយការណ៍គន្លឹះ ដើម្បីផ្ញើរជូនតាមការស្នើសុំរបស់ក្រុមការងារក្រសួងមហាផ្ទៃ ទទួលការងារប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខ័ណ្ឌអាស៊ាន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៤.ប្រជុំដើម្បីផ្តល់ធាតុចូលលើសេចក្តីព្រាងឯកសារទស្សនៈទាន ស្តីពីការរៀបចំច្រកធ្វើដំណើរអាស៊ាន ក្រោមអធិបតីភាព**លោកជំទាវ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** នៅសាលប្រជុំក្រសួងមហាផ្ទៃអគារ ទ ។ ៥.ប្រជុំប្រចាំខែមាសទី១ ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយក្រុមការងារទាំង៦ (អន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ អគារ A ។ ៦.អមដំណើរ**លោកជំទាវ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ចូលរួមកិច្ចប្រជុំស្តីពី ការត្រួតពិនិត្យ និងដោះស្រាយនូវសំណូមពរ និងកង្វល់របស់ប្រជាពលរដ្ឋ ដែលនៅសេសសល់ មិនទាន់បានដោះស្រាយឆ្នាំ២០២០ និងទិសដៅអនុវត្តបន្តរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត កំពង់ឆ្នាំង។ ៧.សិក្ខាសាលាថ្នាក់ជាតិ ស្តីពីសេវាគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព**លោកជំទាវ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។ ៨.ប្រជុំផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវរបស់អង្គការមូលនិធិយុវជនជនបទនៃប្រទេសថៃ ស្តីពីតម្រូវការ និងការសិក្សាជាមូលដ្ឋានសម្រាប់កុមារចំណាកស្រុកកម្ពុជា ដែលកំពុងរស់នៅប្រទេសថៃ តាមរយៈ Video Conference នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ ៩.ធ្វើជាតំណាងរបស់លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមក្នុងពិធីសំណេះសំណាល និងចែកអំណោយដ៏ថ្លៃថ្លារបស់សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចគតិព្រឹទ្ធបណ្ឌិត ជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់នៅខេត្តកំពង់ឆ្នាំងក្រោមអធិបតីភាពដ៏ |

| | |
|---|---|
| | ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុក វ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង។ **១០.**កិច្ចប្រជុំកែសម្រួលខ្លឹមសារនៃកិច្ចព្រមព្រៀង រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការយែអន្តរជាតិប្រចាំកម្ពុជា នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។ **១១.**ពិធីចុះអនុស្សរណៈនៃការយោគយល់រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងអង្គការ A21 ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ **១២.**ជាកិត្តិយស ក្នុងទិវាជនទេសន្តរប្រវេសន៍អន្តរជាតិ IMD តាមរយៈវីដេអូ Conference ក្រោមការដឹកនាំរបស់លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **១៣.**ប្រជុំពង្រឹងរបៀបរបបការងារ ក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមការដឹកនាំក្រោមការដឹកនាំរបស់លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ **១៤.**ពិធីចុះកិច្ចព្រមព្រៀងរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការយែអន្តរជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ **១៥.**ពិធីចុះហត្ថលេខា អនុស្សរណៈនៃការយោគយល់ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រយុទ្ធប្រឆាំងអំពើជួញដូរកុមារ នៅកម្ពុជា(Cambodia-ACT) ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- **លោកអនុប្រធានក្រុមការងារបាន៖** ១.ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ ស្តីពីកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ ក្រោមអធិបតីយភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅក្រសួងមហាផ្ទៃអគារទ ។ ២.ទំនាក់ទំនងទៅលោកឧត្តមសេនីយ៍ទោ **អឿម សំអាត** នាយរងទីចាត់ការការពារព្រំដែន នៃអគ្គបញ្ជាការដ្ឋានក្រសួងការពារជាតិ ដើម្បីសុំរបាយការណ៍ឆមាសទី១ ឆ្នាំ២០២០។ ៣.ទំនាក់ទំនងទៅលោក **អ៊ុក វ៉ារុធ** អនុប្រធាននាយកដ្ឋានហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីសុំរបាយការណ៍ឆមាសទី១ ឆ្នាំ២០២០។ ៤.បូកសរុបទិន្នន័យពលករកម្ពុជាដែលវិលត្រឡប់មកពីបម្រើការងារ នៅក្រៅប្រទេសក្នុងអំឡុងពេលនៃការរាលដាលជម្ងឺកូវីដ-១៩ ប្រចាំថ្ងៃ ទាំង២៥រាជធានី-ខេត្តផ្ញើមកជូន**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវ អគ្គលេខាធិការ** គ.ជ.ប.ជ។ **៥.**ទំនាក់ទំនងទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីយករូបភាពសកម្មភាពការងារប្រឆាំងការជួញដូរមនុស្សរបស់ក្រសួង ដាក់បញ្ចូលក្នុងរបាយការណ៍ឆ្នាំរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ៦.ប្រជុំ ស្តីពីការផ្តល់យោបល់ធាតុចូលសម្រាប់ការបង្កើតទម្រង់ប្រមូលរបាយការណ៍ តាមប្រព័ន្ធប្រមូលទិន្នន័យ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៧.**ប្រជុំផ្ទៀងផ្ទាត់របាយការណ៍ឆមាសទី១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដើម្បីត្រៀមប្រជុំនៅថ្ងៃទី០៦ ខែ០៨ ឆ្នាំ២០២០ ក្រោមអធិបតីភាព**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ** នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ ៨.ប្រជុំជាមួយ លោកជំទាវ ឯកឧត្តមជាអគ្គលេខាធិការរង និងលោក ប្រធានក្រុមជំនួយកិច្ចការជួយជនរងគ្រោះ ពិភាក្សាជាមួយលោក អេង ហុក តំណាងអង្គការ Child Fund នៅកម្ពុជា ដើម្បីត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយ ផ្សព្វផ្សាយពីលទ្ធផលនៃកិច្ចសហការចុះសិក្សាស្រាវជ្រាវពីភាពរងគ្រោះរបស់កុមារដែលត្រូវបានគេជួញដូរ កុមារដែលឪពុកម្តាយធ្វើចំណាកស្រុកចោលជាមួយមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ កាលពីឆ្នាំ២០១៩ តែមិនទាន់ដាក់ប្រធានបទ |

| | |
|---|---|
| | និងជម្រាបជូនពីគម្រោងដែល Child Fund ត្រូវធ្វើបន្តទៅទៀត ក្រោមការសម្របសម្រួលដោយ លោកជំទាវ **អគ្គលេខាធិការ គ.ជ.ប.ជ**។ ៩.កិច្ចប្រជុំត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិលើកទី២ ស្តីពីកតិកាសញ្ញាពិភពលោកសំរាប់ទេសន្តប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) នៅសណ្ឋាគារភ្នំពេញ ក្រោមកិច្ចសហការរៀបចំឡើងដោយអង្គការ IOM និងអង្គការដៃគូ និងក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ |
| **អន្តរក្រសួង ស្ថាប័ន សម្របសម្រួលបាន ១០០លើក** | |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | - **បានចូលរួមកិច្ចប្រជុំ៖** ១.បានចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ។ ២.គណៈកម្មការអាស៊ានស្តីពីការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការការពារ និងការលើកកម្ពស់ទេសន្តប្រវេសន៍ការងារលើកទី១៣(13th ACMW) ក្រោមមូលបទ "ការគាំទ្រពលករទេសន្តប្រវេសន៍ ក្នុងអំឡុងពេលជំងឺរាតត្បាតសម្រាប់សហគមន៍អាស៊ាន ដែលមានភាពស្អិតរមួត និងឆ្លើយតបទាន់ពេលវេលា" និងវេទិកាអាស៊ានលើកទី១៣ ស្តីពីទេសន្តប្រវេសន៍ការងារ(១៣th AFML) ក្រោមប្រធានបទ "ការ និងការការពារពលករទេសន្តប្រវេសន៍ក្នុងអឡុងពេលជំងឺរាតត្បាតកូវីដ ១៩"។<br>- **បានចូលរួមសិក្ខាសាលា៖** ១.ចូលរួមសិក្ខាសាលាពិគ្រោះយោបល់តាមប្រព័ន្ធ ស្តីពីការកំណត់ឱកាសក្នុងអាស៊ានសម្រាប់ជំរុញយុទ្ធសាស្ត្រពហុវិស័យក្នុងតំបន់ដើម្បីដោះស្រាយបញ្ហាការជួញដូរមនុស្ស និងពលកម្មដោយបង្ខំនៅក្នុងឧស្សាហកម្មនេសាទ។ ២.ពិគ្រោះយោបល់ស្តីពី "ការកំណត់ឱកាសក្នុងអាស៊ានសម្រាប់ការជម្រុញយុទ្ធសាស្ត្រពហុវិស័យថ្នាក់តំបន់ ដើម្បីដោះស្រាយបញ្ហាការជួញដូរមនុស្ស និងពលកម្មដោយបង្ខំនៅក្នុងឧស្សាហាមកម្មនេសាទ" តាមប្រព័ន្ធអនឡាញ។<br>- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តជាប់ព្រំដែនកម្ពុជាថៃ បានសហការជាមួយ-អាជ្ញាធរខេត្តក្នុងការទទួលពលករវិលត្រឡប់នៅតាមច្រកព្រំដែន និងសម្របសម្រួលក្នុងការដឹកជញ្ជូនពលករវិលត្រឡប់ទៅស្រុកកំណើតវិញ និងបានចូលរួមសហការក្នុងការណែនាំពលករដែលវិលត្រឡប់ មកដល់ស្រុកកំណើតវិញឱ្យអនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាលនៅតាមមូលដ្ឋានរបស់ខ្លួន។<br>- ប្រឹក្សាទទួលបន្ទុកពលករប្រចាំនៅស្ថានឯកអគ្គរាជទូតកម្ពុជានៅប្រទេសទទួល បានសហការជាមួយអាជ្ញាធរពាក់ព័ន្ធនៃប្រទេសទទួល ដើម្បីដោះស្រាយបញ្ហា និងបានចេញសេចក្តីជូនដំណឹងជាបន្តបន្ទាប់ ដើម្បីផ្សព្វផ្សាយ និងណែនាំដល់ពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការនៅបរទេសឱ្យអនុវត្តតាមច្បាប់ បទបញ្ញា និងវិធានការនានាដែលបានដាក់ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ក្នុងអំឡុងពេលនៃការទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩។<br>- ចាត់មន្ត្រី ២រូប ចូលរួមវគ្គបណ្តុះបណ្តាលអន្តរជាតិតាមប្រព័ន្ធវីដេអូ ស្តីពីការអនុវត្តល្អៗក្នុងការធ្វើអោយប្រសើរឡើងការគ្រប់គ្រងទេសន្តប្រវេសន៍ការងារដើម្បីលើកកម្ពស់ការងារសមរម្យ ដែលរៀបចំដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសថៃ(TICA) សហការជាមួយវិទ្យាស្ថានមេគង្គ(MI)។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលអន្តរជាតិតាមប្រព័ន្ធវីដេអូ ស្តីពីការអនុវត្តល្អៗក្នុងការធ្វើអោយប្រសើរឡើងការគ្រប់គ្រងទេសន្តប្រវេសន៍ការងារដើម្បីលើកកម្ពស់ការងារសមរម្យ ដែលរៀបចំដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសថៃ (TICA) សហការជាមួយវិទ្យាស្ថានមេគង្គ (MI)។ |
| **ក្រសួងអប់រំយុវជន និងកីឡា** | ▪ **បានចូលរួមកិច្ចប្រជុំ៖** ១.ប្រចាំត្រីមាសទី២ ឆ្នាំ២០២០ របស់ក្រុមការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំដោយក្រសួងសង្គមកិច្ច និងបានសហការជាមួយអង្គការដៃគូ។ ២.បានចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |

| | |
|---|---|
| | ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ។ ៣.គណៈកម្មការដឹកនាំការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ នៅសណ្ឋាគារសាន់វេ ។ ៤.ផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់អង្គការមូលនិធិយុវជនជនបទនៃប្រទេសថៃ ស្តីពី"តម្រូវការ និងការសិក្សាមូលដ្ឋានសម្រាប់កុមារចំណាកស្រុកកម្ពុជាដែលកំពុងរស់នៅប្រទេសថៃ" រៀបចំដោយគ.ជ.ប.ជ។ ៥.បូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំឆមាសទី១ ឆ្នាំ២០២០របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅទីស្តីការក្រសួងមហាផ្ទៃ។ ៦.ពិភាក្សាលើការរៀបចំឯកសារឆ្លើយតបរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកពាក់ពន្ធ័ការដាក់ចំណាត់ថ្នាក់កម្ពុជាលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងកិច្ចការនារី។ ៧.ជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជាក្នុងគោលបំណងបកស្រាយ និងបំភ្លឺលើកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាលើការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ៨.បានចូលរួមប្រជុំក្រុមការងារការពារជនរងគ្រោះប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ៩.អន្តរក្រសួងដើម្បី ពិនិត្យ និងកែលម្អកម្រងសំណួរវាយតម្លៃរាជធានី ខេត្តឆ្នាំ២០២០។១០.អន្តរក្រសួងដើម្បី ពិនិត្យ និងពិភាក្សា ស្តីពី "វឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការប្រឈម និងការដោះស្រាយ"។<br>- **បានចូលរួមសិក្ខាសាលា៖** ១.ថ្នាក់ជាតិ ស្តីពីសេវាគាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅភោជនីយដ្ឋានទន្លេបាសាក់ ២។ ២.សិក្ខាសាលាថ្នាក់ជាតិស្តីពីកិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍ រៀបចំដោយ គ.ជ.ប.ជ។ ៣.ថ្នាក់ជាតិលើកទី២កម្រិតថ្នាក់ដឹកនាំស្តីពី "កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់" នៅក្រសួងមហាផ្ទៃ។ ៤.ថ្នាក់ជាតិស្តីពីកិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍ នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួង ស.អ.យ បានដឹកនាំក្រុមការងារចូលរួម៖(៧១លើក)<br>១.កិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារខមមីត ។ ២.កិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស និងក្រុមការងារខមមីត ដែលដឹកនាំដោយ ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងស.អ.យ នៅក្រសួងកិច្ចការនារី។ ៣.សិក្ខាសាលា ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាអន្តរទំនាក់ទំនង និងផែនការយថាភាពក្នុងកិច្ចសហប្រតិបត្តិការ នៃការត្រៀមលក្ខណៈឆ្លើយតប និងការវិល ត្រឡប់ដោយជនចំណាកស្រុក នៅភោជនីយដ្ឋានទន្លេបាសក់ II ។ ៤.សិក្ខាសាលាពិគ្រោះយោបល់លើសេចក្រីព្រាងកម្មវិធីបណ្តុះបណ្តាលតាម Online ស្តីពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត របស់អង្គការទេសន្តរប្រវេសន៍ អន្តរជាតិ (MOI) នៅភោជនីយដ្ឋានទន្លេបាសក់ II ។ ៥.សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីគោលនយោបាយទេសន្តរប្រវេសន៍ការងារឆ្នាំ២០១៩-២០២៣ នៅខេត្តសៀមរាប។ ៦.សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលការវិភាគស្ថានភាពដំបូង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញនៅកម្ពុជា។ ៧.បានចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន ០៩លើក។ ៨.សហការជាមួយអង្គការដៃគូក្នុងការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅធ្វើចត្តាឡីស័កនៅសហគមន៍ចំនួន១៣លើក ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រៃវែង ត្បូងឃ្មុំ កំពង់ចាម ក្រចេះ កំពង់ធំ ឧត្តរមានជ័យ បាត់ដំបង កំពត និងខេត្តស្វាយរៀង។ ៩.ចូលរួមចុះសួរសុខទុក្ខពលករ |

| | |
|---|---|
| | ពលករនីកម្ពុជា ដែលវិលត្រឡប់មកពីប្រទេសថៃវិញ តាមច្រកដូង ច្រកព្រំ និងច្រកទ្វារអន្តរជាតិប៉ោយប៉ែត (ខេត្តបាត់ដំបង និងបន្ទាយមានជ័យ)និងពង្រឹងការអនុវត្តសេចក្តីណែនាំ របស់ ក្រសួងក្នុងការការពារ និងទប់ស្កាត់ជម្ងឺកូវីដ១៩ ។<br>- **ក្រុមការងារនាយកដ្ឋានបាន៖** ១.សហការជាមួយសម្បុរសជន ចុះសួរសុខទុក្ខទារកគ្រោះដោយករណីពពោះជំនួស និងផ្តល់ ជំនួយមនុស្សធម៌មួយចំនួនជូនដល់បុរីទារក និងកុមារជាតិ។ ២.ជួយសម្របសម្រួល និងចុះសួរសុខទុក្ខស្ត្រីរងគ្រោះចំនួន០២នាក់ ដែលបាន សម្រាលកូន និងសម្រាកព្យាបាល នៅមន្ទីរ ពេទ្យ កាល់ ម៉ែត ដោយវះកាត់ និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក រាជធានីភ្នំពេញ ដោយក្នុងនោះមាន ករណីរំលោភបំពានផ្លូវភេទ ០១នាក់ និងជួញដូរផ្លូវភេទ០១នាក់។ ៣.ជួយសម្របសម្រួល និងនាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទូកនេសាទ ទៅទទួលសេវាពិនិត្យ និងព្យាបាលជម្ងឺ ផ្លូវចិត្ត ឥតបង់ថ្លៃ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ ៤.ជួយសម្របសម្រួលដល់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស០១នាក់ ទទួលបាន ប័ណ្ណសមធម៌ រួមជាមួយការ ពិនិត្យព្យាបាល ជម្ងឺឥតបង់ថ្លៃ នៅមន្ទីរពេទ្យ និងបញ្ជូនត្រឡប់ទៅផ្ទះវិញ ខេត្តកណ្តាល។ ៥.សហការជាមួយអង្គការដៃគូទៅទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានា ១៨លើក ក្នុងនោះទទួលពី; ព្រលានយន្តហោះអន្តរជាតិភ្នំពេញចំនួន១៣លើក ព្រលានយន្តហោះអន្តរជាតិព្រះសីហនុ០១លើក និងច្រកអន្តរជាតិបាវិត-ម៉ុកបាយ០៤លើក។ ៦.បានចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)ចំនួន០៥លើក។ ៧.បានសហការជាមួយអង្គការដៃគូចុះតាមដានស្ត្រីពពោះជំនួស០១លើក(បាត់ខ្លួនទាំងម្តាយនិងកូន) នៅខេត្តកំពង់ចាម។ ៨.ចុះជួបពិភាក្សាការងារជាមួយមន្ត្រីទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស ដែលធ្វើសកម្មភាពទទួល និងបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះទៅសហគមន៍វិញ នៅខេត្តកោះកុង។ ៩.ចុះប៉ាន់ប្រម៉ាណគ្រួសារ និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សបណ្តោះអាសន្ន ០២លើក នៅខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ។ ១០.ចុះស្រង់ទិន្នន័យដើម្បីកំណត់អត្តសញ្ញាណកម្មខសញ្ញាជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងចំណោមប្រជាពលរដ្ឋ និងពលករដែលត្រូវបានបញ្ជូនមកពីប្រទេសម៉ាឡេស៊ីចំនួន១២៥នាក់ ដែលបានធ្វើចត្តាឡីស័កនៅវិទ្យាល័យជម្ពូវ័ន ភ្នំពេញ។ ១១.ចាត់មន្ត្រីជួយសម្របសម្រួលជនរងគ្រោះក្នុងនីតិវិធីដាក់ពាក្យបណ្តឹងប្រធានមណ្ឌលអង្គការសុវណ្ណាកុមារ ករណីរំលោភបំពានផ្លូវភេទនៅអគ្គស្នងការដ្ឋាន នគរបាលជាតិ ចំនួន០៤លើក។ ១២.សហការជាមួយអង្គការស្ទួននៃក្តីសង្ឃឹមនៅកម្ពុជា ចុះធ្វើការផ្សព្វផ្សាយពាក់ព័ន្ធការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការអប់រំផ្លូវចិត្តអំឡុងពេលកូវីដ១៩ ដល់ពលករដែលបានត្រឡប់មកពីប្រទេសថៃ នៅខេត្តបាត់ដំបង និងបន្ទាយមានជ័យ។ ១៣.ទទួលអំណោយពីអង្គការដៃគូពាក់ព័ន្ធ ជាគ្រឿងឧបភោគបរិភោគសម្រាប់ចែកជូនដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតាមសហគមន៍ក្នុងបណ្តាខេត្តគោលដៅ អំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩។ ១៤.ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី សារអប់រំក្នុងការផលិតសម្ភារទាក់ទងនឹងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅខេត្តបន្ទាយមានជ័យ ០១លើក។ |
| **ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍** | - បានចូលរួមប្រជុំអន្តរក្រសួងស្តីពីការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២០ នៅទីស្តីការគណៈរដ្ឋមន្ត្រី។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីតួនាទីរបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ។ |

| | |
|---|---|
| **ក្រសួងព័ត៌មាន** | - បានចូលរួមក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩និងទិសដៅការងារឆ្នាំ២០២០របស់គណៈ កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆមាសទី១ ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមកិច្ចប្រជុំជាមួយក្រសួងសង្គមកិច្ច និងអង្គការ UNICEF ដើម្បីពិនិត្យលើខ្លឹមសារនៃសាច់ រឿងល្ខោននិយាយដែលទាក់ទងនឹងការជួញដូរផ្លូវភេទកុមារ នៅខេត្តសៀមរាប។<br>- បានចូលរួមកិច្ចប្រជុំក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នទាំង៦ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)ប្រចាំឆមាសទី១ ឆ្នាំ ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២៨០លើក អ្នកចូលរួមសរុបចំនួន ១១.៤៩៦នាក់ (ស្រី ៣៩៥នាក់)** | |
| **ខេត្តកោះកុង** | - លេខាធិការដ្ឋានខេត្តដឹកនាំដោយលោក **ស្រេង ហុង** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចុះប្រកាសក្រុមការងារទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងផ្សព្វផ្សាយទិវាជាតិ១២ធ្នូ ឆ្នាំ២០២០ នៅទូទាំង០៧ក្រុង ស្រុក។<br>- លោកជំទាវ **មិថុនា ភូថង** អភិបាលនៃគណៈអភិបាលខេត្ត បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានរៀបចំវិធីសំណេះសំណាលពង្រឹងសមត្ថភាពយេនឌ័រ និងផ្សព្វផ្សាយក្រុមប្រតិបត្តិយេនឌ័រ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ស្នងការដ្ឋាននគរបាលជាតិ ដែលមានអ្នកចូលរួមសរុប ២២នាក់។<br>- លោកស្រី **សុខ សុធាវី** ប្រធានមន្ទីរកិច្ចការនារី និងជាអនុប្រធានលេខាធិការដ្ឋានខេត្ត៖ ១.បានជួបពិភាក្សាការងារជាមួយតំណាងស្ថានទូតអាមេរិកប្រចាំកម្ពុជា និងតំណាងអង្គការរីនរ៉ក់អន្តរជាតិ ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួម ១៤នាក់ ស្រី០៤នាក់។ ២.បានចុះជួបពលករខ្មែរដែលថៃចាប់បញ្ជូនតាមច្រកព្រំដែនអន្តរជាតិចាំយាម ចំនួន០៤នាក់ បានអប់រំណែនាំ និងផ្តល់ថវិកាមួយចំនួន។ ៣.បានប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្តីពីការលើកកម្ពស់សុវត្ថិភាព និងកិច្ចការពារដល់ពលករទេសាទនៅប្រទេសថៃ ទៅលើកិច្ចគាំទ្រសេវាកម្មផ្នែកច្បាប់ទាំងនៅក្នុងប្រទេស និងនៅប្រទេសថៃ នៅពេលដែលមានបញ្ហា អ្នកចូលរួមចំនួន១២នាក់ ស្រី០៥នាក់។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ប្រចាំច្រកទ្វារព្រំដែនអន្តរជាតិចាំយាមបានទទួលពលករដែលភាគីថៃចាប់បញ្ជូនមកមិនស្របច្បាប់មានចំនួន១១១លើក មានចំនួន៣២២នាក់ ស្រី៩៩នាក់ ក្មេង០៨នាក់។ គិតដោយឡែកករណីដែលភាគីថៃបញ្ជូនមកមិនស្របច្បាប់ ក្រុមការងារ ច្រកទ្វារព្រំដែនអន្តរជាតិចាំយាមបានធ្វើការអប់រំណែនាំរួចបញ្ជូនមកធ្វើចត្តាឡីស័កកម្រិត២ សាលា ខេត្តចាស់។ |

| | |
|---|---|
| | - នាយការិយាល័យប្រឆាំងការជួញដូរមនុស្សនៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមសិក្ខាសាលាស្តីពី «កិច្ចលើកកម្ពស់កិច្ចការពារកុមារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ក្នុងដំណើរការព្រហ្មទណ្ឌ» នៅខេត្តសៀមរាប។ |
| **ខេត្តបន្ទាយមានជ័យ** | - លោកជំទាវ **ប៉ុក ណារី** អនុប្រធានលេខាធិការ គ.ខ.ប.ជ ខេត្តបានដឹកនាំក្រុមការងារអញ្ជើញ៖ ១.ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ ២.ចុះពិនិត្យមើល និងជួបសំណេះ សំណាលជាមួយប្រជាពលរដ្ឋត្រឡប់ពីប្រទេសថៃតាមច្រកអូរបីជាន់ ច្រកម៉ាឡៃ និងច្រកបឹងត្រកួន។ ៣.អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចុះពិនិត្យ និងសំណេះសំណាលជាមួយប្រជាពលរដ្ឋ ត្រឡប់មកពីប្រទេសថៃនៅមណ្ឌលសិចតប៉ោយប៉ែត និងមណ្ឌលចត្តាឡីស័កចំនួន ០៦លើក នៅស្រុកអូរជ្រៅ ស្រុកថ្មពួក និងស្រុកម៉ាឡៃ មានអ្នកចូលរួមចំនួន៧៦នាក់ ស្រី២៨នាក់ កុមារ៥នាក់។ ៤.ចុះសំណេះសំណាលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃតាមច្រកអូរបីជាន់ ដោយបានឧបត្ថម្ភអង្ករ ១០០គ.ក្រ ម៉ាស់១០០០ ថវិកា២.៥០០.០០០រៀល ដល់ក្រុមការងារប្រចាំការ។ ៥.ចុះសំណេះសំណាល និងចែកអំណោយប្រជាពលរដ្ឋ ត្រឡប់ពីប្រទេសថៃចំនួន១០០គ្រួសារ នៅស្រុកព្រះនេត្រព្រះ និងចំនួន២០០គ្រួសារនៅស្រុកមង្គលបូរី មានអង្ករ សារុង ក្រមា ថ្នាំ ដុសធ្មេញ សាប៊ូ និងថៃល។ |
| **ខេត្តឧត្តរមានជ័យ** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- លេខាធិការដ្ឋាន សហការជាមួយសមាគមនារីខេត្ត ស្រុក ឃុំ និងមន្ត្រីពាក់ព័ន្ធ ចុះសួរសុខទុក្ខ និងផ្តល់អំណោយដល់គ្រួសារជនរងគ្រោះដោយការជួញដូរមនុស្សទៅប្រទេសចិន ចំនួន០១លើក។<br>- បានសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីចុះតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ប្រឆាំង និងនារីភេទជាមួយមន្ទីរពាក់ព័ន្ធអង្គការក្រៅរដ្ឋាភិបាលស្ថាប័ន តុលាការ ស្នងការនគរបាលខេត្ត កងរាជអាវុធហត្ថខេត្ត ដែលមានអ្នកចូលរួម ៤០រូប ស្ត្រី ១៧រូប។<br>- លេខាធិការដ្ឋានរួមនិង សមាគមន៍នារី ខេត្ត ស្រុក ឃុំ កងកម្លាំងទាំងបី យុវជនស្រុក និងមន្ត្រីជំនាញផ្នែកជួញដូរ បានអមដំណើរ លោកជំទាវ មុំ ពុទ្ធីតា បានចុះសួរសុខទុក្ខជនរងគ្រោះឈ្មោះ សែម ស្រីពេជ្រ ដោយការជួញដូរទៅប្រទេសចិន និងគ្រួសារជនរងគ្រោះមានកូនក្នុងបន្ទុកមានចំនួន១១នាក់ ស្រី៨នាក់នៅស្រុកត្រពាំងប្រាសាទ ដោយមានការចែកអំណោយរួមមាន អង្ក២៥គីឡូ ទឹកត្រី១យួ ត្រីខ១យួ មី១កេះ និងឃីត១កញ្ចប់ រួមជាមួយថវិកាចំនួន២៥០.០០០រៀល។ |
| **ខេត្តសៀមរាប** | - ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបាន៖ ១.បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ ២.សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) ចុះជួបសំណេះសំណាលជាមួយអតីតពលករ ពលការិនី និងក្រុមគ្រួសារ ដើម្បីប្រមូលព័ត៌មាន និងស្វែងយល់បញ្ហាបន្ថែមពីករណីជួញដូរកម្លាំងពលកម្ម និងកំណត់ពីតម្រូវការរបស់ជនរងគ្រោះទាក់ទងនឹងផ្នែកច្បាប់ សេវាសង្គមកិច្ច នៅស្រុកអង្គរជុំ ស្រុកក្រឡាញ់ និងស្រុកពួក។ ៣.បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី២ស្តីពី ការឆ្លើយតបទៅនឹងជនងាយរងគ្រោះដែលកំពុងបំលាស់ទី(ចំណាកស្រុកនិងសមាហរណកម្ម) ចំនួន |

| | |
|---|---|
| | ០១លើក នៅខេត្តបាត់ដំបង។ ៤.លោកស្រីស្នងការនគរបាលរង បានចូលរួមកិច្ចប្រជុំកំពូលសកលស្តីពី សេរីភាពពីអំពើជួញដូរមនុស្ស (Global Freedom Summit) ០១លើក រៀបចំដោយអង្គការមូលនីធិអេ២១។ ៥.បានចូលរួមសិក្ខាសាលាស្តីពី សេវាគាំទ្រជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ០១លើក នៅរាជធានីភ្នំពេញ។ ៦.បានសម្របសម្រួល និងទទួលប្រជាពលរដ្ឋដែលចាញ់បោកមេខ្យល់នាំចេញទៅប្រទេសថៃដោយខុសច្បាប់ នៅចំណុចខ្លិនទា ភូមិរុន ឃុំសិង្ហ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បានចំនួន០១លើក។ ៧.សិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីការឆ្លើយតបទៅនឹងជនងាយរងគ្រោះ ដែលកំពុងបំលាស់ទី (ចំណាកស្រុក និងសមាហរណកម្ម) បានចំនួន ០១លើក នៅទីរួមខេត្តបាត់ដំបង។ ៨.ពិធីបញ្ចុះបឋមសិលា សាងសង់អគារមណ្ឌលទទួលពលករ បានចំនួន ០១លើក នៅក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។ ៩.បានធ្វើការសម្របសម្រួលជាមួយស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសថៃ និងអាជ្ញាធរខេត្តបន្ទាយមានជ័យ ក្នុងការអន្តរគមន៍ក្នុងការបញ្ជូន និងទទួលសពពលរដ្ឋខេត្តសៀមរាប ដែលស្លាប់នៅក្នុងប្រទេសថៃបានចំនួន ០៩នាក់ ស្រី ០៣នាក់។ **១០.**បានសម្របសម្រួល និងទទួលប្រជាពលរដ្ឋដែលចាញ់បោកមេខ្យល់នាំចេញទៅប្រទេសថៃដោយខុសច្បាប់ នៅចំណុចខ្លិនទា ភូមិរុន ឃុំសិង្ហ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បានចំនួន០១លើក។ **១១.**សិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីការឆ្លើយតបទៅនឹងជនងាយរងគ្រោះ ដែលកំពុងបំផ្លាស់ទី (ចំណាកស្រុក និងសមាហរណកម្ម) បានចំនួន ០១លើក នៅទីរួមខេត្តបាត់ដំបង។ **១២.**ពិធីបញ្ចុះបឋមសិលា សាងសង់អគារមណ្ឌលទទួលពលករ បានចំនួន ០១លើក នៅក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។ **១៣.**លេខាធិការដ្ឋាន បានចូលរួមចុះសួរសុខទុក្ខ និងផ្តល់ជូននូវកញ្ចប់ស្បៀង ដល់ប្រជាពលរដ្ឋដែលធ្វើចាត្តាឡឺស័ក នៅមណ្ឌលស្រុកអង្គជុំ ក្រុមជំនួយរបស់អង្គការ IOM បានចំនួន ០១លើក។ **១៤.**បានធ្វើការសម្របសម្រួលជាមួយស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសថៃ និងអាជ្ញាធរខេត្តបន្ទាយមានជ័យ ក្នុងការអន្តរគមន៍ក្នុងការបញ្ជូន និងទទួលសពពលរដ្ឋខេត្តសៀមរាប ដែលស្លាប់នៅក្នុងប្រទេសថៃបានចំនួន ០៩នាក់ ស្រី ០៣នាក់ **១៥.**លោកស្រីឧត្តមសេនីយ៍ត្រី ដួង ថាវី ស្នងការរងនគរបាលខេត្ត ជាអនុប្រធានលេខាធិការដ្ឋាន បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលសកលស្តីពី សេរីភាពពីអំពើជួញដូរមនុស្ស (Global Freedom Summit) បានចំនួន០១លើក ដែលរៀបចំដោយអង្គការមូលនិធិ អេ២១។ **១៦.**លោកស្រីប្រធានលេខាធិការដ្ឋាន និងប្រធានក្រុមការងារការពារជនរងគ្រោះ បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពីសេវាគាំទ្រជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស បានចំនួន ០១លើក នៅរាជធានីភ្នំពេញ។ |
| **ខេត្តកណ្តាល** | -ឯកឧត្តម **គង់ សោភ័ណ្ឌ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគ.ខ.ប.ជ និងលោកជំទាវ **ហ៊ិន កុសនី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ឆ្នាំ២០១៩ និងលើកទិសដៅបន្តឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ អាគារ(S)។<br>-លោកជំទាវ **ហ៊ិន កុសនី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បាន៖ ១.ចូលរួមក្នុងពិធីផ្សព្វផ្សាយគោលនយោបាយជាតិស្តីពី ប្រពន្ធ័កិច្ចការពារកុមារ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ក្រោមអធិបតីភាពឯកឧត្តម **វង្ស សូត្រ** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា។ **២.**ចូលរួមជាអធិបតីក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការរួមស្តីពី កិច្ចការពារកុមារផ្តោតលើផែនការពង្រឹងការថែទាំកុមារ និងការសមាហរណកម្មក្នុងខេត្តកណ្តាល នៅសាលប្រជុំអាគារ(C) សាលាខេត្តកណ្តាល ក្រោមអធិបតីភាព ឯកឧត្តម **គួច ចាន់នី** អគ្គនាយកបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធ |

| | |
|---|---|
| | ជន និងយុវនីតិសម្បទា។ ៣.ចូលរួមក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពី "កិច្ចការពារកុមារ អំពើជួញដូរមនុស្ស ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍" នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ ៤.បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ជំនាញផ្តល់សេវាប្រកបដោយគុណភាពដល់អ្នកផ្តល់សេវាជួរមុខ ០១លើក នៅរាជធានីភ្នំពេញ។<br>-លោកស្រីឧត្តមសេនីយ៍ត្រី **ឈឹម វណ្ណនី** ស្នងការរងនគរបាលខេត្ត បានចូលរួមសិក្ខាសាលាលើកកម្ពស់កិច្ចការពារកុមារពីការកេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ នៅខេត្តសៀមរាប ០១លើក និងសិក្ខាសាលាស្តីពី ការបង្ការ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណេត ០១លើក នៅខេត្តកែប។ |
| **ខេត្តកែប** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមសន្និសីទស្តីពី បទឧក្រិដ្ឋប្រឆាំងកុមារ ដែលរៀបចំដោយស្ថាប័ន HIS និង FBI របស់អាមេរិក នៅខេត្តសៀមរាប ០១លើក។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តនីតិវិធីស៊ើបអង្កេត សួរចម្លើយ របៀបសរសេរកំណត់ហេតុ និងការបំពេញសំណុំរឿងបញ្ជូនទៅតុលាការ ចំនួន២វគ្គ នៅស្នងការដ្ឋាននគរបាលខេត្ត។ |
| **ខេត្តតាកែវ** | - លោកស្រីអនុប្រធានអចិន្ត្រៃយ៍ លេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមចូលរួមកិច្ចប្រជុំ៖ ១.ផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ ២.ផ្សព្វផ្សាយការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ ៣៣លើក នៅបណ្តាក្រុង ស្រុក មានអ្នកចូលរួម ៩.៦០៨នាក់ ស្រី២.៩៥៤នាក់។ ៣.បានចុះពង្រឹងការងារនៅមន្ទីរកិច្ចការនារីខេត្តលើការងារផ្នែកច្បាប់ ការផ្តល់សេវាពហុវិស័យ និងជួយដល់ ជនងាយរងគ្រោះ ពិសេសស្ត្រីនិងកុមារ និងការទប់ស្កាត់ការជួញដូរមនុស្សក្នុងសម័យកូវីដ១៩ ចំនួន ០១លើក។ ៤.កិច្ចប្រជុំផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារចំនួន ០១លើក អ្នកចូលរួមចំនួន ៥៨នាក់ ស្រី ០៣នាក់។ ៥.ផ្សព្វផ្សាយផែនការសកម្មភាពសម្រាប់រយៈពេល ០៥ឆ្នាំ (២០១៩-២០២៣)ស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ចំនួន ០១លើក។ ៦.ផ្សព្វផ្សាយផែនការសកម្មភាពសម្រាប់រយៈពេល ០៥ឆ្នាំ (២០១៩-២០២៣) ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនៅទីស្តី ការក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទាចំនួន ០១លើក។<br>- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះស្រាវជ្រាវរកជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅតាមមូលដ្ឋានឃុំ សង្កាត់ចំនួន ០៥នាក់ ស្មើ ០៥លើក នៅស្រុកត្រាំកក់ គិរីវង់ បូរីជលសារ ស្រុកបាទី និងក្រុងដូនកែវ។ |
| **ខេត្តស្វាយរៀង** | - លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានអញ្ជើញ ១.ចុះសួរសុខទុក្ខប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ដែលបានធ្វើចត្តាឡីស័កចំនួន ០២កន្លែង គឺនៅសាលាបឋមសិក្សាតាសួស ឃុំត្រស់ និងសាលាបឋមសិក្សាអំពិល ឃុំអំពិល ស្រុកមេសហែក និងបាននាំយកនូវ អង្ករ ១០០គីឡូក្រាម ទឹកត្រី ទឹកស៊ីអ៊ីវ ម៉ាស អាល់កុល ក្រមា អាវយឺត សាប៊ូ មី ទឹកសុទ្ធឧបត្ថម្ភដល់ប្រជាពលរដ្ឋ ចំនួន ៤៩ នាក់ ស្រី០១ នាក់។ ២.បានចូលរួមប្រជុំ |

| | |
|---|---|
| | ផ្សព្វផ្សាយរបាយការណ៍ជាតិឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ។ ៣.បានចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពី កិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍ នៅភ្នំពេញ ០១លើក។ ៤.សិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ មានអ្នកចូលរួមចំនួន ៩០ នាក់ ស្រី ២៣នាក់។ ៥.បានដឹកនាំក្រុមការងារទាំង៦នៃគណៈកម្មាធិការប្រយុទ្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ដើម្បីអមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ក្នុងពិធីចែកអំណោយជូនដល់ប្រជាពលរដ្ឋក្នុងឃុំក្រសាំង និងឃុំអណ្តូងត្របែក ស្រុកមាសហៃក ខេត្តស្វាយរៀង ដែលមានការខ្វះខាតក្រោយពីត្រឡប់មកពីធ្វើពលករនៅតាមបណ្តាប្រទេសជិតខាង ចំនួន **១១០**គ្រួសារ ។<br>- បានបញ្ជូនមន្ត្រីនគរបាលចំនួន០៥នាក់ ស្រី០២នាក់ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងបច្ចេកទេសសម្ភាសជនរងគ្រោះដោយអំពើហឹង្សាទាក់ទងនឹងយេនឌ័រ និងការជួញដូរមនុស្ស នៅខេត្តក្រចេះ។ |
| **ខេត្តបាត់ដំបង** | - ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត បានដឹកនាំចូលរួម៖ ១.កិច្ចប្រជុំបន្ទាន់ ស្តីពីការទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ចំនួន០១លើក ដែលអ្នកចូលរួមមកពីបណ្តាមន្ទីរ អង្គភាព ក្រុង ស្រុក និងយោធាវរសេនាតូចការពារព្រំដែនគោក នៅសាលាខេត្តបាត់ដំបង។ ២.កិច្ចប្រជុំពិភាក្សាដើម្បីពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា ចំនួន០១លើក នៅសាលាខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ ៣.បានអមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមពិធីបញ្ចុះបឋមសិលាសាងសង់មណ្ឌលទទួលពលករ កំរៀង នៅស្រុកកំរៀង។ ៤.សិក្ខាសាលាពិគ្រោះយោបល់ស្តីពី នីតិវិធីឆ្លើយតបចំពោះប្រជាពលរដ្ឋងាយរងគ្រោះ (ធ្វើចំណាកស្រុក និងការធ្វើសមហរណកម្ម) ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួម ៥៥នាក់។ ៥.សិក្ខាសាលាស្តីពី ការរំលឹកឡើងវិញអំពីការថែទាំជំនួស អំពីសិទ្ធិកុមារ កិច្ចការពារកុមារ និងការចូលរួមរបស់កុមារក្នុងការការពារពួកគេពីការជួញដូរមនុស្ស ទេសន្តរប្រវេសន៍ នៅសាលាស្រុកបវេល និងស្រុកថ្មគោល ដែលរៀបចំដោយអង្គការ HAGAR អ្នកចូលរួម ៧៧នាក់ ស្រី២៨នាក់។ **៦**.វគ្គបណ្តុះបណ្តាលស្តីពី «បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលាខេត្តបាត់ដំបង។ **៧**.សម្របសម្រួលវគ្គអប់រំ ស្តីពី "ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្ស " នៅឃុំស្នឹង ស្រុក បាណន់ ខេត្តបាត់ដំបង។ ៨.បានចូលរួមប្រជុំវេទិកាតុមូលជុំទី៦លើប្រធានបទ"បញ្ហាប្រឈមក្នុងការធ្វើចំណាកស្រុករបស់អនិតិជន និងការជួញដូរមនុស្ស នៅបន្ទប់ប្រជុំមេមម៉ូរីកាហ្វេខេត្តបាត់ដំបង។ ៩.សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីវិធីឆ្លើយតបចំពោះពលរដ្ឋងាយរងគ្រោះ(ការធ្វើចំណាកស្រុក និងការធ្វើសមាហរណកម្ម) ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មានអ្នកចូលរួមចំនួន ៥៥នាក់។ **១០**.ពិធីបញ្ចុះបឋមសិលាសាងសង់មណ្ឌលទទួលពលករ នៅស្រុកកំរៀង ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។<br>- លេខាធិការដ្ឋាន សហការជាមួយអង្គការ និងមន្ទីរសង្គមកិច្ច ស្វែងរកសាច់ញាតិរបស់ពលកររងគ្រោះមានផ្ទៃពោះ និងសតិមិនសូវល្អដែលត្រឡប់មកពីប្រទេសថៃឱ្យបានត្រឡប់ទៅស្រុកកំណើតនៅខេត្តតាកែវ។ |

| | |
|---|---|
| | - មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមធ្វើបទបង្ហាញស្តីពីស្ថានភាពចំណាកស្រុក និងគោលនយោបាយគាំពារពលរដ្ឋចំណាកស្រុកក្នុងកម្មវិធីវេទិកាសហគមន៍ស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការប្រឆាំងការជួញដូរមនុស្ស នៅសាលាស្រុកកំរៀង។ |
| **ខេត្តប៉ៃលិន** | - លោកស្រី **ជា លាភ** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត៖ ១.ក្នុងនាមឯកឧត្តម **ជាន់ ចាន់ធុល** អភិបាលខេត្ត បានសម្របសម្រួលដល់ពលករដែលបានចូលតាមច្រកខ្សែម និងច្រកព្រំ ០២លើក មនុស្សចំនួន ៧១ នាក់ ស្រី ១៥នាក់ ក្មេង ០៧នាក់ និងបានរៀបចំមធ្យោបាយធ្វើដំណើរ និងចំណីអាហារមួយចំនួន ដើម្បីបញ្ជូនពួកគាត់ត្រឡប់ទៅស្រុកកំណើតវិញ។ ២.បានចូលរួមកិច្ចប្រជុំ ស្តីពីការឆ្លើយតបចំពោះប្រជាពលរដ្ឋងាយរងគ្រោះ(ការធ្វើចំណាកស្រុក និងការធ្វើសមាហរណកម្ម) និងពិធីបញ្ចុះបឋមសិលាសាងសង់មណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសណ្ឋាគារក្លាស៊ី &ស្ប៉ា ខេត្តបាត់ដំបង ។ ៣.ជួបពិភាក្សាជាមួយអភិបាលខេត្តចាន់បុរី ប្រទេសថៃ ស្នើសុំជួយសម្របសម្រួលសមត្ថកិច្ចភាគីថៃ ដែលពាក់ព័ន្ធអនុញ្ញាតដំណើរការចេញ-ចូល ទាំងមនុស្ស មធ្យោបាយ និងទំនិញ។ ៥.ចុះត្រួតពិនិត្យការវិលត្រឡប់របស់ពលករខ្មែរ តាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ និងច្រករបៀង (តាមអូរ តាមព្រៃ) ដោយមានការសហការចូលរួមពីកម្លាំងប៉ុស្តិ៍ កម្លាំងស្ថាប័នពាក់ព័ន្ធនានា។ ៦.អោយក្រុមការងារចុះ ដកហូតកុមារីឈ្មោះ ធាត សំណាង អាយុ ១៥ឆ្នាំ យកមកកន្លែងមានសុវត្ថិភាពមួយរយៈជាបណ្តោះអាសន្ន ដើម្បីស្រាវជ្រាវរកការពិត។ ៧.បានរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍១០ខែ ឆ្នាំ២០២០ របស់គ.ខ.ប.ជ ០១លើក អ្នកចូលរួម ២៨នាក់ ស្រី០៨នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - លោកជំទាវភិបាលរង និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានចូលរួមពិធីសំណេះសំណាល និងចែកអំណោយដល់ពលករចំណាកស្រុក និងជនងាយរងគ្រោះ ក្រោមអធិបតីភាព៖ ១. លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជចំនួន ៣លើកនៅ(ក្រុងកំពង់ឆ្នាំង ស្រុកសាមគ្គីមានជ័យ និងស្រុកបរិបូណ៌ )។២.ឯកឧត្តម **ឈួរ ច័ន្ទឿន** គណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការ គ.ខ.ប.ជខេត្ត នៅស្រុកទាំង ៨។ |
| **ខេត្តកំពង់ស្ពឺ** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងក្មេងស្រី ០១លើក នៅមន្ទីរកិច្ចការនារីខេត្ត អ្នកចូលរួម ៣៤នាក់ ស្រី ២៨នាក់។ |
| **ខេត្តព្រះសីហនុ** | - លោកជំទាវភិបាលរង និងជាប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ |

| | |
|---|---|
| | - លោកជំទាវភិបាលរង និងជាប្រធានលេខាធិការដ្ឋាន ព្រមទាំងក្រុមការងារ និងអង្គការយែរកម្ពុជា បានជួបពិភាក្សារកស្រុកគោលដៅដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយទប់ស្កាត់ការចំណាកស្រុកដោយសុវត្ថិភាព អំពើហិង្សាក្នុងគ្រួសារ និងអំពើជួញដូរមនុស្ស។<br>- ក្រុមការងារលេខាធិការដ្ឋាន បានដឹកនាំកិច្ចប្រជុំឆមាសទី១ របស់ គ.ខ.ប.ជ និងបានផ្សព្វផ្សាយពីផែនការសកម្មភាពដល់ក្រុមការងារអន្តរជំនាញ មានអ្នកចូលរួម ៥២នាក់ ស្រី ២៨នាក់។ |
| **ខេត្តកំពង់ធំ** | លោកជំទាវភិបាលរង និងជាប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំ៖ ១.ផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ ២.និងជំរុញដល់សមាជិក គ.ក.ស.ក និងក្រុមប្រឹក្សាឃុំជាស្ត្រី ដែលមានការកិច្ចត្រូវចុះទៅតាមបណ្តាភូមិ ឃុំ ដើម្បីផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស នៅសាលាស្រុកប្រាសាទបល្ល័ង្គ អ្នកចូលរួមចំនួន២៧នាក់ ស្រី២៥នាក់។ ៣.សហការជាមួយអង្គការIJM ចុះប្រមូលព័ត៌មានពលករចំណាកស្រុក ដែលមកពីធ្វើការលើទូកនេសាទនៅប្រទេសថៃ នៅស្រុកប្រាសាទសំបូរ ០១លើក។ ៤.បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញស្តីពី ការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ០១លើក នៅខេត្តសៀមរាប។ ៥.បានចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពី កិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍ ០១លើក នៅរាជធានីភ្នំពេញ។<br>- ក្រុមការងារជំនាញបានចូលរួមប្រជុំពិភាក្សាស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារប្រចាំឆ្នាំ២០១៩ ក្រោមអធិបតីភាព លោកជំទាវនាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សហការជាមួយអង្គការIOM បានចុះសួរសុខទុក្ខ និងចែកអំណោយដល់ពលករដែលបានវិលត្រឡប់ពីក្រៅប្រទេស ចំនួន ១១៨នាក់។ |
| **ខេត្តកំពង់ចាម** | - ឯកឧត្តម **អ៊ុន ចាន់ដា** អភិបាល នៃគណៈអភិបាលខេត្ត និងឯកឧត្តម **វង្ស ប៊ុនវិសុទ្ធ** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម បានអញ្ជើញជាអធិបតីបើកសិក្ខាសាលាស្តីពី "កិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងសំណុំរឿងជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ" នៅស្រុកចំនួន ០៣ (ស្រុកស្ទឹងត្រង់ ស្រុកកងមាស និងស្រុកចំការលើ)ដែលជាស្រុកគោលដៅមានប្រជាជនធ្វើចំណាកស្រុក និងធ្លាក់ក្នុងអន្ទាក់រងគ្រោះក្នុងអំពើជួញដូរមនុស្ស។<br>- លោកជំទាវ **ប៉ាង ដានី** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានប្រឆាំងអំពើជួញដូរមនុស្សបានចូលរួម៖ ១. សិក្ខាសាលាថ្នាក់ជាតិ ស្តីពី"កិច្ចការពារកុមារពីអំពើជួញដូរមនុស្ស ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍" នៅរាជធានីភ្នំពេញ។ ២.កិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ ៣.វគ្គបណ្តុះបណ្តាលស្តីពី យុទ្ធសាស្ត្រក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក្នុងវិស័យនេសាទនៅប្រទេសថៃ ០១លើក អ្នកចូលរួម ២៧នាក់ ស្រី១៩នាក់។ ៤.ពិធីផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមកិច្ច នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ៥.សិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត របស់អង្គការ IOM នៅសណ្ឋាគារ អិល ប៊ី អិន ខេត្តកំពង់ចាម។ ៦.ប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្តីពីការលើកកម្ពស់សុវត្ថិភាព និងកិច្ចការពារពលករនេសាទនៅប្រទេសថៃ ទៅលើកិច្ច គាំទ្រសេវាកម្មផ្នែកច្បាប់ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស នៅពេលដែលមានបញ្ហា មានអ្នកចូលរួម ១៣នាក់ ស្រី ០៥នាក់។ ៧.កិច្ចប្រជុំពិភាក្សាការងារជាមួយតំណាងអង្គការពលកម្ម |

| | |
|---|---|
| | អន្តរជាតិ អំពីបញ្ហាប្រឈមរបស់ពលករដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសក្រៅ និងការគ្រប់គ្រងស្ថិតិពលករតាមមូលដ្ឋាន ០១លើក។ ៨.សួរសុខទុក្ខ និងចែកអំណោយ ព្រមទាំងបានផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់ការរីករាលដាននៃជំងឺកូវីដ១៩ ដល់ពលករ ចំណូលស្រុក នៅស្រុកចំការលើក និងស្រុកស្ទឹងត្រង់ ចំនួន៥០គ្រួសារ ដែលបានឧបត្ថម្ភដោយអង្គការ ILO។ |
| ខេត្តត្បូងឃ្មុំ | - ចូលរួមកម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ "ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមសិក្ខាសាលាស្តីពី ការឆ្លើយតបអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណេត ០១លើក នៅខេត្តកែប។<br>- បានចូលរួមធ្វើបទបង្ហាញដល់វគ្គបណ្តុះបណ្តាលស្តីពី ការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត នៅស្រុកក្រូចឆ្មារ ស្រុកអូររាំងឪ សិក្ខាកាមចូលរួមសរុប ៤៤នាក់ ស្រី០៧នាក់ ដោយទទួលបានការឧបត្ថម្ភគាំទ្រដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ក្នុងការសម្ភាសន៍ កំណត់អត្តសញ្ញាណជនរងគ្រោះ រយៈពេល ០៣ថ្ងៃ ដោយទទួលបានការឧបត្ថម្ភគាំទ្រពីអង្គការសម្ព័ន្ធចាប់ដៃ។<br>- បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការសង្គ្រោះបឋមផ្នែកចិត្តសាស្ត្រ និងការត្រៀមខ្លួនរបស់សហគមន៍ នៅសណ្ឋាគារ LNB Asian ខេត្តកំពង់ចាម ដោយមានការឧបត្ថម្ភ និងរៀបចំដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM)។<br>- មន្ត្រីបង្គោលនៃមន្ទីរសង្គមកិច្ច បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី ការឆ្លើយតបអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធ អ៊ិនធឺណិត នៅសណ្ឋាគារ សង្គហៈមិត្ត ខេត្ត កែប។ |
| ខេត្តក្រចេះ | - ប្រធានលេខាធិការដ្ឋានខេត្តបានចូលរួម៖ ១.កម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ "ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ ២.វគ្គបណ្តុះបណ្តាលស្តីពី ការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណែត ដែលរៀបចំដោយអង្គការសកម្មភាពដើម្បីកុមារ Apple នៅខេត្តកែប អ្នកចូលរួមសរុបចំនួន២១នាក់ ស្រី០៦នាក់។ ៣.សិក្ខាសាលាស្តីពីការលើកកម្ពស់កុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ដែលរៀបចំក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅខេត្តសៀមរាប អ្នកចូលរួមចំនួនប្រមាណ១១០នាក់។<br>- ក្រុមការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អមដំណើរលោកជំទាវអភិបាលរងខេត្ត ទទួលបន្ទុកការងារជួញដូរមនុស្ស ទៅសួរសុខទុក្ខ៖ ១.ស្ត្រីវិលត្រឡប់មកពីប្រទេសចិន នៅមន្ទីរពេទ្យបង្អែកស្រុកឆ្លូង។ ២.បានដឹកនាំក្រុមការងារទេសន្តរប្រវេសន៍ ចុះសួរសុខទុក្ខពលករត្រឡប់ពីប្រទេសថៃ ពលករដែលចេញច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សរុបចំនួនចំនួ០៨នាក់ស្រី០២នាក់ ត្រូវបានបញ្ជូនមកខេត្តក្រចេះ។<br>- មន្ទីរកិច្ចការនារីខេត្ត បានសហការជាមួយគណៈកម្មការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជួយសង្គ្រោះស្ត្រីរងគ្រោះដោយរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយនៅប្រទេសចិន ចំនួន០២នាក់ រស់នៅភូមិឃ្សឹមក្រៅ ឃុំឃ្សឹម ស្រុកស្នួល ០១នាក់ និងភូមិស្រែជិះ ឃុំស្រែជិះ ស្រុកសំបូរ ខេត្តក្រចេះ ០១នាក់។ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត បានទំនាក់ទំនងជាមួយក្រសួងការបរទេសឲ្យគាត់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ។<br>- ស្នងការដ្ឋាននគរបាលខេត្ត សមត្ថកិច្ចជំនាញបានសហការជាមួយអាជាធរខេត្ត ស្ថានទូត និងអ្នកពាក់ព័ន្ធសង្គ្រោះជនរងគ្រោះពីប្រទេសចិនអោយបានត្រឡប់មកដល់ស្រុកកំណើតវិញ ចំនួន០១នាក់។ |

| | |
|---|---|
| | - លោកស្រី **ខាំ សុភាព** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជខេត្តបានដឹកនាំក្រុមការងារបានអញ្ជើញចុះសួរសុខទុក្ខ៖ ១.ពលករត្រឡប់ពីថៃ ត្រូវបានរដ្ឋបាលខេត្តក្រចេះ ដាក់នៅដោយឡែកចំនួន១៤ថ្ងៃដែលមកស្នាក់នៅតាមជានសុខភាពបណ្តោះអាសន្ននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ ២.ស្ត្រីវិលត្រឡប់មកពីប្រទេសចិន នៅមន្ទីរពេទ្យបង្អែកស្រុកឆ្លូង។ ៣. និងសិក្សាស្រាវជ្រាវពីនារីខ្មែរកំពុងរស់នៅប្រទេសចិនតាមការសាកសួរពីម្តាយនារីរងគ្រោះ និងនារីរងគ្រោះផ្ទាល់បានឲ្យដឹងថានារីទាំង០៨នាក់ ក្នុងនោះមាន(នារី៤នាក់ទៀតបានឆ្លងដែនដោយខុសច្បាប់តាមវៀតណាម ក្នុងចំណោមនារីទាំង៤នាក់ មាននារី២នាក់បានលួចរត់វិលត្រឡប់មកដល់ខេត្តក្រចេះ និងមាននារីម្នាក់ទៀតកំពុងរស់នៅដោយខុសច្បាប់នៅប្រទេសចិន ព្រមទាំងនារីម្នាក់ទៀតបានបាត់ខ្លួននៅព្រំដែនចិនវៀតណាម ពេលឆ្លងដែនខុសច្បាប់ត្រឡប់មកស្រុកខ្មែរវិញ។ ៤. និងបានដឹកនាំក្រុមការងារកិច្ចសហការប្រតិបត្តិការអន្តរជាតិជួយធ្វើពាក្យបណ្តឹងនិងកិច្ចសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃដើម្បីស្រាវជ្រាវនិងអន្តរាគមន៍លើករណីដែលលោកស្រីរិទ្ធ មិនា វិលត្រឡប់ពីប្រទេសចិន ហើយបាត់ដំណឹងនៅតាមផ្លូវ និងលោកស្រីកន សុផាត រស់នៅប្រទេសចិនខុសច្បាប់ចង់វិលត្រឡប់មកខ្មែរវិញដោយសារប្តីធ្វើបាប។ និងបានបាត់ដំណឹង លោកស្រី រិទ្ធ មិនា ត្រូវអាជ្ញាធរវៀតណាមចាប់ខ្លួននាង បញ្ជូនទៅប្រទេសចិនហើយនាងបានជាប់គុកនៅទីនោះរយៈពេលប្រាំខែ ក្រោមការជួយអន្តរាគមន៍ពីសំណាក់ស្ថានទូត នៅខេត្តណាននីង នាងបានត្រឡប់មកស្រុកវិញដោយស្របច្បាប់កាលពីថ្ងៃទី០៨ ខែសីហាឆ្នាំ២០២០។ |
| **ខេត្តស្ទឹងត្រែង** | - ចូលរួមកម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ "ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចាត់កម្លាំងជំនាញចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការសម្ភាសន៍ និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស រយៈ៥ថ្ងៃ នៅខេត្តក្រចេះ។<br>- ក្រុមការងារក្រុង-ស្រុកបានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន ០៣លើក។<br>- ស្នងការដ្ឋាននគរបាលខេត្តបានចាត់កម្លាំងជំនាញចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការសម្ភាសន៍ និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស រយៈ៥ថ្ងៃ នៅខេត្តក្រចេះ អ្នកចូលរួម ៥៥នាក់ ស្រី២៦នាក់។ |
| **ខេត្តព្រៃវែង** | - លោកជំទាវ **លៀង ស្រីម៉ុល** អភិបាលរងខេត្ត និងជាប្រធានលេខាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានអញ្ជើញ៖ ១.ជាអធិបតីក្នុងកិច្ចប្រជុំពិភាក្សាកិច្ចសហប្រតិបត្តិការក្នុងបរិបទ "ប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩" ជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) ដែលមានអ្នកចូលរួមចំនួន១៦នាក់។ ២.ជាអធិបតីក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (ជ.ច.ក.ស) ដើម្បីលើកកម្ពស់សុវត្ថិភាព និងកិច្ចការពារដល់ពលករនេសាទដែលធ្វើការនៅប្រទេសថៃ ទៅលើកិច្ចគាំទ្រសេវាកម្មផ្នែកច្បាប់ទាំ នៅពេលដែលមានបញ្ហា ដែលមានអ្នកចូលរួមចំនួន ០៩នាក់ ស្រី០៤នាក់។ ៣.ចូលរួមកម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ "ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ ៤.ចូលរួមជាអធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឱ្យដំណើការជាផ្លូវការគម្រោង "សហគមន៍មានសុវត្ថិភាពសម្រាប់កុមារ" ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង អនុវត្តដោយអង្គការWoman ក្រោមការឧបត្ថម្ភរបស់អង្គការឆាលហ្វាន់កម្ពុជា មានអ្នកចូលរួមសរុបចំនួន៦២នាក់ ស្រី១៨នាក់។ ៥.ចូលរួមជាអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់សេចក្តី ព្រាងគោលនយោបាយជាតិស្តីពី "សុខភាពទេសន្តរប្រវេសន៍" នៅសាលប្រជុំសាលាខេត្ត។ ៦.ចូលរួមក្នុងវេទិកាពិភាក្សាលើកកម្ពស់សមត្ថភាពយុវជន និងសហគ្រិន ក្រោមប្រធានបទ ការជំរុញ |

| | |
|---|---|
| | សហគ្រិនវ័យក្មេងក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មមានអ្នកចូលរួមចំនួន ៤២៨នាក់។ ៧.ជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបបាយការណ៍ប្រចាំឆ្នាំ២០២០ និងទិសដៅឆ្នាំបន្ត របស់លេខាធិការដ្ឋានគ.ខ.ប.ជ មានអ្នកចូលរួមចំនួន ៣៣នាក់ ស្រី១៥នាក់។<br>- មន្ត្រីលេខាធិការដ្ឋានខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី មូលដ្ឋានគ្រឹះសេវាសង្គមកិច្ច និងប្រព័ន្ធគាំទ្រពលករនៅតាមមណ្ឌលចត្តាឡីស័ក ដែលរៀបចំដោយអង្គការ IOM នៅស្រុកពារាំង ខេត្តព្រៃវែង មានអ្នកចូលរួមចំនួន២៧នាក់។<br>- លេខាធិការដ្ឋានខេត្ត ស្នងការនគរបាលខេត្ត មន្ទីរសុខាភិបាលខេត្ត មន្ទីរការងារ មន្ទីរសង្គមកិច្ច មន្ទីរកិច្ចការនារី បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញសម្រាប់សេវាប្រកបដោយគុណភាពដល់អ្នកផ្តល់សេវាជួរមុខ រយៈពេល០៣ថ្ងៃ នៅសណ្ឋាគារសាន់វេ ភ្នំពេញ។<br>- មន្ត្រីលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចូលរួមជាអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់លើ សេចក្តីព្រាងគោលនយោបាយជាតិស្តីពី សុខភាពទេសន្តរប្រវេសន៍ នៅសាលប្រជុំសាលាខេត្ត។ |

## ឧបសម្ព័ន្ធ(១)

### លទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំឆ្នាំ២០២០)

គិតចាប់ពីថ្ងៃទី ០១-០១-២០២០ ដល់ថ្ងៃទី ៣១-១២-២០២០

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | បង្ក្រាបរួម | | | | | | | | ជួញដូរមនុស្ស | | | | | | | | អាជីវកម្មផ្លូវភេទ | | | | | | | | បញ្ជូនជនរងគ្រោះទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនល្មើស | | | ជនរងគ្រោះ | | | | ករណីបង្ក្រាប | ជនល្មើស | | | ជនរងគ្រោះ | | | | ករណីបង្ក្រាប | ជនល្មើស | | | ជនរងគ្រោះ | | | | មជ្ឈមណ្ឌលសង្គមកិច្ច | អង្គការ | គ្រួសារ |
| | | | សរុប | ស្រី | បរទេស | សរុប | -15 | 15-17 | 18+ | | សរុប | ស្រី | បរទេស | សរុប | -15 | 15-17 | 18+ | | សរុប | ស្រី | បរទេស | សរុប | -15 | 15-17 | 18+ | | | |
| 1 | នាយកដ្ឋាន | 10 | 20 | 8 | 6 | 56 | 4 | 12 | 40 | 4 | 6 | 3 | 2 | 19 | 2 | | 17 | 6 | 14 | 5 | 4 | 37 | 2 | 12 | 23 | 32 | | 24 |
| 2 | នាយកដ្ឋានប្រឆ.ប.បច្ចេកវិទ្យា | 3 | 3 | | | | | | | | | | | | | | | 3 | 3 | | | | | | | | | |
| 3 | បន្ទាយមានជ័យ | 12 | 12 | | | 28 | 6 | | 22 | 6 | 6 | | | 22 | | | 22 | 6 | 6 | | | 6 | 6 | | | | | 28 |
| 4 | បាត់ដំបង | 29 | 32 | 1 | | 70 | 28 | 4 | 38 | 5 | 7 | 1 | | 46 | 4 | 4 | 38 | 24 | 25 | | | 24 | 24 | | | | | 70 |
| 5 | កំពង់ចាម | 10 | 11 | 5 | | 45 | 6 | 7 | 32 | 5 | 6 | 5 | | 40 | 1 | 7 | 32 | 5 | 5 | | | 5 | 5 | | | | | 45 |
| 6 | កំពង់ឆ្នាំង | 2 | 2 | | | 2 | 2 | | | 1 | 1 | | | 1 | 1 | | | 1 | 1 | | | 1 | 1 | | | | | 2 |
| 7 | កំពង់ស្ពឺ | 3 | 3 | | | 4 | 2 | | 2 | | | | | | | | | 3 | 3 | | | 4 | 2 | | 2 | | | 4 |
| 8 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 9 | កំពត | 1 | 1 | | | 1 | 1 | | | | | | | | | | | 1 | 1 | | | 1 | 1 | | | | | 1 |
| 10 | កណ្ដាល | 12 | 13 | 1 | 1 | 19 | 14 | 3 | 2 | 1 | 1 | | 1 | 2 | 2 | | | 11 | 12 | 1 | | 17 | 12 | 3 | 2 | 6 | | 13 |
| 11 | កោះកុង | 1 | 1 | | | 1 | 1 | | | | | | | | | | | 1 | 1 | | | 1 | 1 | | | | | 1 |
| 12 | ក្រចេះ | 5 | 5 | | | 7 | 7 | | | 1 | 1 | | | 1 | 1 | | | 4 | 4 | | | 6 | 6 | | | | | 7 |
| 13 | មណ្ឌលគិរី | 3 | 3 | 1 | | 3 | 3 | | | 1 | 1 | 1 | | 1 | 1 | | | 2 | 2 | | | 2 | 2 | | | | | 3 |
| 14 | ភ្នំពេញ | 4 | 4 | 1 | | 12 | 2 | 2 | 8 | | | | | | | | | 4 | 4 | 1 | | 12 | 2 | 2 | 8 | 9 | | 3 |
| 15 | ព្រះវិហារ | 4 | 4 | | | 4 | 4 | | | | | | | | | | | 4 | 4 | | | 4 | 4 | | | | | 4 |
| 16 | ព្រៃវែង | 5 | 5 | | | 5 | 5 | | | | | | | | | | | 5 | 5 | | | 5 | 5 | | | | | 5 |
| 17 | ពោធិ៍សាត់ | 6 | 6 | | | 8 | 8 | | | | | | | | | | | 6 | 6 | | | 8 | 8 | | | | | 8 |
| 18 | រតនគិរី | 2 | 2 | | | 2 | 2 | | | | | | | | | | | 2 | 2 | | | 2 | 2 | | | | | 2 |
| 19 | សៀមរាប | 15 | 22 | 7 | 2 | 106 | 20 | 8 | 78 | 9 | 13 | 4 | 1 | 79 | 16 | 2 | 61 | 6 | 9 | 3 | 1 | 27 | 4 | 6 | 17 | 51 | | 55 |
| 20 | ព្រះសីហនុ | 4 | 9 | 2 | 5 | 17 | 2 | | 15 | | | | | | | | | 4 | 9 | 2 | 5 | 17 | 2 | | 15 | | | 17 |
| 21 | ស្ទឹងត្រែង | 2 | 2 | | | 2 | 2 | | | | | | | | | | | 2 | 2 | | | 2 | 2 | | | | | 2 |
| 22 | ស្វាយរៀង | 8 | 8 | | | 27 | 3 | | 24 | 5 | 5 | | | 24 | | | 24 | 3 | 3 | | | 3 | 3 | | | | | 27 |
| 23 | តាកែវ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | ឧត្តរមានជ័យ | 4 | 6 | 1 | | 39 | 4 | | 35 | 3 | 5 | 1 | | 38 | 3 | | 35 | 1 | 1 | | | 1 | 1 | | | | | 39 |
| 25 | កែប | | | | | | | | | | | | | | | | | | | | | | | | | | | |
| 26 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | | | | |
| 27 | ត្បូងឃ្មុំ | 2 | 2 | 1 | | 1 | | 1 | | 1 | 1 | 1 | | 1 | | 1 | | 1 | 1 | | | | | | | | | 1 |
| 28 | កងរាជអាវុធហត្ថ | 8 | 17 | 2 | 9 | 8 | 4 | 2 | 2 | 2 | 2 | 1 | | 2 | | 2 | | 6 | 15 | 1 | 9 | 6 | 4 | | 2 | | | 8 |
| | សរុបរួម | 155 | 193 | 30 | 23 | 467 | 130 | 39 | 298 | 44 | 55 | 17 | 4 | 276 | 31 | 16 | 229 | 111 | 138 | 13 | 19 | 191 | 99 | 23 | 69 | 98 | | 369 |

**ឧបសម្ព័ន្ធ (១)**

**លទ្ធផលបង្ក្រាបបទល្មើស ជួញដូរមនុស្ស ធ្វើអាជីវកម្មផ្លូវភេទ (ប្រចាំឆ្នាំ២០២០)**

**គិតចាប់ពីថ្ងៃទី ០១-០១-២០២០ ដល់ថ្ងៃទី ៣១-១២-២០២០**

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | មាត្រា១៥ អំពើលក់ដូរមនុស្ស | | | | | | មាត្រា១៩ ការទទួលយកមនុស្ស ដោយមានគោលដៅ | | | | | | មាត្រា២០ ការទទួលយកមនុស្ស ដោយមានគោលដៅដូច ដល់ជនល្មើស | | | | | | មាត្រា៣៤ ការទិញពេស្យាចារកុមារ | | | | | | មាត្រា៣៥ អំពើអូសទាញពេស្យាចារកុមារ | | | | | | មាត្រា៣៦ ការអោយខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ | | | | | | មាត្រា៣៧ កិច្ចសន្យានៃអំពើពេស្យាចារកុមារ | | | | | | មាត្រា៤៥ កិច្ចសន្យាសំរាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | | | | | | ជនរងគ្រោះបញ្ជូនទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | បង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | ម.សង្គមកិច្ច | អង្គការ | គ្រួសារ |
| | | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | -15 | 15-17 | 18+ | ប | ស | | | |
| 1 | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 22 |
| 2 | បាត់ដំបង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 46 |
| 3 | កំពង់ចាម | 1 | 1 | 5 | 31 | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 40 |
| 4 | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | | | 1 | 1 | | | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | 1 |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | កំពត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 8 | កណ្ដាល | | | | | | | | | | | | | | | | | | | 1 | 2 | | | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | 2 |
| 9 | កោះកុង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | | 1 | 1 | | | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | 1 |
| 11 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 |
| 12 | ភ្នំពេញ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 13 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 14 | ព្រៃវែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 17 | សៀមរាប | | | | | | | | | | | | | | | | | | | 1 | 4 | | | 1 | | | | | | | | | | | | | | | | | | | | | | | | | | 30 | | 49 |
| 18 | ព្រះសីហនុ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 24 |
| 21 | តាកែវ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 22 | ឧត្ដរមានជ័យ | | | | | | | | | | | | | 1 | | | 10 | 2 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 38 |
| 23 | កែប | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 25 | នាយកដ្ឋាន | | | | | | | | | | | | | | | | | | | 1 | 1 | | | 1 | 1 | | | | | | | | | | | | | | | | | | | | | | | | | | | 19 |
| 26 | កងរាជអាវុធហត្ថ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 2 |
| 27 | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 |
| | **សរុបរួម** | 1 | 1 | 5 | 31 | 1 | | | | | | | | 1 | | | 10 | 2 | | 5 | 9 | | | 5 | 1 | | | | | | | | | | | | | | | | | | | | | | | | | 30 | | 246 |

## ឧបសម្ព័ន្ធ (១)

### លទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំឆ្នាំ២០២០)
### គិតពីថ្ងៃទី ០១-០១-២០២០ ដល់ថ្ងៃទី ៣១-១២-២០២០

| ល.រ | ប្រភេទបទល្មើស | មាត្រា | ផ្ដន្ទាទោស | ករណី | ជនល្មើស | | | | ជនរងគ្រោះ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ប្រុស | ស្រី | បរទេស | | សរុប | | -១៥ | | ១៥-១៧ | | ១៨+ | | នីតិវិធី | | |
| | | | | | | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | សង្គមកិច្ច | អង្គការ | គ្រួសារ |
| I | **ជួញដូរមនុស្ស** | | | 44 | 55 | 17 | 4 | | 276 | 97 | 31 | 17 | 16 | 9 | 229 | 71 | 30 | | 246 |
| 1 | ការនាំយកអនីតិជន ដោយមិនស្របច្បាប់ | មាត្រា៨ | ២-៥ | 5 | 5 | 1 | | | 6 | 6 | 3 | 3 | 3 | 3 | | | | | 6 |
| 2 | ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | មាត្រា១០ | ៧-១៥/១៥-២០ | 6 | 6 | 3 | | | 33 | 3 | 9 | 1 | 1 | 1 | 23 | 1 | 9 | | 24 |
| 3 | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | មាត្រា១១ | ៧-១៥/១៥-២០ | 22 | 29 | 7 | | | 162 | 71 | 7 | 4 | 6 | 4 | 149 | 63 | 21 | | 141 |
| 4 | ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | មាត្រា១២ | ៧-១៥/១៥-២០ | 3 | 5 | 4 | 1 | | 18 | 2 | 1 | 1 | 1 | 1 | 16 | | | | 18 |
| 5 | អំពើលក់ដូរមនុស្ស | មាត្រា១៤ | ២-៥ | | | | | | | | | | | | | | | | |
| 6 | អំពើលក់ដូរមនុស្សដោយមានគោលដៅ | មាត្រា១៥ | ៧-១៥/១៥-២០ | 1 | 1 | 1 | | | 1 | 1 | 1 | 1 | | | | | | | 1 |
| 7 | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | មាត្រា១៦ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 8 | ការដឹកជញ្ជូនដោយមានគោលដៅ | មាត្រា១៧ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 9 | អំពើនាំឆ្លងដែន | មាត្រា១៨ | ៧-១៥/១៥-២០ | 1 | 1 | | | | 37 | 3 | 1 | | 5 | | 31 | 3 | | | 37 |
| 10 | ការទទួលយកមនុស្សដោយមានគោលដៅ | មាត្រា១៩ | ៧-១៥/១៥-២០ | | | | | | | | | | | | | | | | |
| 11 | ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | មាត្រា២០ | ២-៥/៥-១០ | 1 | 2 | | | | 10 | 4 | | | | | 10 | 4 | | | 10 |
| 12 | ការទិញពេស្យាចារកុមារ | មាត្រា៣៤ | ២-៥/៧-១៥ | 5 | 6 | 1 | 3 | | 9 | 7 | 9 | 7 | | | | | | | 9 |
| 13 | អំពើអូសទាញពេស្យាចារកុមារ | មាត្រា៣៥ | ២-៥/៥-១០ | | | | | | | | | | | | | | | | |
| 14 | ការអោយខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ | មាត្រា៣៦ | ៥-១០ | | | | | | | | | | | | | | | | |
| 15 | កិច្ចសន្យានៃអំពើពេស្យាចារកុមារ | មាត្រា៣៧ | ៥-១០ | | | | | | | | | | | | | | | | |
| 16 | កិច្ចសន្យាសំរាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | មាត្រា៤៥ | | | | | | | | | | | | | | | | | |
| II | **អាជីវកម្មផ្លូវភេទ** | | | 108 | 135 | 13 | 19 | 3 | 191 | 189 | 99 | 99 | 23 | 23 | 69 | 67 | 68 | | 123 |
| 1 | ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | មាត្រា២១ | ៣-៥/៥-១០ | 1 | 9 | 1 | 9 | 1 | 1 | | | | | | 1 | | | | 1 |
| 2 | ស្ថានទម្ងន់ទោស(ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | មាត្រា២២ | ១ជីវិត | | | | | | | | | | | | | | | | |
| 3 | អំពើអូសទាញសញ្ចារកម្ម | មាត្រា២៤ | ១ថ្ងៃ-៦ថ្ងៃ | | | | | | | | | | | | | | | | |
| 4 | សញ្ចារកម្ម | មាត្រា២៦ | ២-៥ | 6 | 12 | 4 | 5 | 1 | 35 | 35 | 1 | 1 | 7 | 7 | 27 | 27 | 19 | | 16 |
| 5 | ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | មាត្រា២៧ | ៥-១០ | 4 | 10 | 3 | 4 | 1 | 25 | 25 | 1 | 1 | 6 | 6 | 18 | 18 | 20 | | 5 |
| 6 | សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | មាត្រា២៨ | ៧-១៥ | 2 | 3 | 2 | | | 19 | 19 | | | 5 | 5 | 14 | 14 | 19 | | |
| 7 | សញ្ចារកម្មដោយមានការធ្វើទារុណកម្ម | មាត្រា២៩ | ១០-២០ | | | | | | | | | | | | | | | | |
| 8 | ការដឹកនាំពេស្យាចារ | មាត្រា៣០ | ២-៥ | | | | | | | | | | | | | | | | |
| 9 | ការដឹកនាំគ្រឹះស្ថានពេស្យាចារ | មាត្រា៣១ | ២-៥ | | | | | | | | | | | | | | | | |
| 10 | ការផ្ដល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | មាត្រា៣២ | ២-៥ | 1 | 1 | 1 | | | 4 | 4 | | | 1 | 1 | 3 | 3 | 4 | | |
| 11 | បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | មាត្រា៣៣ | ៧-១៥ | 1 | 2 | 1 | | | 6 | 5 | 1 | 1 | 3 | 3 | 2 | 1 | 6 | | |
| 12 | រូបភាព និងសម្ភារៈអាសអាភាស | មាត្រា៣៩ | ៧ថ្ងៃ-១ខែ/១ខែ-១ឆ្នាំ | 4 | 7 | 1 | | | 6 | 6 | 1 | 1 | 1 | 1 | 4 | 4 | | | 6 |
| 13 | រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | មាត្រា៤១ | ២-៥/៥-១០/១០-២០ | 1 | 1 | | | | 3 | 3 | 3 | 3 | | | | | | | 3 |
| 14 | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | មាត្រា៤២ | ៥-១០ | 71 | 73 | | | | 72 | 72 | 72 | 72 | | | | | | | 72 |
| 15 | អំពើអាសប្រាតនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | មាត្រា៤៣ | ១-៣ | 17 | 17 | | 1 | | 20 | 20 | 20 | 20 | | | | | | | 20 |
| | **សរុបរួម** | | | 152 | 190 | 30 | 23 | 3 | 467 | 286 | 130 | 116 | 39 | 32 | 298 | 138 | 98 | | 369 |

# ឧបសម្ព័ន្ធទី២
## ការចាត់សិក្ខាសាលា

### អន្តរក្រសួង ស្ថាប័ន លេខាធិការដ្ឋានរាជធានី ខេត្ត សហការ និងរៀបចំសិក្ខាសាលា បានចំនួន ១២៥លើក មានសិក្ខាកាមសរុបចំនួន ៦.៤១៦នាក់ ស្រី ៣៩៥នាក់

| ស្ថាប័ន | សកម្មភាព |
|---|---|
| គ.ជ.ប.ជ និងអន្តរក្រសួង ស្ថាប័ន សហការគ្នា បានរៀបចំសិក្ខាសាលា បានចំនួន ១១៦លើក មានសិក្ខាកាមចំនួន ៦.០១៨នាក់ ស្រី ២៩០នាក់ | |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ សហការជាមួយអង្គការដៃគូរៀបចំសិក្ខាសាលាចំនួន ០៧លើក ដែលមានសិក្ខាកាមចូលរួមសុបចំនួន ១៤៦នាក់ ស្រី ២៥នាក់ រួមមាន៖<br>○ **អង្គការ IOM រៀបចំសិក្ខាសាលា** ចំនួន **០៤លើក** គឺ៖ ១. សិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់លើកទី២ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេសបញ្ជូន (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) មានសិក្ខាកាមចំនួន ៦១នាក់។ ២. សិក្ខាសាលាថ្នាក់ជាតិកម្រិតជំនាញ ដើម្បីការត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ កម្រិតថ្នាក់ដឹកនាំស្តីពី "កតិកាសញ្ញាសកល សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់" សិក្ខាកាមចូលរួមចំនួន ៣៣នាក់ (ស្រី ១២នាក់) នៅសណ្ឋាគារភ្នំពេញ។ ៣. សិក្ខាសាលាពិគ្រោះយោបល់ ស្តីពី "នីតិវិធីប្រតិបត្តិស្តង់ដាអន្តរទំនាក់ទំនង និងផែនការយថាភាព ស្តីពីការត្រៀមលក្ខណៈក្នុងកិច្ចសហប្រតិបត្តិការមនុស្សឆ្លងកាត់ព្រំដែន និងការឆ្លើយតប" មានសិក្ខាកាមចំនួន ៥២នាក់ ស្រី ១៣នាក់។ ៤. សិក្ខាសាលាថ្នាក់ជាតិលើកទី២ កម្រិតថ្នាក់ដឹកនាំស្តីពី "កតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេច ក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>○ **អង្គការឆាលហ្សាន់ ០១លើក** រៀបចំសិក្ខាសាលាថ្នាក់ជាតិ "ស្តីពីកិច្ចការការពារកុមារពីការជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍" កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ នៅសណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ សិក្ខាកាមចូលរួមចំនួន ៤២នាក់ ។<br>○ **អង្គការ ASEAN-ACT ០១លើក** រៀបចំសិក្ខាសាលា "ផ្ទៀងផ្ទាត់បញ្ជាក់បេកគំហើញ និងអនុសាសន៍ កំណត់ផែនទីភាគីពាក់ព័ន្ធផ្នែកសមាសភាព និងបរិយាប័ន" កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ នៅសណ្ឋាគារកាំបូឌីយ៉ាណា សិក្ខាកាមចូលរួមចំនួន ៤៥នាក់ ។<br>▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ រៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី សេវា គាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅភោជនីយដ្ឋានទន្លេបាសាក់២ សិក្ខាកាមចូលរួមចំនួន ៥៨នាក់។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ▪ បានរៀបចំសិក្ខាសាលា ចំនួន ០៥លើក ដែលមានសិក្ខាកាមចូលរួមសុបចំនួន ៣៤៨នាក់ ស្រី ១១៩នាក់ រួមមាន៖<br>១.សិក្ខាសាលាពិគ្រោះយោបល់ លើគោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ចំនួន ០២លើក ដល់មន្ត្រីសាលាស្រុក មន្ត្រីស.អ.យ ស្រុក មេឃុំ មេភូមិ មន្ត្រី គ.ក.ន.ក គ្រូបង្រៀន គ្រូពេទ្យ នគរបាលប៉ុស្តិ៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅស្រុកសូទ្រនិគម ខេត្តសៀមរាប និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានសិក្ខាកាមចំនួន ១១៣នាក់ ស្រី៤៨នាក់។ ២. សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ លើសេចក្តីព្រាងចុងក្រោយ នៃគោលការណ៍ណែនាំស្តីពី"យន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស" នៅរាជធានីភ្នំពេញ មានសិក្ខាកាមចំនួន ៩៨នាក់ ស្រី ៣៧នាក់ ដោយមានកិច្ចសហការ |

| | |
|---|---|
| | ជាមួយអង្គការ UNDP, UN-ACT, UN Women, RATANAK International, Hope for Justice។ ៣. សិក្ខាសាលាស្តីពី "ការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា និងកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស" មានសិក្ខាកាមចំនួន ៦០នាក់ ស្រី ១១នាក់ ដោយមានកិច្ចសហការជាមួយអង្គការ MOI, UN-ACT ។ ៤. សិក្ខាសាលាផ្សព្វផ្សាយនូវ នីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស(SOPs) រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដោយបានសហការជាមួយអង្គការដៃគូ មានអង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM), គម្រោងកម្មវិធីអូស្រ្តាលីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ASEAN-ACT), តេនះអ៊ិនធើណេសិនណល, ក្តីសង្ឃឹម និងយុត្តិធម៌(Hope for Justice) និងអង្គការសម្ព័ន្ធចាប់ដៃ នៅខេត្តសៀមរាប ក្រោមអធិបតីភាព ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងស.អ.យ មានសិក្ខាកាមចំនួន ៧៧នាក់ ស្រី២៣នាក់។ |
| **ក្រសួងអប់រំ យុវជន និងកីឡា** | ▪ សហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ រៀបចំសិក្ខាសាលា ចំនួន ០៥លើក ដែលមានសិក្ខាកាមចូលរួមសុបចំនួន ៤៨៣នាក់ ស្រី ១០៦នាក់ រួមមាន៖<br>○ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការដៃគូ រៀបចំសិក្ខាសាលាចំនួន ០៣លើក៖ ១.ផ្សព្វផ្សាយផែនការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ២០១៩-២០២៣ មានអ្នកចូលរួមចំនួន ១៦៥នាក់ ស្រី ២៧នាក់ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។ ២.បង្រៀនសាកល្បង និងប្រមូលធាតុចូល លើសៀវភៅសិក្សាអប់រំ និងលំនាំនៃការបង្រៀន ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សាជូនលោកគ្រូ អ្នកគ្រូឧទ្ទេស និងគរុសិស្ស នៅសាលាគរុកោសល្យខេត្តកំពង់ចាម មានអ្នកចូលរួមចំនួន ៨៤នាក់។ ៣.ស្តីពីការបង្ការ ទប់ស្កាត់អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ ក្រោមអធិបតីភាព លោកជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា មានអ្នកចូលរួមចំនួន ៣០នាក់ ស្រី ០៣នាក់ នៅ ខេត្តសៀមរាប។<br>○ អង្គការ APLE រៀបចំសិក្ខាសាលា ស្តីពី "រំលោភបំពានផ្លូវភេទកុមារតាមអ៊ីនធឺណិត" នៅខេត្តសៀមរាប មានសិក្ខាកាមចំនួន ៣០នាក់ ស្រី ០៤នាក់។<br>○ អង្គការផ្លែនអន្តរជាតិកម្ពុជា (Plan International Cambodia) រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើ "ការរៀបចំសៀវភៅសិក្សា និងលំនាំនៃការបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស" នៅខេត្តសៀមរាប និងកំពង់ចាម មានសិក្ខាកាមចូលរួមចំនួន ១៧៤នាក់ ស្រី៧២នាក់។ |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | ▪ សហការជាមួយអង្គការដៃគូរ រៀបចំសិក្ខាសាលា ចំនួន ៩៩លើក ដែលមានសិក្ខាកាមចូលរួមសុបចំនួន ៤.៨៩៦នាក់ ស្រី ៤០នាក់ រួមមាន៖<br>○ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "គោលនយោបាយទេសន្តរប្រវេសន៍ការងារ ឆ្នាំ២០១៩-២០២៣" មានអ្នកចូលរួម ៥០នាក់ ស្រី២០នាក់។<br>○ អង្គការ ពលកម្មអន្តរជាតិ (ILO) បានរៀបចំ៖ ១.សិក្ខាសាលាត្រីភាគីត្រៀមថ្នាក់ជាតិ ដើម្បីរៀបចំឯកសារសម្រាប់កម្ពុជាចូលរួមប្រជុំវេទិកាអាស៊ានលើកទី១៣ ស្តីពីការគាំទ្រពលករទេសន្តរប្រវេសន៍ក្នុង អំឡុងពេលជំងឺកូវីដ-១៩ សម្រាប់សហគមន៍អាស៊ានមួយដែលមានការឃ្លាំមើលគ្នា និងឆ្លើយតបទាន់ពេលវេលា។ ២.ពិគ្រោះយោបល់ ស្តីពី "ការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២០-២០២១ ដើម្បីអនុវត្តសកម្មភាពទាក់ទងទៅនឹងទេសន្តរប្រវេសន៍ការងារ និងការប្រយុទ្ធប្រឆាំងនិងអំពើជួញដូរមនុស្ស" មានអ្នកចូលរួម ៥០នាក់ ស្រី២០នាក់។<br>○ សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការស្វែងរកការងារធ្វើ និងបានចុះឈ្មោះអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋាន" បានចំនួន ៩៦ដង មានអ្នកចូលរួម ៤.៧៩៦នាក់។ |

| លេខាធិការដ្ឋាន គ.ខ.ប.ជ អង្គការដៃគូ បានសហការ និងរៀបចំសិក្ខាសាលា បានចំនួន ០៩លើក មានសិក្ខាមចំនួន ៣៩៨នាក់ ស្រី ១០៥នាក់ | |
|---|---|
| ខេត្តកំពង់ស្ពឺ | - បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែន" រៀបចំដោយអង្គការឃែរ និងឧបត្ថម្ភដោយអង្គការ UN Women មានសិក្ខាកាមចំនួន ៦២នាក់ ស្រី ២៤នាក់ នៅសាលាស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ |
| ខេត្តព្រះសីហនុ | - បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែន" រៀបចំដោយអង្គការឃែរ និងឧបត្ថម្ភដោយអង្គការ UN Women ដែលមានសិក្ខាកាមចូលរួមចំនួន ៥៨នាក់ ស្រី ២៦នាក់ ខេត្តព្រះសីហនុ។ |
| ខេត្តកំពង់ចាម | - លេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំសិក្ខាសាលាស្តីពី ការចែករំលែកបទពិសោធន៍ និងពង្រឹងការសហការរវាងជនបង្គោលមូលដ្ឋាន និងអង្គការសង្គមស៊ីវិល លើវិស័យសិទ្ធិការងារ របស់ពលករចំណាកស្រុក នៅសណ្ឋាគារពាមកា ខេត្តកំពង់ចាម។ |
| ខេត្តព្រៃវែង | - លេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសុខភាពទេសន្តរប្រវេសន៍ នៅសាលាខេត្តព្រៃវែង។ |
| អង្គការ APLE | - បានសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រៀបចំសិក្ខាសាលាស្តីពី "ការលើកកម្ពស់កិច្ចការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ" ក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌនៅសណ្ឋាគារខេមរាអង្គរ ខេត្តសៀមរាប ដែលមានសិក្ខាកាមចូលរួមចំនួន១២០នាក់។ |
| អង្គការ ឆាលហ្វាន់ កម្ពុជា | បានរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារពីការជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើចំណាកស្រុក ចំនួន ០២លើក ដែលមានសិក្ខាកាមចូលរួមចំនួន ១៦៨នាក់ ស្រី ៥៥នាក់ ខេត្តព្រះសីហនុ នៅគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងគណៈកម្មាធិការ គ.ខ.ប.ជខេត្ត ។ |
| អង្គការសម្ព័ន្ធចាប់ដៃ | - បានរៀបចំ៖ ១.សិក្ខាសាលាពិគ្រោះយោបល់លើការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពី ការការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីពិនិត្យតម្រូវការនៃការធ្វើបច្ចុប្បន្នភាពសៀវភៅគោលនយោបាយ និងបទដ្ឋាននេះ។ ២.សិក្ខាសាលាផ្ទៀងផ្ទាត់បញ្ជាក់ផែនទីដៃគូ និងគោលការណ៍ណែនាំ ស្តីពី ការមិនបង្កអន្តរាយ ( Do-No Harm ( DNH ) Guidelines) នៃកម្មវិធីអេ ស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT)។ |

# ឧបសម្ព័ន្ធទី៣

## ការខារៀបចំ ដឹកនាំកិច្ចប្រជុំ

### អន្តរក្រសួង ស្ថាប័ន លេខាធិការដ្ឋានរាជធានី ខេត្ត សហការ និងរៀបចំ ដឹកនាំកិច្ចប្រជុំ បានចំនួន ៤៧៦លើក មានមនុស្សសរុបចំនួន ១៥.០៩៧នាក់ ស្រី ៧.៥៦១នាក់

| ស្ថាប័ន | សកម្មភាព |
|---|---|
| **គ.ជ.ប.ជ និងអន្តរក្រសួង ស្ថាប័ន សហការ និងរៀបចំកិច្ចប្រជុំ បានចំនួន ៩៧លើក មានមនុស្សចំនួន ១.៦៨៧នាក់ ស្រី ៤៣០នាក់** | |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>(គ.ជ.ប.ជ) | ▪ បានរៀបចំ ដឹកនាំកិច្ចប្រជុំ បានចំនួន ៧៣លើក ដែលមានមនុស្សចូលរួមសុបចំនួន ៩០៨នាក់ ស្រី ១៩៣នាក់ រួមមាន៖<br>- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បី ពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាក ស្រុកក្នុងស្ថានភាពនៃជម្ងឺកូវីដ ១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- រៀបចំកិច្ចប្រជុំជាន់ខ្ពស់រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការសហប្រជាជាតិប្រចាំកម្ពុជា ស្តីពី កម្មវិធីរួមគ្នាដើម្បីគាំទ្រជនទេសន្តរប្រវេសន៍ ដែលវិលត្រឡប់ ក្នុងស្ថានភាពវិបត្តិជំងឺកូវីដ ១៩ និងផលប៉ះពាល់ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស** បានអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់៖<br>○ ក្នុងពិធីបើកកិច្ចប្រជុំផ្សព្វផ្សាយ របាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩ និងលើកទិសដៅអនុវត្ត ឆ្នាំ២០២០ របស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសភាពចូលរួមមកពីបណ្តាក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និង២៥រាជធានី-ខេត្ត និងអង្គការក្រៅរដ្ឋាភិបាល សរុបប្រមាណ **២០០**នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>○ កិច្ចប្រជុំកម្រិតតាមវីដេអូខនហ្វើរិន ជាមួយ ទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា ដើម្បីពិនិត្យលទ្ធភាពឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុក ក្នុងស្ថានភាពនៃការរីករាលដាលជម្ងឺកូវីដ ១៩។<br>○ កិច្ចប្រជុំរបាយការណ៍ឆមាសទី១ និងលើកទិសដៅអនុវត្តបន្ត ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមសរុប **៥២**នាក់ ស្រី **១៥**នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សា៖<br>○ បន្ត ស្តីពីការពិនិត្យផែនការ ឆ្នាំ២០២០ ចំនួន **០២**លើក ដើម្បីដាក់ជូនក្រសួងមហាផ្ទៃរៀបចំកម្មវិធីឆ្លងកិច្ចប្រជុំនេះ អ្នកចូលរួមចំនួន **១៣**នាក់ ស្រី **០៤**នាក់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |

| | |
|---|---|
| | ○ ពិភាក្សារៀបចំសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (C.L.M.V)។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន **ឯកឧត្តម ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងតំណាងមកពីក្រសួង ស្ថាប័ន ដៃគូឯកជនជាច្រើនរូប ដែលមានវត្តមានសរុបចំនួន ២៤នាក់ នៅសាលប្រជុំគ.ជ.ប.ជ ។<br>○ ពិភាក្សាត្រួតពិនិត្យរបាយការណ៍ឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ.ជ.ប.ជ មានអ្នកចូលរួមចំនួន **១៥**នាក់។<br>○ ពិភាក្សា ស្តីពីការពង្រឹងកិច្ចសហការរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយនឹងដៃគូអភិវឌ្ឍន៍ និងពិធីប្រគល់លិខិតថ្លែងអំណរគុណ ចំពោះកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាមួយគ.ជ.ប.ជ អស់រយៈកាល៥ឆ្នាំកន្លងមក ដល់សមាគម អង្គការជាតិ អន្តរជាតិ ចំនួន**៥៦** ក្រុមហ៊ុនឯកជន ចំនួន០៤ នៅភោជនីយដ្ឋានទន្លេបាសាក់២ ភ្នំពេញ។<br>○ ស្តីពីកិច្ចសហការក្នុងការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ ក្នុងចំណោមពលករចំណាកស្រុក និងសហគមន៍ នៅទីស្តីការក្រសួងមហាផ្ទៃ អ្នកចូលរួមមាន**៧២**នាក់ ស្រី **២៦**នាក់។<br>○ ជាសកល ស្តីពីការរួបរួមគ្នាប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ីនធឺណែត រៀបចំឡើងដោយ IJM Philippines។<br>○ ដើម្បីពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា នៅខេត្តបន្ទាយមានជ័យ។<br>○ ស្តីពីផែនការក្នុងការអនុវត្តកម្មវិធីរួមគ្នា ជួយគាំទ្រដល់ពលករទេសន្តរ ប្រវេសន៍ ដែលវិលត្រលប់កំឡុងពេលវិបត្តិកូវីដ ១៩ និងផលប៉ះពាល់ ថ្នាក់បច្ចេកទេសរវាងតំណាងអង្គការយូអិន តំណាងអង្គការ IOM អគ្គលេខាធិការរង ទទួលបន្ទុកការងារទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងអង្គការ UN, IOM, WHO, UNICEF, UNFPA, និងអង្គការដៃគូពាក់ព័ន្ធ នៅសាលប្រជុំគ.ជ.ប.ជ។<br>○ "ពិនិត្យ និងផ្តល់យោបល់ ទៅលើខ្លឹមសារសេចក្តីព្រាងសៀវភៅការអប់រំ និងលំនាំនៃការបង្រៀន ស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស" នៅសាលប្រជុំគ.ជ.ប.ជ។<br>○ កែសម្រួលការងារបូកសរុបរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆមាសទី១ ឆ្នាំ២០២០ នៅសាលប្រជុំ គ.ជ.ប.ជ។<br>○ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការសម្ព័ន្ធចាប់ដៃ ស្តីពីគម្រោងកិច្ចសហប្រតិបត្តិការទប់ស្កាត់ជនរងគ្រោះ និងជន ចំណាក ស្រុក ខុសច្បាប់ ក្នុងដំណាក់កាលជំងឺកូវីដ១៩ អ្នកចូលរួមចំនួន **០៧**នាក់ ស្រី **០២**នាក់ នៅសាលប្រជុំ គ.ជ.ប.ជ។<br>○ ជាមួយមន្ទីរពាក់ព័ន្ធនានារបស់រដ្ឋបាលខេត្តបាត់ដំបង ស្តីពីផែនការសកម្មភាពក្នុងការអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងយូអិន ទៅក្នុងសហគមន៍ តាមបណ្តាស្រុករបស់ខេត្តបាត់ដំបង នៅសាលាខេត្តបាត់ដំបង។<br>○ ជាមួយមន្ទីរពាក់ព័ន្ធនានារបស់រដ្ឋបាលខេត្តសៀមរាប ស្តីពីផែនការសកម្មភាពក្នុងការអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងយូអិន ទៅក្នុងសហគមន៍ តាមបណ្តាស្រុករបស់ខេត្តសៀមរាប នៅសាលាខេត្តសៀមរាប។ |

| | |
|---|---|
| | ○ ឆមាសទី១ ឆ្នាំ២០២០ ដើម្បីពិនិត្យអំពីការប្រឈម លទ្ធផល និង ទិសដៅអនុវត្តបន្ត ក្នុងក្របខ័ណ្ឌកិច្ចសហការ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយអង្គការដៃគូពាក់ព័ន្ធ អំឡុងពេលវិបត្តិកូវីដ-១៩ មានអ្នកចូលរួមសរុប ៣២នាក់ ស្រី០៩នាក់ នៅសាលប្រជុំគ.ជ.ប.ជ។<br>○ ពាក់ព័ន្ធស្ថានភាព និងការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ ដែលងាយរងគ្រោះក្នុងកំឡុងពេលរាតត្បាតជំងឺកូវីដ ១៩ និងតាមដាន ត្រួតពិនិត្យការអនុវត្តគម្រោង ផែនការរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងយូអិន នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។<br>○ **"ដើម្បីផ្តល់ជាតុចូលលើសេចក្តីព្រាងឯកសារទស្សទាន ស្តីពីការរៀបចំច្រក ធ្វើដំណើរក្នុងអាស៊ាន (ASEAN Travel Corridor Arrangement)"** អ្នកចូលរួមចំនួន ៣៣នាក់ ស្រី ០៩នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>○ ស្តីពីស្ថានភាពរបស់ប្រជាជនចំណាកស្រុកដែលងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងបញ្ហាសុខភាពក្នុងតំបន់ជាប់ព្រំដែន ខេត្តស្ទឹងត្រែង នៅសាលប្រជុំសាលាខេត្តស្ទឹងត្រែង។<br>○ ចំនួន ០២លើក ស្តីពីការធ្វើចំណាកស្រុក ការជួញដូរមនុស្ស និងបញ្ហាសុខភាព របស់ប្រជាជន នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង និងស្រុកឆែប ខេត្តព្រះវិហារ។<br>○ ស្តីពីការរៀបចំរបាយការណ៍ រវាងក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីឆ្លើយតបសហរដ្ឋអាមេរិក អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សនៅក្នុងប្រទេសកម្ពុជា នៅសាលប្រជុំគ.ជ.ប.ជ។<br>○ ជាមួយអង្គការសម្ព័ន្ធមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរមនុស្ស នៅកម្ពុជា ដើម្បីធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវ ស្តីពីតម្រូវការ និងការសិក្សាជា មូលដ្ឋាន សម្រាប់កុមារចំណាកស្រុកកម្ពុជាដែលកំពុងរស់នៅប្រទេសថៃ (រៀននៅសាលារៀន ប្រទេសថៃ) នៅសាលប្រជុំគ.ជ.ប.ជ។<br>○ ត្រួតពិនិត្យរបាយការណ៍ឆ្លើយតបកា អេនុវត្តផែនការ សកម្មភាព ស្តីពីការ "កាត់បន្ថយពលកម្មកុមារនិងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ"(២០១៦-២០២៥)។<br>○ ពិនិត្យ កែតម្រូវពាក្យពេចន៍ អក្ខរាវិរុទ្ធ និងឃ្លោងឃ្លានៅក្នុង MoU រវាង គ.ជ.ប.ជ និង អង្គការ A 21 Foundation បញ្ចប់ ក្រោមការសម្របសម្រួលដោយ លោកជំទាវរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍រួមជាមួយ លោកជំទាវអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>○ ជាមួយតំណាងទូរទស្សន៍បាយ័ន ស្តីពី គម្រោងរៀបចំ ផលិតបទយកការណ៍ទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ។<br>○ ពិនិត្យខ្លឹមសារកិច្ចព្រមព្រៀងរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ.ជ.ប.ជ និងអង្គការវៃយអន្តរជាតិប្រចាំកម្ពុជា ស្តីពី "កិច្ចសហប្រតិបត្តិការអនុវត្តគម្រោងពលករចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព" មានអ្នកចូលរួមចំនួន ១១នាក់ ស្រី០៣នាក់។<br>**- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**<br>○ បានរៀបចំកិច្ចប្រជុំ ពិនិត្យ និងផ្តល់យោបល់លើខ្លឹមសារ សៀវភៅសិក្សាអប់រំ និងលំនាំវិធីនៃការបង្រៀន ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ក្រោមអធិបតីភាព**លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ មានអ្នកចូលរួមចំនួន ១៦នាក់ ស្រី ០៣នាក់។ |

| | |
|---|---|
| | ○ បានរៀបចំកិច្ចប្រជុំស្តីពី សកម្មភាពពិនិត្យកែសម្រួលផែនការសកម្មភាពឆ្នាំ២០២០ របស់ក្រុមជំនួយកិច្ចការទាំង៦ និងលេខាធិការដ្ឋានរដ្ឋបាល សរុប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីដាក់បញ្ចូលក្នុងទម្រង់គំរូផែនការសកម្មភាព របស់អគ្គនាយកដ្ឋាន និងអង្គភាពប្រហាក់ប្រហែលចំណុះក្រសួងមហាផ្ទៃឱ្យមានការឯកភាពតែមួយ មានអ្នកចូលរួមចំនួន ១១នាក់ ស្រី ០៣នាក់ នៅសាលប្រជុំគ.ជ.ប.ជ។<br>○ បានរៀបចំកិច្ចប្រជុំពិភាក្សាសម្រេចរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការចាលហ្វាន់ ដើម្បីរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី "កិច្ចការពារកុមារពីអំពើជួញដូរ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តប្រវេសន៍" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០២០ មានអ្នកចូលរួមចំនួន ០៩នាក់ ស្រី ០៣នាក់ នៅសាលប្រជុំគ.ជ.ប.ជ។<br>○ បានរៀបចំកិច្ចប្រជុំពិនិត្យ និងដកស្រង់របាយការណ៍ ដើម្បីផ្ញើជូនតាមការស្នើសុំ របស់ក្រុមការងារក្រសួងមហាផ្ទៃ ទទួលការងារប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន មានអ្នកចូលរួម ១៥នាក់ ស្រី០២នាក់ នៅសាលប្រជុំគ.ជ.ប.ជ ។<br>○ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** បានសហការជាមួយ **ក្រសួងអប់រំ យុវជន និងកីឡា** និង**អង្គការដៃគូពាក់ព័ន្ធ** បានរៀបចំកិច្ចប្រជុំ ដើម្បីរៀបចំមាតិកាសៀវភៅ ការអប់រំស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន សរុបចំនួន ៣៦លើក មានអ្នកចូលរួមសរុប ៣៧៦នាក់ ស្រី ១១១នាក់(នៅខេត្តកំពង់ស្ពឺ ០២លើក ខេត្តកំពង់ឆ្នាំង ០១លើក ខេត្តសៀមរាប ០២លើក ក្រសួងអប់រំ យុវជន និងកីឡា ១៥លើក និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ១៦លើក)។<br>○ រៀបចំកិច្ចប្រជុំពិនិត្យនិងផ្តល់យោបល់ទៅលើខ្លឹមសារ សេចក្តីព្រាងសៀវភៅ ការអប់រំស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួម ២២នាក់ ស្រី ០៣នាក់។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | ▪ បានរៀបចំ ដឹកនាំកិច្ចប្រជុំ បានចំនួន ១៤លើក ដែលមានមនុស្សចូលរួមសុបចំនួន ៣៩៥នាក់ ស្រី ១៣៥នាក់ រួមមាន៖<br>- ស្តីពីការធ្វើបច្ចុប្បន្នភាព លើទម្រង់ទទួល តាមដាន និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាមួយអង្គការដៃគូពាក់ព័ន្ធ ចំនួន ០៤លើក ដែលមានអ្នកចូលរួមចំនួន ៥៦នាក់ ស្រី ៥២នាក់។<br>- ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយអង្គការចំនួន១០ **មានអង្គការ**:(សម្ព័ន្ធចាប់ដៃ, ក្តីសង្ឃឹម និង យុត្តិធម៌, ក្តីស្រលាញ់គ្មានព្រំដែន, សង្គ្រោះ និងថែទាំស៊ីជីកញ, សកម្មភាពដើម្បីកុមារ(APLE), កូនស្រីនៃកម្ពុជា, សម្រាលទុក្ខមនុស្សជាតិ, សេចក្តីសង្ឃឹមពិភពលោកអន្តរជាតិ, មេត្រីអន្តរជាតិ, វេណាសេរដើរជាមួយស្ត្រីកម្ពុជា) ដែលមានអ្នកចូលរួមសរុប **៧៩**នាក់ **ស្រី៣៣**នាក់ នៅទីស្តីការក្រសួងស.អ.យ។<br>- វាយតម្លៃលើការបណ្តុះបណ្តាលស្តីពី គោលយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបទដ្ឋានពាក់ព័ន្ធមួយចំនួនទៀត ដែលបានបណ្តុះបណ្តាលរួចនៅខេត្តក្រចេះ និងកំពង់ធំ ចំនួន០១លើក ដោយសហការជាមួយអង្គការបេសកកម្មអន្តរជាតិ(IJM)។ |

| | |
|---|---|
| | - ប្រចាំត្រីមាស ឆ្នាំ២០២០ បានចំនួន ០៤លើក ស្តីពី៖ ១.ការពង្រឹងកិច្ចសហប្រតិបត្តិការ និងពិភាក្សាការងារ អំឡុងពេលរាតត្បាតកូវីដ១៩ ជាមួយក្រុមការងារការពារជនរងគ្រោះ ចំនួន ០២លើក មានអ្នកចូលរួមសរុប ១១០នាក់ ស្រី២២នាក់។ ២.ការត្រួតពិនិត្យពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តការងារ អំឡុងពេលរាតត្បាតកូវីដ ១៩ ជាមួយអង្គការដៃគូមិនមែនរដ្ឋាភិបាល ចំនួន ០២លើក មានអ្នកចូលរួមសរុប ១១០នាក់ ស្រី២៨នាក់។<br>- វាយតម្លៃលើការងារបណ្តុះបណ្តាល ស្តីពីគោលនយោបាយ និងបទដ្ឋានអប្បបរមា អំពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបទដ្ឋានមួយចំនួនទៀតដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងដោយអំពើជួញដូរមនុស្ស ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM)។<br>- លើផែនការយុទ្ធសាស្ត្រ ក្នុងការសហការវាំងមណ្ឌលប៉ោយប៉ែត និងអង្គការរតនៈអ៊ិនធើណេសិនណល ស្តីពីតម្រូវការបច្ចុប្បន្នរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនដែលត្រូវគេកេងប្រវ័ញ្ចផ្សេងៗ ដែលវិលត្រឡប់ពីប្រទេសថៃ។<br>- ជាមួយក្រុមការងារចម្រុះ ស្តីពីការផ្តល់សេវាគាំទ្រជូនពលករ ពលការនីដែលត្រូវបានបញ្ជូនពីប្រទេសថៃ នៅមណ្ឌលមណ្ឌលប៉ោយប៉ែត។<br>- បូកសរុបលទ្ធផលទទួលពលករ ពលការនីដែលត្រូវបានបញ្ជូនពីប្រទេសថៃ តាមច្រកអន្តរជាតិប៉ោយប៉ែត និងច្រកអូរបីជាន់។ |
| ក្រសួងអប់រំ យុវជន និងកីឡា | ▪ ដឹកនាំ និងសហការ រៀបចំកិច្ចប្រជុំ បានចំនួន ០៣លើក ដែលមានមនុស្សចូលរួមសុបចំនួន ១៤១នាក់ ស្រី ៣៩នាក់ រួមមាន៖<br>- បានរៀបចំកិច្ចប្រជុំ និងគណៈកម្មការដឹកនាំផែនការសកម្មភាពដើម្បីទប់ស្កាត់ និងដើម្បីឆ្លើយតបអំពើហិង្សាលើកុមារ នៅសណ្ឋាគារកាំបូឌីយ៉ាណា មានអ្នកចូលរួមចំនួន ៥៥នាក់ ស្រី ២២នាក់។<br>- សហការជាមួយ៖ ១.អង្គការភ្លែនអន្តរជាតិកម្ពុជា (Plan International Cambodia) រៀបចំកិច្ចប្រជុំ ដើម្បីរៀបចំមាតិកាសៀវភៅ និងលំនាំនៃការបង្រៀនស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស នៅខេត្តកំពង់ស្ពឺ តាកែវ និងខេត្តកំពង់ឆ្នាំង មានអ្នកចូលរួមចំនួន ៧៨នាក់ ស្រី ១៥នាក់។ ២.អង្គការសកម្មភាពដើម្បីកុមារ (APPLE) រៀបចំកិច្ចប្រជុំ ស្តីពី "ការសិក្សាស្រាវជ្រាវពាក់ព័ន្ធ ការរំលោភបំពានសិទ្ធិកុមារតាមប្រព័ន្ធអ៊ីនធឺណិត" មានអ្នកចូលរួមចំនួន ០៨នាក់ ស្រី ០២នាក់។ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - បានសហការជាមួយអង្គការ(IOM) រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ក្នុងការអនុវត្តគម្រោងប្រចាំឆ្នាំ លើគម្រោងកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការកសាងជំនាញ និងការលើកកម្ពស់ការងារ ឱ្យធ្វើនៅក្នុងប្រទេសកម្ពុជា ឡាវ ភូមា និងប្រទេសថៃ (PROMISE) ចំនួន ០១លើក ដែលមានអ្នកចូលរួមចំនួន ៣៨នាក់ ស្រី ១៥នាក់។ |
| ក្រសួងធម្មការ និងសាសនា | - បានរៀបចំកិច្ចប្រជុំក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំក្រសួងធម្មការ និងសាសនា ០១លើក ដែលមានថ្នាក់ដឹកនាំក្រសួង និងថ្នាក់មន្ទីរចូលរួមសរុបចំនួន ៨០នាក់ ស្រី ១៥នាក់។ |
| ក្រសួងកិច្ចការនារី | ▪ ដឹកនាំ និងសហការ រៀបចំកិច្ចប្រជុំ បានចំនួន ០៤លើក ដែលមានមនុស្សចូលរួមសុបចំនួន ១២៥នាក់ ស្រី ៤៨នាក់ រួមមាន៖<br>- ក្រុមការងារកម្ពុជាប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ(ខមមីតកម្ពុជា) ក្នុងគោលបំណងដើម្បីរាយការណ៍ពីស្ថានភាពបច្ចុប្បន្ន នៃអំពើជួញដូរមនុស្សនៅកម្ពុជា ដើម្បីកំណត់បញ្ហាប្រឈមថ្មី និងលើកទិសដៅបន្តព្រមទាំងផ្សព្វផ្សាយលទ្ធផលកិច្ចប្រជុំនៅប្រទេសវៀតណាម មានអ្នកចូលរួមចំនួន ៤៦នាក់ ស្រី ២៣នាក់។ |

| | |
|---|---|
| | - ត្រៀមឆ្លើយតបចំពោះរបាយការណ៍ឆ្នាំ២០២០ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកពាក់ព័ន្ធនឹងការដាក់ចំណាត់ថ្នាក់កម្ពុជាលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ មានអ្នកចូលរួមចំនួន **២១**នាក់ ស្រី **០៧**នាក់ នៅទីស្តីការក្រសួងកិច្ចការនារី។<br>- រៀបចំកិច្ចប្រជុំជាមួយអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ដើម្បីបំភ្លឺ អនុសាសន៍ទាំង១៧ ដែលអាមេរិកបានស្នើឱ្យកម្ពុជានៅក្នុងរបាយការណ៍វាយតម្លៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ មានអ្នកចូលរួមចំនួន **៣៩**នាក់ ស្រី **០៨**នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងប្រកាសរួមស្តីពីការបង្កើតគណៈកម្មការប្រឹក្សាយោបល់ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី ក្រោមអធិបតីភាពលោកជំទាវ **ឡុង សុផល្លី** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងឯកឧត្តម **ហ៊ូ វឌ្ឍី** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានអ្នកចូលរួមចំនួន **១៩**នាក់ ស្រី **១០**នាក់ នៅសណ្ឋាគារសាន់វេ ។ |
| **ក្រសួងព័ត៌មាន** | - ក្រុមការងារទប់ស្កាត់អំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំពិភាក្សាដើម្បីលើកជាផែនការរៀបចំសិក្ខាសាលា ឬព្រឹត្តិការណ៍ប្រគំតន្ត្រីនៅតាមបណ្តាខេត្តមួយចំនួនដើម្បីចុះអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងកាន់តែច្បាស់ពីសកម្មភាពជួញដូរមនុស្ស និងមានវិធានការ ទប់ស្កាត់បានទាន់ពេលវេលា។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ អង្គការដៃគូ បានសហការ និងរៀបចំកិច្ចប្រជុំ បានចំនួន ៣៧៩លើក មានសិក្ខាមចំនួន ១៣.៤១០នាក់ ស្រី ៧.១៣១នាក់** | |
| **ខេត្តបន្ទាយមានជ័យ** | ▪ លោកជំទាវ ប្រធានលេខា គ.ខ.ប.ជខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ២០២០ និងទិសដៅឆ្នាំ២០២១ ចំនួន៤លើក។ |
| **ខេត្តបាត់ដំបង** | ▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ បានចំនួន **០២**លើក ដែលមានមនុស្សចូលរួមសុបចំនួន **១២០**នាក់ ស្រី **២៧**នាក់ រួមមាន៖<br>- ស្តីពីវិធីឆ្លើយតបចំពោះប្រជាពលរដ្ឋងាយរងគ្រោះ(ការធ្វើចំណាកស្រុក និងការធ្វើសមាហរណកម្ម) និងពិធីបញ្ចុះបឋមសិលាសាងសង់ មណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួមចំនួន **៦៣**នាក់ ស្រី **២៧**នាក់ នៅសណ្ឋាគារ ក្លាស់ស៊ី ខេត្តបាត់ដំបង។<br>- ប្រចាំឆមាសទី២១របស់ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សខេត្ត នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ដែលមានអ្នកចូលរួមមកពីមន្ទីរ អង្គភាពនានាជុំវិញខេត្ត លោក លោកស្រី អភិបាលរង ក្រុង ស្រុក សរុបចំនួន **៥៧**នាក់ ។ |
| **ខេត្តប៉ៃលិន** | - បានរៀបចំប្រជុំស្តីពីលទ្ធផលការងារពិនិត្យពិភាក្សា លើសេចក្តីព្រាងរបាយកាណ៍១០ខែ ឆ្នាំ២០២០ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោក **ចេង ញ៉ាន់** អភិបាលរង នៃគណៈអភិបាលខេត្ត មានអ្នកចូលរួមសរុប **២៨**នាក់ ស្រី**០៨**នាក់ ។ |
| **ខេត្តសៀមរាប** | ▪ លេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ២០២០ បានចំនួន **៤១**លើក ដែលមានអ្នកចូលរួមសរុបចំនួន **៧៤៤**នាក់ ស្រី **៣៩០**នាក់។ និងបានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារបច្ចេកទេស រួមមានក្រុមការងារបង្ការ ទប់ស្កាត់ ក្រុមការងារអនុវត្តច្បាប់ ក្រុមការងារការពារជនរងគ្រោះ និងក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ ស្តីពីការចុះត្រួតពិនិត្យលើមណ្ឌលរបស់អង្គការដារ៉ូម៉ា ក្នុងខេត្តសៀមរាប ចំនួន**០១**លើក។ |

| | |
|---|---|
| | ▪ ក្រុមការងារយុត្តិធម៌ព្រហ្មទណ្ឌស្តីពី ការនាំចេញដោយមិនស្របច្បាប់ នីតិវិធីនៃការឃាត់ខ្លួន និងនីតិវិធីនៃការឃុំខ្លួនអនីតិជន បានចំនួន ០២លើក ដែលមានអ្នកចូលរួមសរុប ១៧៩នាក់ ស្រី៣០នាក់ នៅសាលាខេត្តសៀមរាប។<br>▪ ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក បានរៀបចំកិច្ចប្រជុំ បានចំនួន ៣៧លើក ដែលមានអ្នកចូលរួមសរុបចំនួន ១.៥៣២នាក់ ស្រី ៥៩៩នាក់។ |
| ខេត្តកំពង់ចាម | ▪ លេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបានចំនួន ១២លើក ដែលមានមនុស្សចូលរួមសុបចំនួន ២១៨នាក់ ស្រី ១៥៩នាក់ រួមមាន៖<br>- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ១-សហការជាមួយអង្គការពលកម្មអន្តរជាតិ(ILO) រៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពី លទ្ធផលនៃការស្រាវជ្រាវផលប៉ះពាល់លើពលករទេសន្តរប្រវេសន៍ ដោយជំងឺកូវីដ១៩ និងក្រមសីលធម៌ក្នុងការជ្រើសរើស ព្រមទាំងយន្តការដោះស្រាយបណ្តឹង របស់ពលករ ចំនួន ០១លើក មានអ្នកចូលរួម ៤៦នាក់ ស្រី២៣នាក់។ ២-ប្រជុំក្រុមការងារទេសន្តរប្រវេសន៍ ពិភាក្សាអំពីការជ្រើសរើសស្រុកគោលដៅ ក្នុងការអនុវត្តសកម្មភាពទប់ស្កាត់ការរីករាលដាលជំងឺកូវីដ ១៩ ដល់ពលករចំណូលស្រុក និងមធ្យោបាយក្នុងការធ្វើសកម្មភាពស្វែងរកមូលនិធិគាំទ្រ ចំនួន ០៩លើក ដែលមានអ្នកចូលរួមចំនួន ១៤នាក់ ស្រី ០៩នាក់។<br>- ក្រុមការងារសហប្រតិបត្តិការ ដែលដឹកនាំដោយមន្ទីរកិច្ចការនារីខេត្ត បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់ការជួញដូរមនុស្ស និងច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ នៅស្រុកចំការលើ កងមាស ស្ទឹងត្រង់ និងស្រុកកំពង់សៀម ដែលមានអ្នកចូលរួមសរុបចំនួន ១៤៥នាក់ ស្រី ១២២នាក់។<br>- ក្រុមការងារលេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្តីពីការលើកកម្ពស់សុវត្ថិភាព និងកិច្ចការពារដល់ទៅលើកិច្ចគាំទ្រសេវាកម្មផ្នែកច្បាប់ទាំងនៅក្នុងប្រទេស និងនៅប្រ ពលករនេសាទនៅប្រទេសថៃទេសថៃ នៅពេលដែលមានបញ្ហា អ្នកចូលរួមចំនួន១៣នាក់ ស្រី០៥នាក់។ |
| កំពង់ឆ្នាំង | ▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ បានចំនួន ០៤លើក ដែលមានមនុស្សចូលរួមសុបចំនួន ១៦នាក់ ស្រី ០៤នាក់ រួមមាន៖<br>- គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត(គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែមករា កុម្ភៈ មីនា និងប្រចាំត្រីមាសទី១ ឆ្នាំ២០២០ ដែលមានការអញ្ជើញចូលរួមពីក្រុមទាំង៦ និងបណ្តាក្រុង/ស្រុកទាំង៨។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែមីនា ត្រីមាសទី១ និងលើកទិសដៅការងារអនុវត្តបន្ត។<br>- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំកិច្ចប្រជុំប្រចាំត្រីមាស របស់ក្រុមការងារការពារជនរងគ្រោះ ចំនួន០១លើក អ្នកចូលរួម១៦នាក់ ស្ត្រី ០៤នាក់។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ជ.ប.ជ ខេត្តបានចូលរួមកិច្ចប្រជុំប្រចាំខែ របស់គណៈកម្មាការពិគ្រោះយោបល់ស្ត្រី និងកុមារ នៅសាលាខេត្ត ចំនួន០១លើក។ |
| ខេត្តកំពង់ស្ពឺ | ▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ បានចំនួន ១៦លើក ដែលមានមនុស្សចូលរួមសុបចំនួន ១.០៧៦នាក់ ស្រី ៥៦៤នាក់ រួមមាន៖<br>- កិច្ចប្រជុំបូកសរុបរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំ២០១៩ ទិសដៅ២០២០ អ្នកចូលរួមចំនួន ៧៥នាក់ ស្រី២៩នាក់។<br>- សន្និបាតបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០ អ្នកចូលរួម ចំនួន ៤៦៣នាក់ ស្រី ១៩៧នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងក្មេងស្រី ០១លើក នៅមន្ទីរកិច្ចការនារីខេត្ត អ្នកចូលរួម ៣៤នាក់ ស្រី ២៨នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំចំនួន ១៣លើក មានអ្នកចូលរួម ៥០៤នាក់ ស្រី ៣១០នាក់។ |
| ខេត្តព្រៃវែង | ▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ បានចំនួន ០៣លើក ដែលមានមនុស្សចូលរួមសុបចំនួន ១៤នាក់ ស្រី ០៥នាក់ រួមមាន៖ |

| | |
|---|---|
| | - ឯកឧត្តម **ជា សុមេធី** អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដឹកនាំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ចំនួន ០២លើក និងបានណែនាំដល់កងកម្លាំងទាំងបី អាជ្ញាធរមូលដ្ឋាន ជាពិសេសស្រុកដែលជាប់ព្រំដែនវៀតណាម និងមន្ត្រីពាក់ព័ន្ធទាំងអស់ត្រូវពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ ខិតខំទប់ស្កាត់ និងចាត់វិធានការឲ្យបានទាន់ពេលវេលានូវការបង្ក្រាបបទល្មើសនានា ជាពិសេសបញ្ហាជួញដូរមនុស្ស ការចំណាកស្រុករបស់បងប្អូនប្រជាពលរដ្ឋប្រកបដោយសុវត្ថិភាព និងយកចិត្តទុកដាក់ចំពោះបងប្អូនចំណាកស្រុកមកពីប្រទេសថៃត្រូវដាក់ដោយឡែក១៤ថ្ងៃ ដើម្បីការពារកុំឲ្យឆ្លងជម្ងឺកូវីដ-១៩។<br>- លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំបូក សរុបបាយការណ៍ប្រចាំឆមាសទី១ និងលើកទិសដៅផ្នាំបន្ត ក្រោមអធិបតីភាព លោកជំទាវ លៀង ស្រីម៉ុល អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអ្នកចូលរួមចំនួន **១៤**នាក់ ស្រី **០៥**នាក់។ |
| **ខេត្តស្វាយរៀង** | ▪ លោកជំទាវ **ឯក សុវណ្ណភារៈ** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ ដឹកនាំលេខាធិការដ្ឋាន គ.ខ.ប.ជបានរៀបចំកិច្ចប្រជុំ បានចំនួន ០៦លើក ដែលមានមនុស្សចូលរួមសុបចំនួន **២៦៥**នាក់ ស្រី **១១៣**នាក់ រួមមាន៖<br>- សហការជាមួយអង្គការឆាលហ្វាន់កម្ពុជា រៀបចំវេទិកាផ្សព្វផ្សាយ «ទស្សនៈបញ្ជាំងអំពីវឌ្ឍនភាពនៃការ អនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលាខេត្តស្វាយរៀង មានអ្នកចូលរួម **៧៦**នាក់ ស្រី**២៩**នាក់។<br>- សហការជាមួយអង្គការឆាលហ្វាន់ បានរៀបចំកិច្ចប្រជុំឆ្លងរបាយណ៍ប្រចាំឆមាសទី១ និងទិសដៅបន្ត អ្នកចូលរួម**៥៧**នាក់ ស្រី**២៨**នាក់។<br>- រៀបចំកិច្ចប្រជុំពិភាក្សាពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងពលករឆ្លងដែនដោយខុសច្បាប់ទៅប្រទេសវៀតណាមតាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ និងច្រកទ្វារព្រំដែនទេសភាគីសំរោង ចំនួន០៣លើក អ្នកចូលរួម **៥៦**នាក់ ស្រី**២៧**នាក់។<br>- សហការជាមួយអង្គការឆាលហ្វានកម្ពុជា រៀបចំកិច្ចប្រជុំទស្សនៈបញ្ជាំងអំពីវឌ្ឍនភាពនៃការអនុវត្តការងារ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំសាលាខេត្តស្វាយរៀង ដែលមានសមាសភាពចូលរួមចំនួន **៧៦នាក់** ស្រី **២៩** នាក់ ។ |
| **ខេត្តក្រចេះ** | ▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ បានចំនួន **១១**លើក ដែលមានមនុស្សចូលរួមសុបចំនួន **៤៦៧**នាក់ ស្រី **២០០**នាក់ រួមមាន៖<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ចំនួន០៨លើក អ្នកចូលរួម **៣៤១**នាក់ ស្រី **១៤៥**នាក់។<br>- លោកស្រី **ខាំ សុភាព** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែ ត្រីមាស ឆមាស ១០ខែ និងឆ្នាំ២០២០ ទិសដៅអនុវត្តបន្ត ឆ្នាំ២០២១ បានចំនួន **៣**លើកនៅសាលប្រជុំមេគង្គសាលាខេត្ត អ្នកចូលរួមសរុបចំនួន **១២៦**នាក់ ស្រី **៥៥**នាក់។ |
| **ខេត្តឧត្តរមានជ័យ** | - បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគោះយោបល់លើកិច្ចការស្ត្រី និងកុមារ ចំនួន០១លើក អ្នកចូលរួមចំនួន**២២**នាក់ ស្រី**១១**នាក់។ |
| **ខេត្តកណ្តាល** | ▪ លោកជំទាវ **ហ៊ិន កុសនី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ២០២០ និងទិសដៅឆ្នាំ២០២១ បានចំនួន **១២៥**លើក ដែលមានមនុស្សចូលរួមសុបចំនួន **៣.៦៥៦**នាក់ ស្រី **២.២៧១**នាក់។<br>▪ គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ២០២០ និងទិសដៅឆ្នាំ២០២១ ចំនួន**១២**លើក អ្នកចូលរួមចំនួន**៥៨៥**នាក់ ស្រី**៣០៤**នាក់។<br>▪ ក្រុមការងារក្រុង-ស្រុកទាំង១១ បានប្រជុំប្រចាំខែ ចំនួន **១២០**លើក អ្នកចូលរួមចំនួន**២.៩៥១**នាក់ ស្រី**១.៩៣៣**នាក់។ |

| | |
|---|---|
| **ខេត្តតាកែវ** | ▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ បានចំនួន ០៧លើក ដែលមានមនុស្សចូលរួមសុបចំនួន ៧០៥នាក់ ស្រី ១៤០នាក់ រួមមាន៖<br>- ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពខេត្ត បានរៀបចំកិច្ចប្រជុំស្តីពី ការណែនាំទប់ស្កាត់ដល់ប្រជាពលរដ្ឋធ្វើចំណាកស្រុក ទៅរកការងារធ្វើនៅប្រទេសជិតខាង ក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ ១៩ និងអំពើហិង្សាក្នុងគ្រួសារ ០៤លើក អ្នកចូលរួម ៣៨១នាក់ ស្រី ៥៩នាក់។<br>- រដ្ឋបាលឃុំរមេញ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារចំនួន០១លើក អ្នកចូលរួម ២០៦នាក់ ស្រី ៥០នាក់។<br>- បានប្រជុំបូកសរុបរបាយការណ៍រយៈ ៩ខែ របស់លេខាធិការដ្ឋានគ.ខ.ប.ជ ខេត្ត មានអ្នកចូលរួម ៧៥នាក់ ស្រី ១៥នាក់។<br>- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការដៃគូ រៀបចំកិច្ចប្រជុំ ស្តីពីការផ្តល់សេវាជួយជនរងគ្រោះនិងងាយរងគ្រោះចំនួន ០១លើក មានអ្នកចូលរួមចំនួន ៤៣នាក់ ស្រី ១៦នាក់។ |
| **ខេត្តកែប** | - លេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ ចំនួន ០៣លើក ស្តីពីការទប់ស្កាត់ការធ្វើចំណាកស្រុក អំពើហិង្សាក្នុងគ្រួសារ និងអំពើជួញដូរមនុស្ស។ |
| **ខេត្តកោះកុង** | ▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ បានចំនួន ០៣លើក ដែលមានមនុស្សចូលរួមសុបចំនួន ១៩នាក់ ស្រី ១០នាក់ រួមមាន៖<br>- ប្រជុំរៀបចំកែសម្រួល សមាសភាពក្រុមការងារទាំង០៦ ក្រុមការងារទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រុង ស្រុក ឃុំ សង្កាត់ និងផ្សព្វផ្សាយការចំណាកស្រុកដោយសុវត្ថិភាពដល់ ក្រុង ស្រុក ទូទាំងខេត្ត មានអ្នកចូលរួម ០៧នាក់ ស្រី០៤នាក់។<br>- ប្រជុំឆ្លងរបាយការណ៍ ១០ខែ របស់លេខាធិការដ្ឋាន គ.ខ.ប.ជ មានអ្នកចូលរួម ០៦នាក់ ស្រី ០៣នាក់។<br>- ប្រជុំត្រៀមរៀបចំប្រកាសក្រុមការងារទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងត្រៀមផ្សព្វផ្សាយទិវាជាតិ១២ ធ្នូ ឆ្នាំ២០២០ មានអ្នកចូលរួម ០៦នាក់ ស្រី ០៣នាក់ នៅសាលាខេត្តកោះកុង។ |
| **អង្គការ APLE** | - បានរៀបចំកិច្ចប្រជុំប្រចាំខែ ដោយសហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តកោះកុង បានចំនួន០៧លើក ក្នុងការអនុវត្តផែនការសកម្មភាពស្តីពីការបង្ការអំពើជួញដូរមនុស្ស និងការការពារកុមារពីអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ រួមទាំងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត និងកិច្ចប្រជុំយុត្តិធម៌ព្រហ្មទណ្ឌ ដែលមានសមាសភាពចូលរួមសរុបចំនួន៦៤៣នាក់ ស្រី ៣៦៣នាក់។ |
| **អង្គការសម្ព័ន្ធចាប់ដៃ** | - បានសហការជាមួយ៖១.អង្គការអភិវឌ្ឍន៍ អេរិក្ស រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីបេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីបង្ក្រាបអំពើជួញដូរមនុស្ស នៅខេត្តព្រះវិហារ និងខេត្តកំពង់ចាម បានចំនួន ០៣លើក ដែលមានមន្ត្រីនគរបាលពាក់ព័ន្ធចូលរួមចំនួន ១៧០នាក់។ ២.អង្គការមូលនិធិយុវជន ជនបទប្រទេសថៃ ស្តីពី "តម្រូវការ និងការសិក្សាមូលដ្ឋានសម្រាប់កុមារចំណាកកម្ពុជាដែលកំពុងរស់នៅប្រទេសថៃ"។ ៣.នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម ជនរងគ្រោះ លើគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងការរំលោភបំពានទម្រង់ផ្សេងៗ។ ៤.ក្រុមការងារបច្ចេកទេស ស្តីពីការធ្វើបច្ចុប្បន្នភាពលើទម្រង់គ្រប់គ្រងករណីថ្នាក់ជាតិ(សមាហរណកម្ម) សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ។ |

# ក្របខណ្ឌតាមដាន
# សកម្មភាព និងលទ្ធផលការងារ
# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# ឆ្នាំ ២០២០

## របស់

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

( គ.ជ.ប.ជ )

# ការចុះជួបសាកសួរសុខទុក្ខផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងតំបន់ជួបគ្រោះធម្មជាតិ ទឹកជំនន់ របស់ថ្នាក់ដឹកនាំកំពូលនៃរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២០






កិច្ចប្រជុំនានាតាមប្រព័ន្ធអនឡាញ និងនៅអង្គការសហប្រជាជាតិ ក្នុងឆ្នាំ២០២០
របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា






ដើម្បីដោះស្រាយបញ្ហា សេដ្ឋកិច្ច សង្គម រួមទាំងវិបត្តិនៃទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្សផងដែរ

## កិច្ចប្រជុំពិគ្រោះយោបល់ជាមួយតំណាងយូអិននៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ រយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុកក្នុងស្ថានភាពវិករាលដាលជម្ងឺកូវីដ ១៩ ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ (ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០)











ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមលោកជំទាវ រដ្ឋមន្ត្រី ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកសិកម្ម ក្រសួងមហាផ្ទៃ








ខាងអង្គការសហប្រជាជាតិ មានលោកស្រី Pauline Tamesis តំណាងអង្គការយូអិននៅកម្ពុជា លោកស្រី Kristin Parco ប្រធានអង្គការ ទេសន្តរប្រវេសន៍អន្តរជាតិ លោកស្រី Li Ailan តំណាងអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា លោក Daniel Alemu ប្រធានអង្គការ UNFPA លោកស្រី Lucia Soleti តំណាងអង្គការ UNICEF






អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អគ្គស្នងការនគរបាលជាតិ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងបណ្តាក្រសួងពាក់ព័ន្ធមួយចំនួនទៀត

# ពិធីប្រកាសគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ស្តីពីការជួយគាំទ្រដល់ជនទេសន្តរប្រវេសន៍ ដែលវិលត្រលប់ក្នុងដំណាក់កាលកូវីដ-១៩


















«គម្រោងរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ប្រចាំនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុកក្នុងស្ថានភាពរីករាលដាលជម្ងឺកូវីដ ១៩» ត្រូវបានសម្រេចអនុវត្តនៅក្នុងខេត្តចំនួនបី ដែលមានពលករវិលត្រឡប់ច្រើនជាងគេ គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប ចាប់ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២០

# កិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ថ្នាក់ជាតិឆ្នាំ២០១៩ និងទិសដៅឆ្នាំ២០២០ របស់ គ.ជ.ប.ជ

















មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ដែលជាប្រធាន អនុប្រធាន សមាជិក គ.ជ.ប.ជ ក្រុមការងារអន្តរក្រសួង ស្ថាប័នទាំង៦ តំណាងអង្គទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា អភិបាលគ្រប់រាជធានី ខេត្ត និងលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ កងកម្លាំងនគរបាល កងរាជអាវុធហត្ថលើផ្ទៃប្រទេស ទីចាត់ការព្រំដែន ក្រសួងការពារជាតិ និងអង្គការដៃគូអភិវឌ្ឍនានា សរុប ជាង ៥០០នាក់

# កិច្ចប្រជុំបូកសរុបរបាយការណ៍ឆមាសទី១ ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)










**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានដឹកនាំកិច្ចប្រជុំឆមាសរបស់គណៈកម្មាធិការជាតិ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការប្រចាំឆ្នាំ ភាពប្រឈមនិងលើកទិសដៅបន្តទៅឆមាសបន្ទាប់ទៀត

# កិច្ចប្រជុំថ្នាក់បច្ចេកទេស ជាមួយអង្គការដៃគូពាក់ព័ន្ធ ស្តីពីការអនុវត្តគម្រោងគាំទ្រ ដល់ជនទេសន្តរប្រវេសន៍ដែលវិលត្រលប់ ក្នុងបរិបទកូវីដ ១៩














អង្គការដៃគូជាតិ និងអន្តរជាតិ បានចូលរួមយ៉ាងសកម្មជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានផ្លាស់ប្តូរយោបល់យ៉ាងផុសផុល ដើម្បីកំណត់រកសកម្មភាព ដែលត្រូវអនុវត្តសម្រាប់ការគាំទ្រដល់ជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់ ក្នុងអំឡុងពេលដែលប្រទេសជិតខាងមានវិធានការបិទព្រំដែន ដើម្បីបង្ការទប់ស្កាត់ ការរីករាលដាល ជម្ងឺកូវីដ ១៩

# សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្ដីពីការអនុវត្តកតិកាសញ្ញាពិភពលោក សម្រាប់ជនទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់

















កតិកាសញ្ញាពិភពលោក ស្ដីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរង និងស្របច្បាប់ ត្រូវបានអនុម័តជាផ្លូវការដោយបណ្ដាថ្នាក់ដឹកនាំនៃប្រទេសជាសមាជិកអង្គការសហប្រជាជាតិ នាថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១៨ នៅទីក្រុង ម៉ារ៉ាកិច ប្រទេស ម៉ារ៉ុក

# សកម្មភាពចុះពិនិត្យស្ថានភាព តាមដានសភាពការណ៍ និងគាំទ្រ ដល់បណ្ដាខេត្តជាប់ព្រំដែន របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ








កិច្ចប្រជុំពិភាក្សា ការពង្រឹងវិធានការឆ្លងដែន និងគ្រប់គ្រងពលករឆ្លងដែនខុសច្បាប់នៅសាលាខេត្តបន្ទាយមានជ័យ




# ការចុះសាកសួរសុខទុក្ខមន្ត្រីជួរមុខ ដែលឈរជើងនៅតាមព្រំដែន ចាំទទួលពលករទេសន្តរប្រវេសន៍ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ក្នុងខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង




ផ្តល់ការឧបត្ថម្ភ លើកទឹកចិត្ត មន្ត្រីឈរជើងនៅកន្លែងទទួលពលករដែលវិលត្រឡប់ពីប្រទេសថៃ តាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ




ចុះសាកសួរសុខទុក្ខ និងផ្តល់សម្ភារៈឧបត្ថម្ភមណ្ឌលចត្តាឡីស័ក នៅសាលាបឋមសិក្សា អូរបីជាន់






ប្រតិភូ គ.ជ.ប.ជ បានចុះពិនិត្យកន្លែងទទួលពលករ និងច្រកទ្វារព្រំដែនអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង

# កិច្ចប្រជុំរួមរវាងក្រុមការងារដឹកនាំគម្រោង និង រដ្ឋបាលខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ស្តីពីការអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ដើម្បីដោះស្រាយផលប៉ះពាល់ លើវិស័យសេដ្ឋកិច្ច សង្គម ដោយ កូវីដ ១៩ (នៅខេត្តសៀមរាប)










# ការចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ ពិនិត្យស្ថានភាព ភាពប្រឈម និងផ្តល់អំណោយ ជូនបងប្អូនពលករទេសន្តរប្រវេសន៍ដែលវិលត្រលប់ នៅតាមបណ្តាគោលដៅ ក្នុងខេត្តបាត់ដំបង




ជំនួបពិភាក្សាការងារពាក់ព័ន្ធនឹងការសាងសង់មណ្ឌលទទួលពលករ និងបញ្ហាប្រឈមនានាជាមួយគណៈអភិបាលខេត្តបាត់ដំបង




ការចុះសាកសួរសុខទុក្ខពលករទេសន្តរប្រវេសន៍ ដែលវិលត្រឡប់ពីប្រទេសថៃ ក្នុងអំឡុងនៃការរីករាលដាល កូវីដ ១៩ នៅក្នុងស្រុកកំរៀង ខេត្តបាត់ដំបង






ពលករទេសន្តរប្រវេសន៍ ដែលវិលត្រឡប់ពីប្រទេសថៃ នៅក្នុងនៅក្នុងស្រុកកំរៀង ស្រុកបវេល និង ស្រុកថ្មគោល ក្នុងខេត្តបាត់ដំបង ដោយមានការចូលរួមជួយឧបត្ថម្ភ ដោយអង្គការ UNFPA និងអង្គការ Hagar





ជួបប្រជាពលរដ្ឋជួបការលំបាក និងជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់ នៅក្នុងស្រុករមាសហែក ខេត្តស្វាយរៀង
ដោយមានការចូលរួមជួយឧបត្ថម្ភពី អង្គការ UNFPA  និងអង្គការ Child Fund





ជួបប្រជាពលរដ្ឋជួបការលំបាក និងជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់ នៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប
ដោយមានការចូលរួមជួយឧបត្ថម្ភពី អង្គការ UNFPA និងអង្គការ IOM




ជួបប្រជាពលរដ្ឋជួបការលំបាក និងជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់ នៅក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង
ដោយមានការចូលរួមជួយឧបត្ថម្ភពី អង្គការ UNFPA និងមូលនិធិ ROTTARY CLUB




ជួបប្រជាពលរដ្ឋជួបការលំបាក និងជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់ នៅក្នុងស្រុកព្រះនេត្រព្រះ
ខេត្តបន្ទាយមានជ័យ ដោយមានការចូលរួមជួយឧបត្ថម្ភពី អង្គការ UNFPA និងមូលនិធិ ROTTARY CLUB






ជួបប្រជាពលរដ្ឋជួបការលំបាក និងជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់នៅស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដោយមានការចូលរួមជួយឧបត្ថម្ភពី អង្គការ UNFPA និងមូលនិធិ ROTTARY CLUB




ការសាកសួរសុខទុក្ខប្រជាពលរដ្ឋជួបការលំបាកនៅក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង និងសង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឧបត្ថម្ភដោយ អង្គការ UNFPA និង ROTTARY CLUB



ជួបពិភាក្សាជាមួយរដ្ឋបាលស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង



ជួបពិភាក្សាជាមួយរដ្ឋបាលខេត្តនៅសាលាខេត្តព្រះវិហារ



ជួបពិភាក្សាជាមួយរដ្ឋបាលស្រុកម៉ាល័យ ខេត្តបន្ទាយមានជ័យ



វគ្គបណ្តុះបណ្តាលជំនាញកសិកម្មក្នុងស្រុកកំរៀង ខេត្តបាត់ដំបង

# ការចុះពិនិត្យទីតាំងទទួលពលករ នៅភូមិច័ន្ទគីរី ឃុំដូង និងទីតាំងសម្រាប់សាងសង់មណ្ឌលទទួលពលករ ស្រុកកំរៀង ខេត្តបាត់ដំបង ដែលជាអំណោយរបស់អង្គការ CARITAS ស្វីស






កិច្ចពិភាក្សា ជាមួយរដ្ឋបាលស្រុកកំរៀង ខេត្តបាត់ដំបង អំពីស្ថានភាពពលករ និងការចុះពិនិត្យទីតាំងត្រៀមសាងសង់មណ្ឌលទទួលពលករដែលជាអំណោយរបស់ CARITAS ស្វីស





ផ្ទៃដី ៥០ម×១០០ម សម្រាប់ការសាងសង់មណ្ឌលទទួលពលករកំរៀង ជាអំណោយសប្បុរសធម៌របស់ **លោក ស៊ីន យឹម** ជាសប្បុរសជនដែលរស់នៅក្នុងស្រុកកំរៀង ខេត្តបាត់ដំបង







ពិធីចម្រើនព្រះបរិត សែនក្រុងពាលី សុំម្ចាស់ទឹកដី និងបញ្ចុះសីមា សាងសង់មណ្ឌលទទួលពលករ ស្រុកកំរៀង





ការចាប់ផ្ដើមដំណើរការសាងសង់មណ្ឌលទទួលពលករ ស្រុកកំរៀង បន្ទាប់ពីបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន សាងសង់ និងបានគូរប្លង់សំណង់រួច នៅក្នុងខែកក្កដា ឆ្នាំ២០២០ និងរំពឹងថា នឹងសាងសង់រួចរាល់ជាស្ថាពរ ក្នុងខែមិនា ឆ្នាំ២០២១

# ប្រតិភូក្រសួងមហាផ្ទៃ ដឹកនាំដោយសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានអញ្ជើញចុះត្រួតពិនិត្យតាមព្រំដែនខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ (ក្នុងអំឡុងពេលដែលថៃប្រកាសបិទព្រំដែន ថ្ងៃ២៣ ខែមីនា ឆ្នាំ២០២០)



ការចុះត្រួតពិនិត្យស្ថានភាព និងសកម្មភាពទទួលពលករវិលត្រឡប់ នៅមណ្ឌលសំចតប៉ោយប៉ែត ខែមីនា ឆ្នាំ២០២០



ពលករវិលត្រឡប់មកតាមច្រកអន្តរជាតិប៉ោយប៉ែត មុនថ្ងៃដែលអាជ្ញាធរថៃប្រកាសបិទព្រំដែន ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកមណ្ឌលសំចតប៉ោយប៉ែត តាមការបញ្ជូនពីការិយាល័យអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិ

# ការទទួលអំណោយជាសម្ភារៈប្រើប្រាស់ និងសម្ភារៈអនាម័យសម្រាប់ចែកជូនជនងាយរងគ្រោះ និងពលករវិលត្រលប់ ក្នុងអំឡុងនៃការរីករាលដាល ជម្ងឺកូវីដ-១៩



ការទទួលអំណោយពីអង្គការ UNFPA



ការទទួលអំណោយពីអង្គការអេ21 (A21)





ការទទួលអំណោយពីអង្គការការីតាស កម្ពុជាដែលមានតំណាងពីអន្តរសាសនាសម្រាប់ឧបត្ថម្ភដល់ប្រជាជនប្រឈមកូវីដ១៩




ការទទួលអំណោយជាអង្ករ២០តោន ទឹកត្រី ទឹកស៊ីអ៊ីវ និងសម្ភារៈមួយចំនួន ពី សមាគមROTARY CLUB នៅកម្ពុជា




ទទួលម៉ាស់ពីតំណាងស្ថានទូតហ្វីលីពីនប្រចាំព្រះរាជាណាចក្រកម្ពុជា



ទទួលសម្ភារៈអនាម័យ គ្រឿងឧបភោគបរិភោគពីអង្គការAIM អន្តរជាតិ

## ការចុះសំណេះសំណាលសួរសុខទុក្ខពលករវិលត្រឡប់ នៅមណ្ឌលចត្តាឡីស័ក និងសហគមន៍ ដល់គោលដៅ



ការចុះសាកសួរសុខទុក្ខ នៅមណ្ឌលចត្តាឡីស័ក ស្រុកមាល័យ ខេត្តបន្ទាយមានជ័យ



ប្រគល់ជូនសម្ភារៈដល់កងកម្លាំងប្រចាំការ នៅច្រកព្រំដែនអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ



នាំយកសម្ភារៈទៅប្រគល់ជូន កម្លាំងឈរជើងនៅទីតាំងទទួលពលករបណ្ដោះអាសន្នច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង



ជួបសំណេះសំណាលសួរសុខទុក្ខ និងចែកជូនសម្ភារៈគ្រឿងឧបភោគបរិភោគនៅស្រុកបវេល ខេត្តបាត់ដំបង





លោក ម៉ៃ ទុំ និងលោក លឹមទិត្យ តំណាង UNFPA សហការជាមួយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចុះស្រាវជ្រាវ ស្ថានភាពជួញដូរមនុស្ស ឆ្លងកាត់ព្រំដែន កម្ពុជា ឡាវ និងបានជួបសំណេះសំណាល និងប្រគល់ជូនអំណោយ ប្រជាពលរដ្ឋភូមិសំរោង ឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ជាប់ព្រំដែនឡាវ








# កិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍ប្រឆាំងការជួញដូរមនុស្ស ប្រចាំឆមាស និងប្រចាំឆ្នាំ ឆ្នាំ២០២០










របាយការណ៍ឆមាស និងរបាយការណ៍ឆ្នាំ ត្រូវបានផ្ទៀងផ្ទាត់ ត្រួតពិនិត្យ ដោយកិច្ចប្រជុំជាមួយលេខាធិការដ្ឋាន គ.រ.ប.ជ និងគ.ខ.ប.ជ ទាំង ២៥ លេខាធិការដ្ឋាននៃក្រុមការងារអន្តរក្រសួង-ស្ថាប័នទាំង៦ និងអង្គការដៃគូជាតិ និងអន្តរជាតិ ដែលបានធ្វើការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដើម្បីធានាថា ទិន្នន័យព័ត៌មានដែលទទួលបាន ជាក់លាក់ អាចជឿជាក់បាន ។

# វគ្គបណ្តុះបណ្តាលជំនាញពង្រឹងសមត្ថភាព និងមន្ត្រីតាមបណ្តាខេត្ត គ.ជ.ប.ជ






វគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ
ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តបាត់ដំបង




វគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ
ដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប នៅខេត្តប៉ៃលិន




សិក្ខាសាលាស្តីពីការលើកកម្ពស់កិច្ចការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ
ក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ សហការរៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ និងអង្គការដៃគូ

# សិក្ខាសាលាថ្នាក់ជាតិ-អន្តរជាតិ និងកិច្ចសហការជាមួយអង្គការដៃគូរអភិវឌ្ឍន៍








កិច្ចប្រជុំជាមួយប្រតិភូតំណាងនៃប្រទេសបញ្ជូនពលករ រួមមាន កម្ពុជា ភូមា វៀតណាម ឡាវ




សិក្ខាសាលារៀបចំផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីកិច្ចការពារកុមារ





សិក្ខាសាលាថ្នាក់ជាតិ ស្តីពីសូចនាករទេសន្តរប្រវេសន៍នៅកម្ពុជា និងការត្រៀមអនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ សហការរៀបចំដោយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ IOM




សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារួមគ្នានិងផែនការត្រៀមសម្រាប់កិច្ចសហប្រតិបត្តិការមនុស្សធម៌ សម្រាប់ការត្រៀមខ្លួនឆ្លើយតបទៅនឹងបញ្ហាគ្រោះធម្មជាតិ និងការវិលត្រឡប់នៃប្រជាជនទេសន្តរប្រវេសន៍ក្នុងស្ថានភាពកូវីដ ១៩






កិច្ចប្រជុំពង្រឹងកិច្ចសហការ ជាមួយអង្គការដៃគូរអភិវឌ្ឍនានា ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយនឹងអាជ្ញាធរខេត្តគោលដៅ






កិច្ចប្រជុំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស Child Fund

## កិច្ចប្រជុំក្រុមការងារបច្ចេកទេស គ.ជ.ប.ជ និងអង្គការ IOM ដើម្បីពិភាក្សាអំពីគោលបំណងកតិកាសញ្ញាពិភពលោក



## ពិធីចុះហត្ថលេខា និងប្រកាសគម្រោង Grab for good គាំទ្រមនុស្សថ្លង់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស



សិក្ខាសាលានៅខេត្តសៀមរាប រៀបចំដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ Caritas Swiss ប្រចាំកម្ពុជា ស្តីពីកិច្ចសហការ ផ្តល់សេវាដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលនឹងអនុវត្តនៅមណ្ឌល ទទួលពលករស្រុកកំរៀង










សិក្ខាសាលាផ្ទៀងផ្ទាត់បញ្ជាក់ របកគំហើញ និងអនុសាសន៍ កំណត់ផែនទីភាគីពាក់ព័ន្ធផ្នែកសមភាព និងបរិយាប័ន្ន







# កិច្ចប្រជុំជាមួយអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជា ស្ដីពីវឌ្ឍនភាពនៃកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា










ជំនួបរវាងគណៈប្រតិភូស្ថានទូតសហរដ្ឋអាមេរិក ដឹកនាំដោយឯកឧត្តម **Patrick Murphy** ឯកអគ្គរដ្ឋទូត វិសាមញ្ញ និងពេញសមត្ថភាពសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូអន្តរក្រសួងកម្ពុជា៖ លើកទី១ ដឹកនាំដោយ លោកជំទាវវេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី អនុប្រធាន គ.ជ.ប.ជ និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងលើកទី២ ដឹកនាំដោយ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ







# អនុស្សរណៈនៃការយោគយល់គ្នា រវាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយអង្គការជាតិ និងអន្តរជាតិ





ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង គ.ជ.ប.ជ និងអង្គការ Cambodia-Acts





ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង គ.ជ.ប.ជ និងអង្គការមូលនីធិអេ២១ (A21)






ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង គ.ជ.ប.ជ និងអង្គការឃែរ (CARE)



ជំនួបពិភាក្សាការងាររវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងតំណាងស្ថានទូត អាមេរិក និងអង្គការ អភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក USAID



ការជួបជុំលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានីខេត្តគ.រ.ប.ជ/ គ.ខ.ប.ជ ប្រចាំឆ្នាំដើម្បីត្រួតពិនិត្យរបាយការណ៍ការងារ

# យុទ្ធនាការផ្សព្វផ្សាយ ដើម្បីលើកកម្ពស់សុវត្ថិភាពអ៊ីនធើណិត សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ













យុទ្ធនាការនេះរៀបចំឡើងដោយមានការគាំទ្រពីអង្គការសកម្មភាពដើម្បីកុមារ (APLE) ដោយមានការអញ្ជើញចូលរួម ពីមន្ត្រីជាន់ខ្ពស់ នៃក្រសួង-ស្ថាប័ន រាជធានី-ខេត្ត អ្នកអនុវត្តការងារនៅតាមបណ្តាសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ លោកគ្រូ អ្នកគ្រូ យុវជនកាកបាទក្រហម យុវជនកាយរិទ្ធិ សិស្សានុសិស្ស ប្រមាណជាង៥០០នាក់

## ជំនួបពិភាក្សារវាងគណៈប្រតិភូស្ថានទូតសហរដ្ឋអាមេរិក និងអគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីវឌ្ឍនភាពនៃការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស នៅកម្ពុជា









## ការចុះតាមដានគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ដែលអនុវត្តក្នុងខេត្តបី គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប







## សកម្មភាពពាក់ព័ន្ធនឹងការអនុវត្តច្បាប់ របស់ក្រុមការងារអនុវត្តច្បាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ




កិច្ចប្រជុំក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ




វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពី ការលើកកម្ពស់កិច្ចការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ




ការបង្ក្រាបករណីជួញដូរមនុស្ស កេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទ និងការនាំមនុស្សឆ្លងដែនខុសច្បាប់




# សកម្មភាពពាក់ព័ន្ធ នឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ (COMMIT Regional Taskforce Meeting) និងកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រី លើកទី១៤ (14th COMMIT Senior Official Meeting) តាមរយៈប្រព័ន្ធអនឡាញ






ការងារបណ្តុះបណ្តាល ដោយមានកិច្ចសហការជាមួយស្ថាប័នដៃគូ និងអង្គការពាក់ព័ន្ធ















ទោះបីក្នុងដំណាក់កាលនៃការរីករាលដាលជម្ងឺ កូវីដ ១៩ ដែលគួរឲ្យភ័យខ្លាចក៏ដោយ តែរាជរដ្ឋាភិបាល ជាពិសេស គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដៃគូពាក់ព័ន្ធ ដែលមានឆន្ទៈ និងសកម្មភាព ចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តែងតែព្យាយាមរកគ្រប់មធ្យោបាយ ដើម្បីជួបពិភាក្សាដោយផ្ទាល់ និងពីចម្ងាយ ដើម្បីរិះរកវិធានការឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងភាពប្រឈមជាក់ស្តែងចំពោះមុខ

# សកម្មភាពពាក់ព័ន្ធ ការងារបង្ការទប់ស្កាត់





ការចុះអប់រំផ្សាល់ នៅតាមសហគមន៍ អំពីវិធានការពីររួមគ្នា គឺការបង្ការទប់ស្កាត់ការឆ្លង និងចម្លង កូវីដ ១៩ និងអំពើជួញដូរមនុស្ស

សិក្ខាសាលារបស់ក្រុមការងារបង្ការទប់ស្កាត់ស្តីពី វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្របង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ដឹកនាំដោយឯកឧត្តម ស **សុខា** រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា





សកម្មភាពចងក្រងសៀវភៅមេរៀនស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់សិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សា





កិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងកែសម្រួល ខ្លឹមសារសៀវភៅអប់រំស្តីពីការបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស សម្រាប់សិស្សកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដើម្បីបោះពុម្ពលើកទី១





# សកម្មភាពពាក់ព័ន្ធនឹងសុវត្ថិភាពពលករ នៅគ្រប់ដំណាក់កាលនៃទេសន្តរប្រវេសន៍



កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារលើកទី៦ស្តីពីកិច្ចសហប្រតិបត្តិការ លើវិស័យការងារសម្រាប់ប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាម CLMTV តាមរយៈVideo Conference



សិក្ខាសាលាថ្នាក់ជាតិ ស្តីពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍ និងការអនុវត្តកតិកាសញ្ញាពិភពលោក GCM





សិក្ខាសាលាត្រីភាគីត្រៀមថ្នាក់ជាតិសម្រាប់កម្ពុជាចូលរួមកិច្ចប្រជុំវេទិកាអាស៊ានលើកទី១៣៖13th AFML ស្តីពីការគាំទ្រពលករទេសន្តរប្រវេសន៍ក្នុងពេលជំងឺរាតត្បាត COVID-19





កិច្ចពិភាក្សាទ្វេភាគី កម្ពុជា-ថៃ «ស្តីពី សេចក្តីព្រាង នីតិវិធីប្រតិបត្តិស្តង់ដា សម្រាប់កិច្ចសហការអនុវត្តច្បាប់» គាំទ្រដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ IOM នៅសណ្ឋាគារ កាំបូឌីយ៉ាណា





សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីភាពងាយរងគ្រោះរបស់ជនបម្លាស់ទី ការឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងការធ្វើសមាហរណកម្ម

# សកម្មភាពពាក់ព័ន្ធនឹងកិច្ចការយុត្តិធម៌





















លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប បានអនុវត្តសកម្មភាពពង្រឹងកិច្ចសហការ រវាងស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធបានល្អប្រសើរ ជាពិសេស ស្ថាប័នអយ្យការ និងនគរបាលយុត្តិធម៌ ដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ វគ្គបណ្តុះបណ្តាលច្បាប់ស្តីពី យុត្តិធម៌ អនីតិជន និងកិច្ចការពារកុមារ ត្រូវបានផ្តល់ដល់អធិការ អធិការរងទទួលបន្ទុកការងារព្រហ្មទណ្ឌ កិច្ចការប៉ុស្តិ៍ នាយប៉ុស្តិ៍ នាយរងប៉ុស្តិ៍ មេបញ្ជាការកងរាជាវុធហត្ថ ទទួលព្រហ្មទណ្ឌ និងជំនួយការកងរាជអាវុធហត្ថស្រុក ដែលជាអ្នកអនុវត្តផ្ទាល់ក្នុងប្រព័ន្ធការងារយុត្តិធម៌ ។









# សកម្មភាពពាក់ព័ន្ធ នឹងកិច្ចការពារជនរងគ្រោះ







សិក្ខាសាលាបណ្តុះបណ្តាល ស្តីពី បទដ្ឋាននៃការអនុវត្តបែបកុមារមេត្រី ដើម្បីការពារជនរងគ្រោះនៃអំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើជនរងគ្រោះជាអនីតិជន







វគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរ ដើម្បីផ្តល់សេវាសមស្រប











សិក្ខាសាលាស្តីពីការព្រាងគោលនយោបាយថ្នាក់ជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ គាំទ្រដោយអង្គការអាយអូអឹម

# សកម្មភាពផ្សេងៗទៀត របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ជាក្រុមជំនាញបច្ចេកទេស ដើម្បីផ្តល់ធាតុចូល ក្នុងការរៀបចំផែនការ គោលនយោបាយ អនុស្សរណៈ កិច្ចព្រមព្រៀង មេរៀនបណ្តុះបណ្តាល ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មពលកម្ម អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ












## កិច្ចប្រជុំការងារទៀងទាត់ក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងតាមបណ្តាក្រុមជំនួយកិច្ចការបច្ចេកទេស














## ការរៀបចំ និងចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំ និងអន្តរក្រសួង ស្ថាប័ន ពាក់ព័ន្ធអំពើជួញដូរមនុស្ស











# កិច្ចប្រជុំថ្នាក់តំបន់ និងអន្តរជាតិ ត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ



























# សមិទ្ធិផលការងារព័ត៌មានវិទ្យា របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ




គេហទំព័រផ្លូវការរបស់
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស



ទំព័រហ្វេសប៊ុកផ្លូវការរបស់
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស




បណ្ណាសាររបស់
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស






ប្រព័ន្ធទំនាក់ទំនង Telegram Messenger ប្រើប្រាស់
ក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ



Mobile App សម្រាប់ងាយស្រួលដល់ប្រជាពលរដ្ឋ ស្វែងរកទីតាំងអង្គការដៃគូអភិវឌ្ឍន៍ ដែលផ្តល់សេវាពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស (ជួយជនរងគ្រោះ)

និង ប្រព័ន្ធព័ត៌មានបញ្ចូលទិន្នន័យរបស់ពលករ ឆ្លងកាត់ព្រំដែន

# សកម្មភាព របស់គណៈកម្មាធិការថ្នាក់ក្រោមជាតិ គ.រ.ប.ជ/គ.ខ.ប.ជ


























































កិច្ចប្រជុំ




កិច្ចប្រជុំ
































NATIONAL COMMITTEE FOR COUNTER TRAFFICKING(N.C.C.T)
MITSUBISHI FUSO

# យុទ្ធនាការចាក់សាំងបង្ការជម៉ឺកូវីដ១៩ របស់រាជរដ្ឋាភិបាលជូនប្រជាពលរដ្ឋកម្ពុជា






ការចាក់ថ្នាំបង្ការកូវីដ១៩ ជូនថ្នាក់ដឹកនាំរាជរដ្ឋាភិបាល






ការចាក់ថ្នាំបង្ការកូវីដ១៩ ជូនបងប្អូនប្រជាពលរដ្ឋ

ការចាក់ថ្នាំបង្ការកូវីដ១៩ ជូនដល់ទណ្ឌិតក្នុងពន្ធនាគារ




ផ្តើមចេញពីការចូលរួម រៀបចំ
ផ្តល់ធាតុចូល និងចូលរួមអនុម័ត



ឈានឆ្ពោះទៅកាន់ ប្រទេសជ័យលាភី
ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក
(GCM)




របាយការណ៍នេះអាចទាញយកពី គេហទំព័រ

**www.ncct.gov.kh**


បោះពុម្ពដោយៈ

**ថវិកាជាតិ**

ចូលរួមឧបត្ថម្ភគាំទ្រដោយៈ